00758968

**E1/17.1**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Dec-2011, 15:35
CMS/CFO: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក អាន់ឌ្រូ ខេលី *(Mr.Andrew CAYLEY)*

លោក សេង ប៊ុនឃាង

លោក ឌែល លីសាក់ *(Mr. Dale LYSAK)*

លោក ច័ន្ទ តារាស្មី

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោក ប៉ាស្កាល់ អូប៊ីង *(Mr. Pascal AUBOUIN)*

លោក ហុង គឹមសួន

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អេនឌ្រូ អ៊ីនួហ្ស៊ី | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក អាកទួរ វែកគែន | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | អង់គ្លេស |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក ក្លាន វ៉ិត | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅជនជាប់ចោទ នួន ជា**

សួរដោយចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ផ្ដើមពី ........................................................ទំព័រ ០៣

**ការសួរសំណួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ក្លាន ទ៉ិត**

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................ទំព័រ ២២

សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្ដើមពី ........................................................ទំព័រ ២៧

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯលះ........................................................ទំព័រ ៦០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:៤៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

កិច្ចដំណើរការសវនាការពិភាក្សាដេញដោលជនជាប់ចោទ នួន ជា កាលពីម្សិលមិញ ដោយអង្គជំនុំជម្រះមិនទាន់បានចប់នៅឡើយទេ ដោយសារមូលហេតុលោក នួន ជា មានបញ្ហាសុខភាពសម្ពាធឈាមខ្ពស់។ ហេតុដូច្នេះហើយបានជាអង្គជំនុំជម្រះ បានសម្រេចផ្អាកកិច្ចដំណើរការសវនាការមុនពេលកំណត់៤០នាទី ដើម្បីទុកលទ្ធភាពឲ្យលោក នួន ជា សម្រាកឲ្យបានច្រើនដើម្បីមានលទ្ធភាពអាចឆ្លើយនឹងសំណួរដេញដោលចំពោះគាត់ ពាក់ព័ន្ធនឹងអង្គហេតុដែលអង្គជំនុំជម្រះលើកមកធ្វើសវនាការនៅវគ្គដំបូងនេះ។

[០៩:០៥:២៩]

ហើយនៅព្រឹកនេះទៀតសោតអង្គជំនុំជម្រះ ក៏បានកត់សម្គាល់ឃើញផងដែរថា លោក នួន ជា នៅមានបញ្ហាសុខភាព ដោយសម្ពាធឈាមរបស់គាត់ឡើងខ្ពស់ខុសពីធម្មតា ដោយផ្អែកតាមរបាយការណ៍របស់ពេទ្យប្រចាំការ។ ដោយអាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមជម្រាបជូនភាគី និងសាធារណជនបានជ្រាបថា អង្គជំនុំជម្រះនឹងបន្តនូវកិច្ចដំណើរការសួរដេញដោលជនជាប់ចោទ នួន ជា នៅព្រឹកនេះហើយរហូតដល់ពេលរសៀល ក្រោយពេលអាហារថ្ងៃត្រង់អង្គជំនុំជម្រះមិនសួរដេញដោលចំពោះគាត់ទៀតទេ អង្គជំនុំជម្រះនឹងជ្រើសរើសយកដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដើម្បីយកមកស្តាប់នូវសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ ជាការជំនួសពេលវេលា ដែលមានមូលហេតុដោយសារបញ្ហាសុខភាពរបស់លោក នួន ជា។ នេះជាការកែប្រែនូវកិច្ចដំណើរការសវនាការខ្លះ ដូចអង្គជំនុំជម្រះបានជម្រាបហើយបញ្ហានេះគឺ ដោយសារបញ្ហាភាពវ័យចាស់ ទាំងជនជាប់ចោទ ទាំងភាគីចូលរួម ជាពិសេសសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលស្រដៀងគ្នានេះដែរ។ អ៊ីចឹងហើយបានជានៅក្នុងរបៀបវារៈ កាលបរិច្ឆេទនៃកិច្ចដំណើរការសវនាការដែលបានគ្រោងទុកគឺ ពីនេះទៅមុខនឹងអាចមានការប្រែប្រួលខ្លះ។

[០៩:០៧:២០]

អនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅចំពោះមុខអង្គជំនុំជម្រះនេះ។

**លោក ម៉ៃខល ផេសមិនៈ**

អរុណសួស្តី! ខ្ញុំសូមស្នើទៅលើបញ្ហានេះម្តងទៀតថា តើយើងអាចធ្វើការវាយតម្លៃទៅលើស្ថានភាពសុខភាពរបស់ជនជាប់ចោទម្តងទៀតទេ ក្រោយពីយើងឈប់សម្រាក? ដើម្បីជាប្រតិចារឹកសម្រាប់សវនាការកូនក្តីរបស់ខ្ញុំគឺបោះបង់សិទ្ធិមិនចូលរួមនៅក្នុងរសៀលថ្ងៃនេះ។ លោក នួន ជា ដែលជាជនជាប់ចោទ គាត់មិនចង់មានវត្តមានទេនៅក្នុងរសៀលថ្ងៃនេះ។ សូមអរគុណ។

[០៩:០៨:៤០]

**ប្រធានអង្គជំនុំៈ**

អម្បាញ់មិញនេះ អង្គជំនុំជម្រះគឺរូបខ្ញុំ បានជម្រាបជូនភាគី និងសាធារណជនរួចហើយ អំពីស្ថានភាពចំពោះមុខនេះ ដែលអង្គជំនុំជម្រះបានទទួលនូវកំណត់ហេតុ ដែលបានធ្វើឡើងដោយវេជ្ជបណ្ឌិត គីម សំសាន ដែលជាវេជ្ជបណ្ឌិតប្រចាំការនៅបន្ទប់សវនាការនេះ។ ហើយអម្បាញ់មិញនេះ យើងបានជម្រាបច្បាស់លាស់ថា ការប្រមើលមើលនូវបញ្ហាសុខភាពនេះ លទ្ធភាពរបស់គាត់អាចនឹងឆ្លើយនឹងសំណួរទាំងឡាយនៅក្នុងអំឡុងពេលព្រឹកនេះ ហើយរសៀលនេះអង្គជំនុំជម្រះបានធ្វើការផ្លាស់ប្តូរនូវការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបជំនួសការស្តាប់ជនជាប់ចោទ ដោយសារមូលហេតុនេះ។

ដោយឡែកបញ្ហាផ្សេងទៀត ដែលសំណើសុំរបស់មេធាវី ដោយសារយើងបានត្រៀមសព្វគ្រប់នូវវេជ្ជបណ្ឌិតសម្រាប់ពិនិត្យសុខភាពជនជាប់ចោទ នៅក្នុងអំឡុងពេលដំណើរសវនាការក្នុងស្ថានភាពណាមួយ គឺយើងនឹងអនុញ្ញាត ឬក៏ឲ្យវេជ្ជបណ្ឌិតធ្វើការត្រួតពិនិត្យសុខភាព ហើយរាយការណ៍ជាបន្ទាន់មកអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះមានវិធានការជាក់ស្តែងតាមកាលៈទេសៈសមស្រប។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីបន្តការតាំងសំណួរចំពោះលោក នួន ជា។

សូមអញ្ជើញលោកស្រីចៅក្រម!

សូមអញ្ជើញលោក នួន ជា!

[០៩:១១:០២]

**លោក នួន ជា៖**

ស្នើសួរឲ្យខ្លីៗបន្តិច កុំឲ្យវែងពេក ពីព្រោះខួរក្បាលខ្ញុំវាភ្លេចមុខភ្លេចក្រោយ ជួនណាឆ្លើយមិនអស់បញ្ហា។ ដូច្នោះស្នើសួរខ្លីៗ ដើម្បីខ្ញុំស្រួលឆ្លើយ។ សូមស្នើលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទៗ អរគុណនូវសំណើសុំនេះ។ ដូច្នេះសូមលោកចៅក្រម និងភាគីដែលគ្រោងនឹងសួរគាត់ទៅថ្ងៃក្រោយ គឺសូមរៀបចំសំណួរខ្លីៗ ដើម្បីឲ្យគាត់ងាយស្តាប់យល់ ហើយនិងងាយឆ្លើយ។

សូមអញ្ជើញមេធាវី!

**លោក អាកទូរ វែកគែន៖**

បាទ, សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរខ្លីមួយ គឺថាខ្ញុំចង់សួរដល់លោកប្រធាន គឺថាតើដើមបណ្តឹងរដ្ឋប្បវេណីមួយណា ដែលថា យើងនឹងស្តាប់នៅរសៀលនេះនោះ តើនៅក្នុងលំដាប់លំដោយបែបណាទៅ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីនេះ យើងបានជម្រាបជូននៅក្នុងអនុស្សរណៈ អំពីការកំណត់នូវដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ដែលយើងសួរលើកដំបូង។ ឥឡូវនេះ គឺសូមបញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណី ដែលយើងនឹងគ្រោងសួរនៅរសៀលនេះគឺ TCCP185។ ក្នុងចំណោមពីររូបនេះ យើងសួរមួយរូបមុនគឺ TCCP185។

សូមអញ្ជើញលោកស្រីចៅក្រម!

[០៩:១២:៤៨]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន។

**ស៖** លោក នួន ជា នៅក្នុងដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ ត្រង់កថាខណ្ឌ៨៦៦ បានលើកឡើងថា លោកមានតួនាទីនៅក្នុងជួរយោធានៅចន្លោះឆ្នាំ៧០ ដល់៧៥។ តើការលើកឡើងនៅក្នុងកថាខណ្ឌនោះត្រឹមត្រូវដែរឬទេ?

**លោក នួន ជា៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមអនុញ្ញាតឆ្លើយនឹងសំណួរ។

**ឆ៖** ខ្ញុំជម្រាបហើយជម្រាបទៀត ថាខ្ញុំមិនដែលនៅក្នុងគណៈកម្មាធិការឃោធាទេ។ ខ្ញុំជាគណៈអចិន្ត្រៃយ៍ទទួលបន្ទុកខាងអប់រំផ្ទៃក្នុងបក្ស តែប៉ុណ្ណឹង តែម្យ៉ាងប៉ុណ្ណោះទេ។

**ស៖** តាមពិតលោកមានតួនាទីផ្សេងទៀត ដែលក្នុងនោះជាក្រៅពីអនុលេខា គឺលោកមានតួនាទីក្នុងការអប់រំ។ ហើយលោកក៏មានតួនាទីក្នុងការធ្វើការឃោសនាផងដែរ នៅក្នុងទសវត្សរ៍ទី៥០ នៅពេលដែលលោកវិលត្រឡប់មកពីប្រទេសថៃវិញ។ តើពិតជាត្រឹមត្រូវដែរឬទេ ត្រង់ចំណុចនេះ?

[០៩:១៤:៣៩]

**ឆ៖** តាមចំណុចនេះខ្ញុំទទួលថាត្រឹមត្រូវ គឺធ្វើការឃោសនាដោយមាត់ទទេផង ឃោសនាដោយសរសេរកាសែតផង សរសេរអត្ថបទផ្សេងៗផង ហើយចុះទៅឃោសនាក្នុងប្រជាជនផង។ សូមជម្រាបលោកស្រីប៉ុណ្ណឹង។

**ស៖** ថាតើលោកមានតួនាទីនៅក្នុងការរៀបចំបង្កើតនូវទស្សនាវដ្ដីទង់បដិវត្តន៍ឬទេ? គឺទស្សនា-វដ្ដីទង់បដិវត្តន៍ ដែលវាជាឈ្មោះទស្សនាវដ្ដីនៅពេលនោះ តើលោកមានតួនាទីក្នុងការរៀបចំទៅលើទស្សនាវដ្ដីហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំគ្មានតួនាទីរៀបចំទស្សនាវដ្ដីទង់បដិវត្តន៍ទេ នេះជាតួនាទីរបស់លេខាបក្ស ប៉ុល ពត អ្នករៀបចំ។

**ស៖** ថាតើលោកជួយ លោក ប៉ុល ពត ជាមួយនឹងសម្ភារឯកសារផ្សេងៗដែរឬទេ នៅក្នុងតួនាទីរបស់លោក ក្នុងការអប់រំ និងឃោសនានោះ?

**ឆ៖** សូមជម្រាបលោកចៅក្រម លោកប្រធាន អត់ទោស ខ្ញុំក្នុងតួនាទី ខ្ញុំជាឃោសនាអប់រំ ខ្ញុំមានតួនាទីអប់រំខាងមាគ៌ានយោបាយបដិវត្តន៍ មាគ៌ានយោបាយយុទ្ធសាស្ត្រ យុទ្ធវិធី និងកសាង អប់រំកសាងទស្សនៈ គោលជំហរស្នេហាជាតិ ស្នេហាប្រជាជន ស្នេហាបដិវត្តន៍ ឲ្យកម្មាភិបាលតាំងពីថ្នាក់ភាគ ថ្នាក់តំបន់ ឯថ្នាក់ឃុំខ្ញុំគ្មាននាទីអីទេ នេះសម្រេចនៅថ្នាក់ភាគ ថ្នាក់តំបន់គេធ្វើ។

[០៩:១៧:៤៤]

**ស៖** នៅក្នុងចន្លោះឆ្នាំ១៩៧០ ដល់ ៧៥ ថាតើលោកបានធ្វើដំណើរទៅធ្វើបទឧទ្ទេសនាម ឬធ្វើបទបង្ហាញទៅដល់អង្គការរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងតួនាទីរបស់លោក ជាអ្នកឃោសនា និង

អប់រំ ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ចន្លោះពីឆ្នាំ៧០-៧៥ ខ្ញុំបានធ្វើតួនាទីនេះក្នុងកាលៈទេសៈ ដែលបើកឲ្យខ្ញុំធ្វើ គឺពេលណាមានពេលទំនេរ ខ្ញុំអាចចុះទៅអប់រំខ្លះ ដោយពេល ដោយវេលាមួយរយៈកាល សូមជម្រាប។

**សៈ** នៅពេលនេះខ្ញុំចង់ដឹង ថាតើលោករស់នៅ ស្នាក់នៅទីណា? ហើយថាតើអត្តសញ្ញាណ និងឈ្មោះរបស់លោកដែលប្រើប្រាស់ជាសាធារណៈនោះ គឺឈ្មោះអ្វីដែរ នៅពេលដែលលោកបានវិលត្រឡប់មកពីប្រទេសថៃវិញ? ថាតើត្រឹមត្រូវដែរឬទេ នៅពេលដែលលោកវិលត្រឡប់មកពីប្រទេសថៃនៅក្នុងឆ្នាំ១៩៥១ លោកបានទៅសំឡូត ស្រុកសំឡូត ហើយចូលរួមជាមួយនឹងចលនាតស៊ូ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំស្នាក់នៅមិនទៀងទាត់ទេ ផ្លាស់ឡើងផ្លាស់ចុះ ដើម្បីការពារសេចក្តីសម្ងាត់ ជួនណាខ្ញុំនៅឃុំនេះ ជួនណាខ្ញុំចុះទៅសំឡូត ជួនណាទៅតាសាញ ជួនណាទៅបូព៌ាខ្លះ មិនទៀងទាត់ទេ កន្លែងនៅ។ ប៉ុន្តែកន្លែងដែលរស់នៅជាប្រចាំសម្រាប់ដេកនៅនេះ គឺនៅដងស្ទឹងជីនិត។

**សៈ** នៅចន្លោះឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៣ លោកបានទទួលការអប់រំវគ្គនយោបាយនៅប្រទេសវៀតណាម ដូចដែលលោកបានលើកឡើងកាលពីម្សិលមិញ តើត្រឹមត្រូវដែរឬទេ ត្រង់ចំណុចនេះ?

**ឆ៖** សូមគោរពលោកចៅក្រម! តាមសំណួរនេះ ពីឆ្នាំចន្លោះ៥១ ដល់៥៣ ខ្ញុំក៏បានទទួលការអប់រំខ្លះពីសំណាក់វៀតណាម។

**សៈ** ថាតើនៅចន្លោះឆ្នាំនុ៎ង លោកនៅប្រទេសវៀតណាមនៅចន្លោះឆ្នាំ៥១ ទៅដល់៥៣នោះរហូតឬក៏បានវិលត្រឡប់មកប្រទេសកម្ពុជាវិញដែរ នៅក្នុងចន្លោះពេលនោះមួយចំនួន?

**ឆ៖** សូមជម្រាបលោកប្រធាន ចន្លោះពីឆ្នាំ៥១ ទៅ៥៣ ខ្ញុំមិនដែលបានត្រឡប់មកប្រទេសវិញទេ នៅជួយធ្វើការ និយាយឃោសនាអប់រំ អង្គាល់នោះ មានពេលខ្លះចុះទៅអប់រំ ជួយខាងភាគខាងណោះ។ ដូច្នោះខ្ញុំអត់បានត្រឡប់មកកន្លែងខ្ញុំវិញទេ។

[០៩:២២:៤៩]

**សៈ** នៅពេលដែលលោកវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៣ តើលោកស្នាក់នៅឯណា?

**ឆ៖** ៥៣ ពេលដែលខ្ញុំត្រឡប់មកសំណាក់នៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៥៣ ដូចជាខ្ញុំបានជម្រាបអ៊ីចឹងហើយ គឺម្តងនៅកន្លែងនេះ ម្តងនៅនោះ។ ឧទាហរណ៍ ដូចជានៅបឹងល្វា តាមដងស្ទឹងជីនិត នៅសំឡូត នៅតាសាញ នៅក្រញ៉ូង សម្រេចតែសភាពការណ៍ខ្លាំង បើកាលណាឮស្គរខ្មាំងបុករុកមកកន្លែងនេះ ត្រូវផ្លាស់ទៅកន្លែងនោះ បុករុកមកកន្លែងនោះត្រូវផ្លាស់ទៅកន្លែងនេះ។ ដូច្នោះ កន្លែងរស់នៅរបស់ខ្ញុំវាមិនទៀងទាត់ ពីព្រោះនៅក្នុងសម័យសង្គ្រាមឈ្លបត្រូវចល័តឡើង ចល័តចុះ នៅមួយកន្លែងមិនបានទេ។

**ស៖** ក្រោយពេលកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវបានធ្វើឡើង នៅពេលដែលលោករស់នៅក្នុងទីក្រុងភ្នំពេញ គេគ្រប់គ្នាគិតថាលោកគឺជាអ្នករកស៊ី អាជីវករ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ក្នុងពេលក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ដែលខ្ញុំរស់នៅក្នុងទីក្រុងភ្នំពេញ របររកទទួលទានរបស់ខ្ញុំវាផ្លាស់ប្តូរឡើងផ្លាស់ប្តូរចុះ ដើម្បីឲ្យសមស្របនឹងរូបភាព។ ជួនកាល ខ្ញុំធ្វើជាគ្រូបង្រៀនពិសេសពេលយប់ ជួនកាលខ្ញុំធ្វើជាអ្នករកទទួលទានលក់ដូរនេះនោះ ហើយជួនកាល ខ្ញុំមានស្ម័គ្រទៅធ្វើស្មៀនខាងអាហារ័ណនីហារ័ណ ប៉ុន្តែបានមួយរយៈ ខ្ញុំក៏ឈប់ទៅ ពីព្រោះគ្មានកម្មាភិបាលធ្វើការងារបក្ស។

[០៩:២៦:០៨]

**ស៖** នៅក្នុងឆ្នាំ១៩៦៣ អៀង សារី និង សាឡុត ស ឬក៏ ប៉ុល ពត រត់លាក់ខ្លួនក្នុងព្រៃ ក៏ប៉ុន្តែលោកនៅតែស្នាក់នៅក្នុងទីក្រុងភ្នំពេញដដែល។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ត្រឹមត្រូវ។

**ស៖** ខ្ញុំចង់ដឹងថា តើលោកអាចរក្សាទំនាក់ទំនងជាមួយនឹងចលនាខាងកុម្មុយនីស្តតាមរបៀបណា ដែលលោកបានលាក់ខ្លួនដោយសុវត្ថិភាពនៅក្នុងទីក្រុងភ្នំពេញ? តើលោកអាចពន្យល់ថាតើលោកអាចទំនាក់ទំនងជាសម្ងាត់ពីទីក្រុងភ្នំពេញនេះជាមួយនឹង អៀង សារី និង ប៉ុល ពត ដែលគាត់រត់លាក់ខ្លួនក្នុងព្រៃដោយរបៀបណាក្នុងឆ្នាំ១៩៦៣ នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ការលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ក្នុងការធ្វើការសម្ងាត់ វាប្រែប្រួលឡើង ប្រែប្រួលចុះទៅតាមរូបភាព។ បើខ្ញុំចង់ទាក់ទងជាមួយ ប៉ុល ពត ខ្ញុំត្រូវធ្វើដំណើរមកទាក់ទង ប៉ុល ពត នៅឯជាយដែន ក៏ប៉ុន្តែការរស់នៅក្នុងទីក្រុងភ្នំពេញ វាមិនមែនស្រួលទេ ក្នុងការធ្វើការងារសម្ងាត់។ បើយើងទៅរស់នៅក្នុងចំណោមអាណិកជនចិន ក៏វាមិនស្រប ពីព្រោះវាអាចចោទថា យ៉ាងនេះ យ៉ាងនោះ។ វាពិបាកណាស់ អើបើយើងទៅរស់នៅតាមភូមិ ក៏ពិបាកទៀត ពីព្រោះនៅតាមភូមិ

ពេលនោះមានគិញច្រើន ហើយប្រជាជនតាមភូមិច្រើនតែមកខ្ចីលុយ ស្មានតែខ្ញុំនេះមានលុយមានកាក់ឲ្យខ្ចី។ ដូច្នោះ និយាយរួម ខ្ញុំជម្រាបឲ្យត្រង់ ខ្ញុំទៅរស់នៅជិតចិនលក់ត្របែកត្រាំ លក់កន្ទួតត្រាំវិញទេ។ ខ្ញុំអត់នៅកន្លែងស្រួលបួលទេ វាគ្មានកន្លែង ទៅកន្លែងនេះវាប៉ះអ៊ីចេះ ទៅកន្លែងនោះប៉ះអ៊ីចុះ។ វាមិនស្របនឹងសភាពការណ៍នៃការធ្វើការងារសម្ងាត់។

[០៩:២៩:៣២]

ដូច្នោះបើអ្នកណាធ្លាប់ធ្វើការងារសម្ងាត់ បានដឹងថាសភាពការណ៍ វាលំបាក វាស្មុគស្មាញ វាអីៗយ៉ាងម៉េចៗនោះ លំបាកណាស់។ ដេកយប់មិនដែលបានពេញភ្នែកទេ។ តែម៉ោងបី ត្រូវក្រោកត្រៀមហើយ ពីព្រោះតាមធម្មតាគិញច្រើនទៅរកចាប់អ្នកបដិវត្តន៍ម៉ោងបីទាបភ្លឺ កុំឲ្យរត់ទាន់។ ដូច្នោះត្រូវត្រៀមខោអាវអីស្រេចនេះ ខ្ញុំសូមជម្រាបឲ្យអស់សេចក្ដី ដើម្បីកុំឲ្យសង្ស័យ។

**ស៖** លោកបានលើកឡើងថា ក្នុងអំឡុងពេលនោះ ដែលលោកស្នាក់នៅក្នុងទីក្រុងភ្នំពេញ ប៉ុល ពត និង អៀង សារី និងបុគ្គលផ្សេងទៀត គឺមានទីតាំងមូលដ្ឋាននៅជិតព្រំដែនវៀតណាម ហើយប្រសិនបើលោកចង់ទាក់ទងជាមួយនឹង ប៉ុល ពត លោកត្រូវធ្វើដំណើរទៅជាយដែន។ ដូច្នេះ ថាតើលោកអាចទាក់ទងតាមរយៈសារទូរលេខ ឬក៏តាមនីរសារដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាប ដូចតទៅនេះ ពេលដែល ប៉ុល ពត, អៀង សារី ទៅនៅព្រំដែន ហើយខ្ញុំនៅភ្នំពេញចង់ទាក់ទង គឺទាក់ទងតាមរយៈនីរសារនាំសំបុត្រ។ ខ្ញុំជិះឡានពីភ្នំពេញទៅចុះកន្លែងមួយ ហើយមាននីរសារគេចាំទទួលចុះពីឡានដើរទៅចូលព្រៃទៅតាមជាយដែនទៀត ដើម្បីទៅជួប គេហៅថា "មន្ទីរ ១០០" របស់ ប៉ុល ពត នោះ។ ឯការណ៍នេះ ក៏មិនមែនជាការស្រួល ពីព្រោះគិញតាមដានជាប់។ ដូច្នោះត្រូវប្រែខ្លួនមួយរយជំពូក ជួនកាលធ្វើជាអ្នករាជការ ជួនកាលធ្វើជាអ្នករកស៊ី។ នេះខ្ញុំសូមជម្រាប។

[០៩:៣២:៣២]

**ស៖** នៅក្នុងឆ្នាំ១៩៧០ នៅពេលដែលរដ្ឋប្រហារបានទម្លាក់សម្ដេចសីហនុ លោកបានរត់ចេញពីទីក្រុងភ្នំពេញដើម្បីចូលទៅលាក់ខ្លួនក្នុងព្រៃដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ពេលនោះ ពេលដែលគេទម្លាក់ព្រះករុណា ខ្ញុំនៅបើកសាលាអប់រំនៅខាងបូព៌ាឯណោះទេ។ ដូច្នោះ ខ្ញុំមិនបាននៅភ្នំពេញទេ ទាល់តែរយៈបីបួនខែ បានជាខ្ញុំរកផ្លូវនីរសារទាក់ទងត្រឡប់ទៅភ្នំពេញវិញ។

**ស៖** ដូច្នេះ លោកនិយាយថា លោកមិនបានរត់ទៅលាក់ខ្លួនក្នុងព្រៃនៅតាមព្រំដែនវៀតណាម នៅពេលដែលមានរដ្ឋប្រហារទម្លាក់ព្រះករុណានោះទេ គឺលោកបានវិលត្រឡប់ចូលមកទីក្រុងភ្នំពេញវិញ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** ដូច្នេះ នៅពេលដែលមកនៅក្នុងទីក្រុងភ្នំពេញនោះ តើលោកបានស្នាក់នៅរយៈប៉ុន្មានដែរនៅពេលនោះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ដែរ ប៉ុន្តែបើខ្ញុំចាំប្រហែលជាប្រាំ ឬប្រាំមួយខែ នៅទីក្រុងភ្នំពេញ។

**ស៖** នៅពេលនោះ តើលោកបានទៅលាក់ខ្លួននៅព្រំដែនជាមួយនឹង ប៉ុល ពត, អៀង សារី និងជនដទៃទៀតដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានទៅលាក់ខ្លួននៅក្នុងព្រៃជាមួយ ប៉ុល ពត, អៀង សារីទេ យូរៗខ្ញុំទៅជួបម្តង មួយខែពីរខែទៅជួបគ្នាម្តង ដើម្បីពិភាក្សា ដើម្បីខ្ញុំយកសភាពការណ៍ទៅរាយ-ការណ៍ហើយទទួលនូវការណែនាំពី ប៉ុល ពត មកវិញ តើត្រូវដំណើរការយ៉ាងម៉េច? ត្រូវរៀបចំបក្សយ៉ាងម៉េច? អីយ៉ាងម៉េច? ជួនណាពីរខែទៅម្តង ជួនណាមួយខែទៅម្តង សម្រេចតែនឹងសភាពការណ៍វាអំណោយឲ្យ គឺតាមការចាំបាច់នៃសភាពការណ៍ក្នុងរយៈកាលនីមួយៗ។

**ស៖** ដូច្នេះ លោកបន្តធ្វើការងារដ៏គ្រោះថ្នាក់ដដែលនៅក្នុងទីក្រុងភ្នំពេញ បានន័យថាលោកនៅតែធ្វើការអប់រំ និងធ្វើការឃោសនានៅទីក្រុងភ្នំពេញ ហើយពិភាក្សាអំពីស្ថានភាពដែលកើតឡើងមួយខែម្តង ឬក៏ពីរខែម្តងជាមួយនឹង ប៉ុល ពត និងកម្មាភិបាលដឹកនាំដទៃទៀតដែលរស់នៅព្រំដែនវៀតណាម តើពិតជាដូច្នោះដែរឬទេ?

**ឆ៖** ពិតដូច្នោះមែន។

[០៩:៣៦:៥៧]

**ស៖** តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ ថាតើនៅពេលណាគេផ្លាស់ប្តូរមន្ទីរ១០០ ពីព្រំដែនវៀតណាមចូលមកក្នុងទឹកដីកម្ពុជា?

**ឆ៖** និយាយរួមតាមខ្ញុំសង្កេតណា ថាព្រំដែនវៀតណាមមែន ប៉ុន្តែការពិតតាមដែលដឹងដីហ្នឹងជាដីខ្មែរទេ មិនមែនដីវៀតណាមទេ។ ក៏ប៉ុន្តែពេលនោះ នៅទឹកដីវៀតណាម គេគ្មានកន្លែងនៅពីព្រោះអាមេរិកវាទម្លាក់គ្រាប់បែកខ្លាំង ដល់អាមេរិកទម្លាក់គ្រាប់បែកខ្លាំងអីចឹងទៅ វៀតណាមនេះត្រូវរំកិល

មកនៅជាប់នឹងជាយដែនខ្មែរ ជួនកាលលូកមកដីខ្មែរវិញ។ តាមខ្ញុំដឹង វៀតណាមគេឆ្លាតដែរ គេមានទាក់ទងជាមួយមេឃុំដែលនៅតាមព្រំដែនទិញដីខ្មែរយើងមួយគីឡូ ពីរគីឡូ ដើម្បីគេនៅ ហើយមេឃុំយើងនេះក៏លក់ដីហ្នឹងឱ្យគេ។ នេះខ្ញុំដឹងច្បាស់តែម្តង ពីព្រោះ ពួកវៀតណាមនិយាយប្រាប់ខ្ញុំ ថាដីនេះដីខ្មែរទេ ក៏ប៉ុន្តែពួកខ្ញុំទិញពីមេឃុំ។ សូមជម្រាបលោកចៅក្រម-- លោកប្រធានប៉ុណ្ណឹង។

[០៩:៣៨:៥៩]

**ស៖** ប៉ុន្តែ មន្ទីរ១០០ បានផ្លាស់ប្តូរទីតាំង ជាពិសេស នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាកាន់តែទទួលជោគជ័យនៅក្នុងការចាប់យកដី ហើយមន្ទីរ១០០ នេះបានផ្លាស់ប្តូរទីតាំងពីពេលមួយទៅពេលមួយហើយចូលមកដាក់ទីតាំងនៅក្នុងទីក្រុងភ្នំពេញ តើមានការផ្លាស់ប្តូរអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំសូមសួរវិញថា ឆ្នាំណា?

**ស៖** ខ្ញុំអត់មានការកត់ត្រាថ្ងៃនៅចំពោះខ្ញុំទេ គឺនៅចន្លោះឆ្នាំ១៩៧០ ដល់ ១៩៧៥ មន្ទីរ១០០ គឺផ្លាស់ប្តូរពីទីតាំងនៅជាប់ព្រំដែននោះបានផ្លាស់ប្តូរមកទីតាំងកំពង់ធំ កំពង់ចាម កំពង់ឆ្នាំង។ តើពិតជាមានការផ្លាស់ប្តូរទីតាំងមកអ៊ីចឹងដែរឬទេ?

**ឆ៖** សូមបញ្ជាក់ឆ្នាំណាដល់ឆ្នាំណា?

**ស៖** ក្នុងឆ្នាំនោះគឺចន្លោះឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ មន្ទីរ១០០ នេះផ្លាស់ប្តូរទីតាំងពីកន្លែងមួយទៅកន្លែងមួយ តើមានការផ្លាស់ប្តូរទីតាំងដែរឬទេ នៅចន្លោះឆ្នាំ៧០ ដល់៧៥?

**ឆ៖** ៧០, ៧០-៧៥! តាមខ្ញុំចាំ សូមគោរពលោកប្រធាន ពីឆ្នាំ១៩៧០ បាទ ពីឆ្នាំ១៩៧០ ប៉ុលពត បានប្រមូលប្រជុំមជ្ឈិមនៅភូមិមួយ ហៅថា បឹងល្វា ស្រុកសន្ទុក កំពង់ធំ ដើម្បីចាត់តាំងឱ្យកម្មាភិបាលទៅធ្វើការនៅតាមភូមិភាគ។ នេះក្នុងឆ្នាំ១៩៧០ ខែតុលា ឆ្នាំ១៩៧០។

**ស៖** សូមអរគុណ។ ចំណុចមួយទៀតដែលខ្ញុំចង់ដឹងផងដែរនោះ គឺគោលនយោបាយផ្សេងៗដែលបានលើកយកមកពិភាក្សាដោយកម្មាភិបាលដឹកនាំនៃបក្សពលករកម្ពុជា ឬក៏បក្សកុម្មុយនីស្តកម្ពុជា លោកបានជម្រាបចៅក្រម និងអង្គសវនាការ កាលពីពីរសប្តាហ៍មុនថា "នៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ អង្គការរបស់បក្សបានមានការរីកចម្រើនខ្លាំង ហើយលោកបានរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយយុទ្ធសាស្ត្រផ្សេងៗ ថាតើលោកមានការចូលរួមនៅក្នុងការរៀបចំគោលនយោបាយយុទ្ធសាស្ត្រទាំងអស់នោះដែរឬទេ?

[០៩:៤៣:៤៩]

**ឆ៖** អត់ទោសសូមបញ្ជាក់ឆ្នាំណា?

**ស៖** កាលពីពីរសប្តាហ៍មុននៅក្នុងពេលធ្វើសវនាការនេះ លោកបានលើកឡើងថាក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បានន័យថានៅចន្លោះឆ្នាំ១៩៥០ ទៅដល់ ឆ្នាំ១៩៦០ គឺមានការរៀបចំនូវគោលនយោបាយយុទ្ធសាស្ត្រមួយចំនួនបានធ្វើឡើង។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើលោកមានការចូលរួមនៅក្នុងពិភាក្សារៀបចំគោលនយោបាយយុទ្ធសាស្ត្រទាំងអស់នោះដែរឬទេ នៅចន្លោះឆ្នាំ ទសវត្សរ៍ឆ្នាំ១៩៥០នោះ?

**ឆ៖** បញ្ហានេះ សូមជម្រាបលោកប្រធាន វាវែងបន្តិច ចន្លោះពីឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៦០ វាមានរយៈពេល១០ឆ្នាំ។ ក្នុងរយៈពេលដប់ឆ្នាំនេះ ខ្ញុំសូមជម្រាបថា ត្រូវបក្សមិនទាន់មានមាគ៌ានយោបាយជាយុទ្ធសាស្ត្រ ជាយុទ្ធវិធីអ្វីនៅឡើយទេ។ ដូច្នោះ ពេលនោះនែ៎ក្នុងរវាងឆ្នាំ១៩៥១-៥៧ លោកតា ទូ សាមុត អញ្ជើញទៅប្រតិបត្តិការនៅភ្នំពេញ។ ដូច្នោះបានហៅខ្ញុំ និង សាឡុត ស ទៅពិភាក្សាថា បក្សយើងនៅមិនទាន់មានមាគ៌ានយោបាយ ជាយុទ្ធសាស្ត្រ ជាយុទ្ធវិធីអ្វីឯករាជ្យខ្លួនឯងនៅឡើយទេ។ យើងនៅអាស្រ័យពឹងពាក់លើវៀតណាមទាំងអស់ អ្វីៗទាំងអស់ត្រូវតែមានសារាចរពីហាណូយ ទៅបានយើងអនុវត្តបាន។ ដូច្នោះ ខ្ញុំ ទូ សាមុត សូមស្នើមិត្តទាំងពីរនេះត្រៀម ក្នុងចន្លោះឆ្នាំហ្នឹងអ្ហែ៎ រៀបចំមាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធីជាបណ្តើរៗទៅ ឲ្យហើយទៅ ដើម្បីយើងរំដោះឲ្យផុតពីការដឹកនាំបញ្ជារបស់វៀតណាម។

[០៩:៤៧:២៨]

ដោយបានទទួលនូវសេចក្តីណែនាំពីលោកតា ទូ សាមុត ដែលគាត់ជាបក្ខជនចាស់ទុំ មានពិសោធន៍ ខ្ញុំហើយនិង សាឡុត ស រវាងឆ្នាំ១៩៥០ តាំងពី៥៥, ៥៦, ៥៧, ៥៨, ៥៩ បីបួនឆ្នាំនេះ ក៏បានទទួលភារកិច្ចត្រៀមរៀបចំមាគ៌ាយុទ្ធសាស្ត្រ និងមាគ៌ាយុទ្ធវិធីរបស់បក្ស។ ឯលោកតា គាត់ចាំអនុម័តចាំជួយយោបល់នៅសម្ងាត់។ ឯការរៀបចំមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីនេះ ចែកគ្នាជាពីរផ្នែក។ មួយ ប៉ុល ពត ទទួលដើម្បីក្តាប់សភាពការណ៍នៅតាមទីក្រុង ពីព្រោះគាត់ជាអ្នកគ្រូបង្រៀន ស្គាល់សភាព-ការណ៍ ហើយទាក់ទងជាមួយអ្នករាជការ អ្នកពួករណៈ-- បានធំទូលាយ។ ឯខ្ញុំទទួលនាទីទាក់ទងជាមួយកម្មាភិបាលចាស់ៗពីសម័យក្រោយកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំមួយពាន់ប្រាំបួនរយ-- នែ៎ ប៉ុន្មាននែ៎ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ ខ្ញុំទទួលទាក់ទងបានពីរភាគ។ មួយ ទទួលទាក់ទងបានខាងភូមិភាគពាយព្យ។ ពីរ ទាក់ទងភូមិភាគនិរតី ហើយបីខាងបាត់ដំបង។

ឯ ប៉ុល ពត គាត់ទាក់ទងកម្មាភិបាលខាងបូព៌ា គឺ សោ ភឹម នេះឯង។ ដល់ទាក់ទងបានហើយស្នើសួរអំពីសភាពការណ៍នៅជនបទ តើបច្ចុប្បន្ននេះមានការប្រែប្រួលយ៉ាងម៉េច? សង្គមនៅជនបទយ៉ាងម៉េច? ឯ ប៉ុល ពត គាត់ក្ដាប់សង្គមនៅទីក្រុង។ ពិនិត្យទៅឃើញថា នៅជនបទភាគច្រើន ៨៥ភាគរយ ជាកសិករក្រីក្រ។ យ៉ាងម៉េចដែលហៅថា កសិករក្រីក្រ? វាមានកសិករបែងជាអីចេះ។ ម្ចាស់ដីមិនមែនកសិករទេ ហៅថា "ម្ចាស់ដី"។ ម្ចាស់ដីនេះ គឺអ្នកដែលមិនធ្វើការពលកម្ម ជួលតែគូលី ធ្វើស្រែនេះមួយស្រទាប់។ មួយទៀត កសិករមាន កសិករមាននេះ គេធ្វើការខ្លះដែរ ក៏ប៉ុន្តែ ធ្វើការបន្តិចបន្តួចទេក្រៅពីនេះជួលគូលីធ្វើស្រែ។ ស្រទាប់ទីបី កសិករកណ្ដាលលើ។ កណ្ដាលលើនេះ គេធ្វើ ពលកម្មខ្លួនគេច្រើន ឯក្រៅពីនេះជួលម្នាក់ពីរនាក់ ដើម្បីជួយធ្វើស្រែ។

[០៩:៥២:២៤]

ក្រៅពីកសិករកណ្ដាលលើហើយ មានកសិករកណ្ដាលៗ កសិករកណ្ដាលក្រោម ហើយនិងកសិករក្រ ហើយនិងកសិករដែលអត់ដី។ វាមានច្រើនស្រទាប់យ៉ាងនេះ ដែលវាស្មុគស្មាញនោះ។ ដូច្នោះ ឯ ប៉ុល ពត គាត់ក្ដាប់សភាពការណ៍វណ្ណៈ សភាពការណ៍អ្នករាជការតូចតាច អ្នករាជការដែលមានឋានៈជាគ្រូបង្រៀន ជាអីៗនេះនៅទីក្រុងភ្នំពេញគាត់ក្ដាប់បាន ពីព្រោះគាត់មានខ្សែសង្វាក់របស់គាត់។

ពេលនោះៗបានមករាយការណ៍ជូនលោកតា អំពីសភាពការណ៍ជនបទ ដែលមានសភាពការណ៍យ៉ាងម៉េច? សភាពការណ៍ជនបទមានការជិះជាន់ធ្ងន់ណាស់។ ស្រូវខ្ចី១០០ថាំង យកការ៣០ថាំង ជួនកាល៤០ ថាំង កន្លែងខ្លះ៥០ថាំងក្នុង១០០ថាំង។

[០៩:៥៣:៤៣]

ដូច្នោះកសិករងើបមុខមិនរួចទេ។ នេះយើងត្រូវឃើញកម្លាំង។ ឯក្រៅពីនេះនៅមានមេឃុំ ជំទប់ប៉ូលិស ទាហាន អ្នករដ្ឋការតូចតាច អ្នករាជការខ្លះដែលនៅតាមជនបទជិះជាន់ប្រជាជនកសិករថែមទៀត។ ដូចជា កេណ្ឌ កៀរ យកទៅធ្វើពលកម្មដោយអត់ឲ្យលុយឲ្យកាក់ ឲ្យទៅធ្វើការឲ្យទទេ។ ដូច្នោះកសិករគេហៅថា "ទុរគតភារូបនីយកម្ម"។ នយោបាយទុរគតភារូបនីយកម្មកសិករ របស់រដ្ឋាភិបាលសម័យហ្នឹង។ ភាគច្រើនណាស់ គឺក្រ។ ឯខាង ប៉ុល ពត គាត់ក្ដាប់សភាពការណ៍ ខាងអ្នករាជការតូចតាច ខាងអីៗក៏ឃើញថាជីវភាពលំបាកដែរ។ ពេលនោះ ប្រទេសកម្ពុជាពិតមែនតែថា មានឯករាជ្យក៏ប៉ុន្តែវាមិនទាន់ជាឯករាជ្យពេញលេញទេ។ តាមទស្សនៈរបស់បក្សពិនិត្យ តើពេលនោះសង្គម-- មុននឹងធ្វើមាគ៌ា គោលការណ៍ធ្វើមាគ៌ាត្រូវធ្វើយ៉ាងម៉េច? ខ្ញុំសូមជម្រាប គឺវិភាគអំពីធាតុពិតនៃសង្គមកម្ពុជា

តើពេលនោះសង្គមកម្ពុជាជាសង្គមអី? រួមគ្នាវិភាគទៅឃើញថា ពេលនោះសង្គមកម្ពុជា ជាសង្គមពាក់កណ្តាលអាណានិគម ហើយពាក់កណ្តាលសក្តិភូមិ។ ពាក្យថា "សក្តិភូមិ" នេះមិនមែនស្តេចទេ។ សក្តិភូមិនេះគឺអ្នករកស៊ីបុលបណ្តាក់ចងការ ខ្ចី ឲ្យខ្ចីស្រូវអីយកការថ្លៃដូចខ្ញុំបានរៀបរាប់មកហើយ។ ដូច្នោះជាសង្គមពាក់កណ្តាលអាណានិគមពីព្រោះវានៅជាប់កម្អែលអាណានិគម មេឃុំអីនេះនៅមានអំណាចជិះជាន់សង្កត់សង្កិនប្រជាជន។ ដូច្នោះវិភាគឃើញថា ច្បាស់ថា ឯនៅទីក្រុង ក៏មាននាយទុនដែរ ប៉ុន្តែមិនទាន់ជានាយទុនជាតិអីធំដុំទេ ដោយច្រើនជនបរទេសចិនធ្វើជានាយទុន ហើយមានអ្នកខ្លះគេហៅថាជា "នាយទុនកុំប្រាឌ័រ"។ "នាយទុនកុំប្រាឌ័រ"នេះ គឺនាយទុនតំណាងឲ្យផលប្រយោជន៍បរទេស។

[០៩:៥៨:០០]

ដូចជា អ្នកទទួល គេហៅថាពួក*អ៊ិចស្ព័ត អ៊ីមផត*នេះ អង្កាល់ណោះមានចលនាជំនួយពីអាមេរិក *ដូឌីវីស* ឯពួកនាយទុនកុំប្រាឌ័រនេះមិនមែន *ដូឌីវីស* នេះទៅទិញអីវ៉ាន់យកមកលក់ទេ។ ប៉ុន្តែ ដូនេះយកលុយទៅផ្ញើបង់ហុងកុង ដើម្បីយកចំណេញ។ ដូច្នោះបានជាសរុបគ្នាទៅយល់ឃើញថា សង្គមកម្ពុជាយើងជាសង្គមពាក់កណ្តាលអាណានិគម ពីព្រោះវានៅមានកម្អែលអាណានិគមនៅឡើយ។ វាមិនទាន់ឯករាជ្យសុទ្ធសាធទេ ហើយជាសង្គមពាក់កណ្តាលសក្តិភូមិ ពីព្រោះវាមានរបបនាយទុនហើយ។ វាមិនមែនសក្តិភូមិ វាមិនមែនសក្តិភូមិទាំងដុលទេ វាមានរបបនាយទុនហ្នឹង។ ក្តាប់សភាពការណ៍នេះ ឃើញដូច្នោះ បើកម្ពុជាយើងមានធាតុពិតជាសង្គមពាក់កណ្តាលសក្តិភូមិ ពាក់កណ្តាលអាណានិគមអ៊ីចឹង តើយើងត្រូវធ្វើបដិវត្តន៍អី?

ចោទបញ្ហា ពិភាក្សាគ្នាយូរ។ ធ្វើបដិវត្តន៍សង្គមនិយម ឬក៏ធ្វើបដិវត្តន៍អី?

ពិភាក្សាគ្នាច្រើនថ្ងៃដែរ ពិភាក្សាគ្នាចុះឡើងទៅ បានសម្រេចថា បើធាតុពិតនៃសង្គមកម្ពុជាជាសង្គមពាក់កណ្តាលអាណានិគម ពាក់កណ្តាលសក្តិភូមិ យើងត្រូវធ្វើបដិវត្តន៍ជាតិប្រជាធិបតេយ្យ។ យ៉ាងម៉េចហៅថាបដិវត្តន៍ជាតិ? បដិវត្តន៍ជាតិ គឺកម្ចាត់នូវឥទ្ធិពលរបស់បរទេស អាណានិគមបរទេស។ ចុះប្រជាធិបតេយ្យយ៉ាងម៉េច? ប្រជាធិបតេយ្យ គឺកម្ចាត់នូវឥទ្ធិពលធាតុពិត មិនមែនសម្លាប់ទេ ពាក្យថា "កម្ចាត់"នេះ គឺឥទ្ធិពលរបស់ពួកអ្នកឲ្យបុល ឲ្យបណ្តាក់អីៗអស់នេះ ដើម្បីរំដោះកសិករ ឲ្យកសិករក្រនេះ មានបានធូរធារបន្តិចខាងឈ្នួលស្រែ ការប្រាក់ ថ្លៃគោថ្លៃក្របីអីអស់នេះ។ ជំពាក់អីគេនេះ ឈ្នួល--បំពាក់បំណុលគេនេះឲ្យធូរបន្តិចមក។

[១០:០១:៤១]

ឧបមាថាខ្លីគេ១០០ ពីដើមការ៥០ ឲ្យនៅសល់ត្រឹម២០អីៗបានហើយ។ បញ្ហានេះ មានការអធិប្បាយពន្យល់ច្រើនណាស់ មិនមែនធ្វើបានងាយៗទេ។

ដូច្នោះ ធាតុពិតរបស់បដិវត្តន៍កម្ពុជាពេលនោះ ហៅថាបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ។ ខ្ញុំសូមបញ្ជាក់ម្ដងទៀត ប្រជាជាតិ គឺកម្ចាត់ឥទ្ធិពលរបស់អាណានិគម ពាក់កណ្ដាលអាណានិគម។ ប្រធិបតេយ្យ គឺកម្ចាត់ធាតុឥទ្ធិពលរបស់ពួកសក្តិភូមិម្ចាស់ដី។ នេះធាតុពិតរបស់វា។ ដូច្នោះក្ដាប់ធាតុពិតរបស់បដិវត្តន៍កម្ពុជាឲ្យជាប់ ដើម្បីកុំផ្អៀងទៅរកបដិវត្តន៍សង្គមនិយម កុម្មុយនីស្តនិយមអីតាមចលនាពេលនោះ។ អានេះ ខទីពីរ។

[១០:០២:៥៧]

ខទីបី បើបដិវត្តន៍ បើធាតុពិតនៃបដិវត្តន៍កម្ពុជា ជាបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ តើអ្នកណាជាសត្រូវ? រកសត្រូវឲ្យឃើញ។ សត្រូវ គឺបរទេស កម្ពែលដែលនៅសល់ កម្ពែលបរទេសដែលនៅប្រើអំណាចអាជ្ញាមកលើប្រជាជនខ្មែរ នេះគឺជាសត្រូវហើយ។ ត្រូវដុះលាង ឯពាក់កណ្ដាលសក្តិភូមិ គឺទាមទារឲ្យកសិករគស្ង៉ូបន្ថយឈ្នួលស្រែ ការប្រាក់ បុលបណ្ដាក់។ល។...

ដូច្នោះ មិនមែនយកមនុស្សជាសត្រូវទេ ខ្ញុំសូមជម្រាបអ៊ីចេះ គឺយកការប្រព្រឹត្តរបស់គេជាសត្រូវ។ ចុះបើសត្រូវយ៉ាងហ្នឹង យើងត្រូវយកកម្លាំងខទីបី អ៎ខទីបួន។

[១០:០៤:៣៦]

អ្នកណាជាកម្លាំងបដិវត្តន៍? ពេលនោះ គឺកសិករក្រ កសិករកណ្ដាលថ្នាក់ក្រោម ក្រោមសម្ព័ន្ធភាពរបស់កម្មករ កសិករ ជាកម្លាំងបដិវត្តន៍របស់បដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់។ ឯក្រៅពីនេះ គឺអ្នកដែលមានស្មារតីជាតិ ស្មារតី ប្រជាធិបតេយ្យក៏យើងត្រូវប្រមូលដែរ យើងមិនបដិសេធអ្នកណាទេ ដូចជាកសិករកណ្ដាល ទោះបីជា ឬក៏កសិករមានទោះបីជាមានការជិះជាន់ខាងបុលបណ្ដាក់ខ្លះ ក៏យើងមិនទុកជាសត្រូវដែរ ត្រូវប្រមូលកម្លាំងអស់នេះមកចូលក្នុងបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។

ខទីបួន តើធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនេះ នៅឯណា? ចាប់ផ្ដើមធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យធ្វើពីចុងកាត់មាត់ញកទៅ ឲ្យវារាលទៅទីប្រជុំជន ទៅតាមទីរួមស្រុក គឺប្រៀបដូចជាតំណក់ប្រេង។ កាលណោះ ពួកខ្ញុំប្រើពាក្យថា “ធ្វើបដិវត្តន៍របៀបតំណក់ប្រេង”។

[១០:០៦:២៩]

អាហ្នឹង "ខ" បួន-- "ខ" ប្រាំ តើរបៀបតស៊ូយ៉ាងម៉េច? តស៊ូគឺយកស្របច្បាប់ ពាក់កណ្តាលស្របច្បាប់ មិនស្របច្បាប់ តស៊ូទាំងនយោបាយ តស៊ូទាំងសេដ្ឋកិច្ច តស៊ូទាំងវប្បធម៌ ហើយក៏មិនចោលបើចាំបាច់ត្រូវរួមផ្សំ បើចាំបាច់ណាស់ ត្រូវរួមផ្សំការតស៊ូអាវុធ និងការតស៊ូនយោបាយរួមផ្សំគ្នា អានេះក្នុងករណីពិសេសទេ។ ចោទបញ្ហាទៀត តើអ្នកណាដឹកនាំ? កាលណោះ គឺមានតែបក្សកុម្មុយនីស្តកម្ពុជាទេដឹកនាំ ក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ដឹកនាំចលនាបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ។

ខទីប្រាំមួយ ចុះលើកពាក្យស្លោកយ៉ាងម៉េច? ដើម្បីសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ តស៊ូយូរអង្វែង លំបាកវេទនា ខ្លួនទីពឹងខ្លួន ខ្លួនសម្រេចវាសនាជាតិខ្លួនដោយខ្លួនឯង។ បើចាំបាច់ក៏យើងមានការទាក់ទងជាមួយមិត្ត ប្រទេសជាមិត្តដែលស្នេហាសន្តិភាព ស្នេហាយុត្តិធម៌ផងដែរ។ ហើយការតស៊ូនេះ ដើម្បីការពារជាតិបូរណភាពដែនដីនៃប្រទេសយើង។ អានេះ ពាក្យស្លោកក្នុងមាគ៌ាយុទ្ធសាស្ត្រមានពាក្យស្លោកប្រាំមួយប្រាំពីរ "ខ" ហ្នឹង តាមខ្ញុំចាំ។

[១០:០៩:១០]

ចុះយុទ្ធវិធីយ៉ាងម៉េច? យុទ្ធវិធីមានសាស្ត្រហើយ ក៏ប៉ុន្តែបើអត់យុទ្ធវិធី ន៎ ក៏ដំណើរការតស៊ូទៅមិនបានដែរ ពីព្រោះយុទ្ធសាស្ត្រវាជាទិសដៅយូរអង្វែងមិនដឹងជាពេលណាសម្រេចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យនោះទេ។ ដូច្នោះ ន័យថា មាគ៌ាយុទ្ធវិធី គឺមាគ៌ារណសិរ្សរួបរួមជាតិនោះឯង គឺមាគ៌ាដែលត្រូវអនុវត្តក្នុងរយៈកាលនៃសភាពការណ៍ជាក់ស្តែងនីមួយៗ ឲ្យសមស្រប មិនយក។ ប៉ុន្តែកុំ ចោលមាគ៌ាយុទ្ធសាស្ត្រ ត្រូវផ្អែកលើមាគ៌ាយុទ្ធសាស្ត្រ ដើម្បីលើកមាគ៌ាយុទ្ធវិធី។ បើមិនផ្អែកលើមាគ៌ាយុទ្ធសាស្ត្រទេ ខុសហើយ ជួនកាលទៅឆ្វេង ជួនកាលទៅស្តាំ។ តើមាគ៌ាយុទ្ធវិធី ឬហៅថាមាគ៌ារណសិរ្សយ៉ាងម៉េច? គឺប្រមូលកម្លាំងគ្រប់ជនជាតិទាំងអស់ ដែលមានស្មារតីជាតិ ស្មារតីស្នេហាប្រជាជន មិនរើសអើងពីអតីតកាល មិនថាជនជាតិភាគតិច មិនថាជនជាតិភាគច្រើន ចូលមករួបរួមគ្នាជាកម្លាំងមហាសាមគ្គីជាតិ ដើម្បីតស៊ូកម្ចាត់របបពាក់កណ្តាលអាណានិគម ពាក់កណ្តាលសក្តិភូមិ។

[១០:១១:៣៤]

នេះ ឯមាគ៌ាយុទ្ធវិធីនេះ វាប្រែប្រួលទៅតាមសភាពការណ៍នីមួយៗ វាមិននៅនឹងថ្កល់ទេ ក៏ប៉ុន្តែកុំឲ្យវង្វេងពីមាគ៌ាយុទ្ធសាស្ត្រ។ មាគ៌ាយុទ្ធសាស្ត្រគឺស្ពឹក្តាប់ឲ្យជាប់ បដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យ។ ឯមាគ៌ាយុទ្ធវិធី ក៏បដិវត្តន៍មាគ៌ាបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យដែរ ក៏ប៉ុន្តែឲ្យសមស្របទៅតាមសភាពការណ៍នៃដំណាក់កាលនីមួយៗ។

ដល់ដូច្នោះហើយ បានជាតាំងពីមានមាគ៌ាយុទ្ធសាស្រ្ត-- (ខ្ញុំហត់ណាស់) តាំងពីមានមាគ៌ាយុទ្ធសាស្រ្ត មានមាគ៌ាយុទ្ធវិធីមក បដិវត្តន៍កម្ពុជាចេះតែចម្រើនជាលំដាប់ៗឡើងមករហូត។ មុនៗមានមាគ៌ាអត់មានទេ ចេះតែមានគិតតែម្យ៉ាង វាយបាវាំងរំដោះប្រជាជាតិ ក៏ប៉ុន្តែធ្វើអីទៀត បើកសិករក្រយ៉ាងនេះ។ ប៉ុន្តែដល់មានមាគ៌ាយុទ្ធសាស្រ្ត មានមាគ៌ាយុទ្ធវិធីហើយបានរៀនសូត្រ។ មាគ៌ាយុទ្ធសាស្រ្ត យុទ្ធវិធីនេះមិនមែនធ្វើតែក្នុងគណៈអចិន្ត្រៃយ៍ ឬគណៈមជ្ឈិមប៉ុណ្ណោះទេ។ តាមខ្ញុំចាំ គឺឲ្យពិភាក្សាតាំងពីសាខាបក្សនៅតាមភូមិឃុំឡើងមក តើមានមតិយ៉ាងម៉េច? ពីព្រោះយើងអនុវត្តនូវប្រជាធិបតេយ្យ នូវសមូហភាពដឹកនាំ។ ដូច្នោះយកមតិពីខាងក្រោម ពីឃុំ ពីស្រុក ពីតំបន់ ពីភាគ ហើយមកប្រមូលផ្តុំចងក្រងជាមាគ៌ាយុទ្ធសាស្រ្ត យុទ្ធវិធីហើយ បញ្ជូនឲ្យទៅរៀនវិញ។ តើសុខចិត្តទេខាងក្រោម? ដូច្នោះនេះហៅថា ប្រជាធិបតេយ្យប្រមូលផ្តុំ មិនមែនប្រជាធិបតេយ្យសេរីពហុបក្សទេ។ ពិតមែនមានបក្សតែមួយ ប៉ុន្តែអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំដោយយកមតិពីក្រោមឡើងលើ យកមតិភាគច្រើនយល់យ៉ាងម៉េច។ ក៏ប៉ុន្តែមិនបដិសេធមតិភាគតិចទេ។ មតិភាគតិចត្រូវរក្សាទុក ខ្លាចលោថ្ងៃក្រោយយើងត្រូវការប្រើ។ តាំងពីនោះមក៦០។

[១០:១៤:៤២]

ដូច្នោះ មហាសន្និបាតបក្សលើកទីពីរ លើកទីពីរ តាមខ្ញុំចាំឆ្នាំ១៩៦០-- លើកទីមួយឆ្នាំ១៩៦០ ឆ្លងមាគ៌ានយោបាយយុទ្ធសាស្រ្ត មាគ៌ាយុទ្ធវិធីនេះ បានឯកភាពគ្នា ហើយបានចាប់ផ្តើមអនុវត្ត ក៏ប៉ុន្តែក្នុងការអនុវត្តនេះ វាមិនបានត្រឹមត្រូវទាំងអស់ទេ អ្នកខ្លះក៏វាយល់ អ្នកខ្លះក៏មិនទាន់យល់។ ខ្ញុំសូមលើកឧទាហរណ៍ដូចជាបញ្ហាថា "ប្រឆាំងរបបសក្តិភូមិ" ត្រូវយល់ថា ត្រូវវាយរបបសក្តិភូមិ ឬវាយស្តេច? ការពិតវាមិនមែនទេ។ មិនមែនវាយរបបសក្តិភូមិ មិនមែនវាយស្តេចទេ គឺវាយរបបខ្ចីបុលបណ្តាក់ ចងការប្រាប់នេះ។ អានេះជារបប។ ដូច្នេះ ទម្រាំតែយល់ ហើយកសិករផងមិនមែន ខ្ញុំមិនមែនមើលងាយកសិករទេ ដោយសមត្ថភាពវប្បធម៌គាត់វានៅទន់ទាបបន្តិច ក៏ប៉ុន្តែគាត់មានការប្រតិបត្តិ ការពិសោធក្នុងការអនុវត្តច្រើន ដូច្នោះ ត្រូវប្រើពេលវេលាយូរណាស់ទម្រាំតែមាគ៌ាយុទ្ធសាស្រ្ត យុទ្ធវិធីនេះបានសម្រេច។

ដូច្នោះ ក្នុងរយៈពេលតាំងពីធ្វើមាគ៌ាយុទ្ធសាស្រ្ត យុទ្ធវិធីមក យើងបានតស៊ូវាយចក្រពត្តិអាមេរិកពួក លន់ នល់ ឈ្នះ ថ្ងៃទីប៉ុន្មាន ១៨ មេសា ១៩៧៥ៗ តាំងពី៧០, ៧១, ៧២, ៧៣, ៧៤, ៧៥ ប្រាំឆ្នាំអ្នកណាក៏គេថាដែរ ជាពិសេស វៀតណាម គេថាមិនដែលមានបដិវត្តន៍ណាវាយយកបានទីក្រុងទេ។

[១០:១៧:៣៧]

នេះ ក៏ប៉ុន្តែក្នុងហ្នឹង វាមានឧបសគ្គដែរ។ វៀតណាម មាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីនេះ យើងមិនបានទៅពិភាក្សាសុំសេចក្ដីយល់ឃើញពីបក្សកុម្មុយនីស្តវៀតណាមទេ អត់ទេ។ យើងម្ចាស់ការខ្លួនឯង ធ្វើដោយខ្លួនឯង សម្រេចវាសនាជាតិដោយខ្លួនឯង ដូច្នេះ វៀតណាមគេប្រឆាំងនឹងមាគ៌ានេះ។ ថាមាគ៌ានេះ វាមិនទាន់ត្រឹមត្រូវទេ វាអ៊ីចេះ វាអ៊ីចុះ វាខ្វះនេះ ខ្វះនោះ។ ក៏ប៉ុន្តែ យើងយកទៅឧទ្ទេសនាមទៅចិន ជូ អេនឡាយ គាត់មានមតិថា "មិត្តធ្វើមាគ៌ាយុទ្ធសាស្ត្រ យុទ្ធវិធីដោយវិភាគធាតុពិតនៃសង្គមត្រឹមត្រូវហើយ" អានេះត្រឹមត្រូវ។ ដូច្នេះ បក្សកុម្មុយនីស្តចិន ឧបត្ថម្ភនូវមាគ៌ានយោបាយ យុទ្ធសាស្ត្រ យុទ្ធវិធីរបស់បក្សកុម្មុយនីស្តកម្ពុជា។ ឯវៀតណាម គេឆ្លើយៗ ស្ងៀមៗ ត្រជាក់ៗ ហៅថា "ធ្វើក៏ធ្វើទៅ មិនធ្វើក៏ហើយទៅ"។ មិនត្រឹមតែប៉ុណ្ណឹង គេរករិធីដើម្បីនឹងបំបែរមាគ៌ានេះជូនទៅឆ្វេង ជូនទៅស្តាំ សម្រេចតែនឹងចិត្តគេ ដើម្បីកុំឲ្យកម្ពុជានេះ រីកចម្រើនក្នុងចលនាតស៊ូដែលមាគ៌ាត្រឹមត្រូវ។ ពីព្រោះ វៀតណាមគេមានផែនការរំដោះព្រៃនគរក្នុងឆ្នាំ១៩៧៦ ឯកម្ពុជាយើងរំដោះឆ្នាំមួយពាន់ប្រាំបួនរយ-- មុនវៀតណាមកន្លះខែ។ នេះខ្ញុំសូមជម្រាបអំពីសំណួរដែលតាមរយៈលោកប្រធានសួរ។ ខ្ញុំចប់តែប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ ជាព័ត៌មានលម្អិត ហើយគួរឲ្យចាប់អារម្មណ៍ណាស់ ប៉ុន្តែខ្ញុំសូមអនុញ្ញាតសួរសំណួរមួយទៀត មុនពេលដែលយើងឈប់សម្រាក។ សំណួរនោះគឺថា តើបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលពិភាក្សាយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់បក្សនោះ ថាតើនៅក្នុងអំឡុងពេលហ្នឹងបក្សកុម្មុយនីស្តកម្ពុជាមានការបង្កើតលក្ខន្តិកៈ ហើយលក្ខន្តិកៈនោះមានបានអនុម័តដោយមហាសន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ១៩៦០ ដែរឬទេ?

**ឆ៖** បញ្ហានេះ ខ្ញុំមិនចាំមិនច្បាស់ទេ ក៏ប៉ុន្តែមានការអនុម័តលក្ខន្តិកៈរបស់បក្សមាន។ លក្ខខណ្ឌរបស់បក្ស លក្ខន្តិកៈរបស់បក្សមានទាំងអស់៣០មាត្រា។ ប៉ុន្តែខ្ញុំមិនចាំទេ ប៉ុន្តែបើធ្វើខុសខ្ញុំដឹង។ ធ្វើខុសធ្វើត្រូវ ខ្ញុំដឹង ប៉ុន្តែឲ្យខ្ញុំចាំមាត្រា ខទីមួយ ទីពីរ ទីបី អីខ្ញុំមិនបានចាំ ពីព្រោះវាយូរហើយ ហើយបានរំសាយបក្សហើយ មិនដែលបានមើលសូត្រអីទេ។ នេះសូមជម្រាប។

**ស៖** ថាតើលក្ខន្តិកៈនោះ វាជាលក្ខន្តិកៈដូចគ្នារបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានប្រើប្រាស់នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាបានទទួលជោគជ័យ និងរំដោះទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

[១០:២២:២២]

**ឆ៖** តាមខ្ញុំចាំ ដូចជាមិនទាន់បានប្រើភ្លាមទេ ប៉ុន្មានខែក្រោយមកទៀតបានអនុម័តប្រើ។

**ប្រធានអង្គជំនុំ៖**

បាទ, ឥឡូវនេះ ដល់ម៉ោងសមល្មមនឹងត្រូវឈប់សម្រាកហើយ។ ហើយអង្គជំនុំជម្រះប្រកាសសម្រាកកន្លះម៉ោងចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្ទះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំលោក នួន ជា ទៅកាន់កៅអីដែលរៀបចំទុកសម្រាប់គាត់នៅពីក្រោយមេធាវីរបស់គាត់ចុះ ហើយនិងឲ្យនាំគាត់មកវិញមុនពេលអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

សូមអញ្ជើញសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:២៤ នាទី ដល់ម៉ោង ១១:០៦ នាទី)*

[១១:០៦:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធី។

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំមិនមានកម្លាំងបន្តទៅទៀតទេ ស្នើសុំត្រឡប់ទៅកន្លែងឃុំឃាំងវិញ។ ចាំថ្ងៃស្អែក ព្រោះខ្ញុំអស់កម្លាំងហើយ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:១០:៥៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

នៅមុនពេលសម្រាកព្រឹកនេះវេជ្ជបណ្ឌិតរបស់លោក នួន ជា បានមានប្រសាសន៍ថា គាត់បាន

ពិនិត្យមើលសុខភាពរបស់លោកហើយ ហើយគាត់ជម្រាបថា លោកអាចមានលទ្ធភាពចូលរួមបន្តក្នុងសវនាការនេះ។ ហើយអង្គជំនុំជម្រះយល់ឃើញថា លោកមានការនឿយហត់ ប៉ុន្តែយើងខ្ញុំសូមស្នើសួរលោកតែកន្លះម៉ោងទៀតទេ ហើយបន្ទាប់ពីនោះលោកអាចនឹងសម្រាករហូតដល់ពេលពិសាបាយថ្ងៃត្រង់។ លោកយល់ព្រមឱ្យខ្ញុំសួរលោករយៈពេលកន្លះម៉ោងទៀតទេ?

**លោក ម៉ៃខល ផេសមិន៖**

លោកស្រី-- គឺថា កូនក្តីខ្ញុំមានសិទ្ធិត្រូវការពិគ្រោះយោបល់ជាមួយក្រុមមេធាវីសិន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំសូមសួរទៅលោក នួន ជា ទេ។ គាត់ឆ្លើយសិន សឹមម៉េចឱ្យគាត់ពិគ្រោះយោបល់ជាមួយលោកក្រោយ។

លោក នួន ជា លោកមានអារម្មណ៍ថា អាចនឹងបន្តឱ្យខ្ញុំសួរលោកន្លះម៉ោងទៀតបានទេ?

[១១:១២:២៤]

**លោក នួន ជា៖**

ខ្ញុំមិនអាចបន្តកន្លះម៉ោងទៀតបានទេ ព្រោះភេទ *(ឮមិនច្បាស់)* ឈាមកាន់តែឡើងហើយ។ ខ្ញុំពិសោធន៍មកអីចឹងហ្នឹង។ ហើយខ្ញុំគ្មានកម្លាំងនឹងឆ្លើយផង ហើយបើឆ្លើយក៏មិនត្រឹមត្រូវដែរ។ ដូច្នោះវាមិនត្រូវនឹងការពិតដែលតុលាការត្រូវការ។ ដូចនោះខ្ញុំសូមស្នើស្អែកបន្តទៀត។

សូមមេត្តាករុណាអនុញ្ញាត សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដោយមូលហេតុនៃការ-- សុខភាពរបស់លោក នួន ជា ដែលសុំយ៉ាងទទូចថា ខ្លួនមិនអាចឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះតទៅទៀតបាន ដោយបញ្ហាសម្ពាធឈាមរបស់គាត់មានការប្រែប្រួល ដោយគាត់សុំត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ។ អង្គជំនុំជម្រះយល់ឃើញថា ឥឡូវនេះស្ថានភាពនៃបញ្ហាសុខភាពរបស់គាត់អាចឱ្យតុលាការពិចារណា អនុញ្ញាតឱ្យគាត់ឈប់សម្រាកបាននៅព្រឹកនេះត្រឹមនេះ។ ដោយឱ្យគាត់ទៅសម្រាកនៅបន្ទប់ខាងក្រោមនៃបន្ទប់សវនាការនេះ ដោយបដិសេធនូវការស្នើសុំត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ។

អនុរក្សមន្ទីរឃុំឃាំងនាំ នួន ជា ត្រឡប់ទៅកាន់បន្ទប់ខាងក្រោមនៃបន្ទប់ ដែលបានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់ ហើយបង្គាប់ឱ្យផ្នែកខាងសោតទស្សន៍រៀបចំតនូវប្រព័ន្ធសោត

ទស្សន៍ និងរូបភាព ដើម្បីឲ្យគាត់តាមដាននូវដំណើរការសវនាការពីចម្ងាយ។ នាំគាត់ទៅចុះ ហើយឲ្យនាំគាត់ត្រឡប់មកវិញនៅពេលរសៀល។

**លោក នួន ជា៖**

ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

បើកៗ!!

**លោក នួន ជា៖**

ទៅកន្លែងឃុំឃាំងវិញ សម្រាក ស្អែកខ្ញុំនឹងខំត្រឡប់មកវិញ ដើម្បីឲ្យសុខភាពខ្ញុំបានស្រួលបួលមែនទែន ដើម្បីបម្រើនូវតុលាការនេះបានផល។ ដូច្នោះខ្ញុំសូមទទូចហើយទទូចទៀត ត្រឡប់ទៅកន្លែងមន្ទីរខ្ញុំ កន្លែងឃុំឃាំងវិញ ពីព្រោះកន្លែងនោះវាស្រួលរបស់ខ្ញុំណាស់ ដើម្បីទៅសម្រាកយកកម្លាំងឲ្យបាន មានកម្លាំង ដើម្បីត្រៀមស្អែកទៀត ពីព្រោះនៅកន្លែងនេះក៏មិនស្រួលដែរ។

[១១:១៦:០៣]

**ប្រធានអង្គជំនុំ៖**

បាទ, នេះកិច្ចដំណើរការនីតិវិធី។ ទីមួយ អង្គជំនុំជម្រះបានសម្រេចរួចហើយ។ ទីពីរ កិច្ចដំណើរការនីតិវិធី ដែលជនជាប់ចោទត្រូវចូលរួម គឺមានមធ្យោបាយពីរ។ ទីមួយ ចូលរួមដោយផ្ទាល់ ទីពីរ ក្នុងករណីមិនអាចចូលរួមដោយផ្ទាល់បានទេ ក្នុងករណីលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់។ ជម្រើសទីពីរ គឺតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមនៅពីបន្ទប់ខាងក្រោមសាលសវនាការនេះ ដែលបានរៀបចំរួចជាស្រេចនូវប្រព័ន្ធឧបករណ៍សោតទស្សន៍។ ដោយអង្គជំនុំជម្រះមិនទុកឲ្យពេលវេលាកន្លងទៅឥតប្រយោជន៍នោះទេ ត្រូវរៀបចំនូវកិច្ចដំណើរការដេញដោលតាមមធ្យោបាយ និងលទ្ធភាពដែលអាចធ្វើទៅបាន។ ពីព្រោះក្រោយពីលោកមិនបន្ត សុំមិនបន្តការឆ្លើយតបនេះ ពេលវេលានេះអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សី ឬក៏នឹងរៀបចំនូវការសួរឆ្លាស់គ្នាចំពោះជនជាប់ចោទដទៃទៀត ដើម្បីសន្សំសំចៃពេលវេលា ជំរុញឲ្យកិច្ចដំណើរការនេះប្រព្រឹត្តទៅបានដោយយុត្តិធម៌ និងចាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។

[១១:១៧:៣២]

អនុរក្សមន្ទីរឃុំឃាំងនាំគាត់យកទៅចុះ!

ក្រឡាបញ្ជី តើមានវត្តមានដើមបណ្ដឹងរដ្ឋប្បវេណី TCCP185 ដែរឬទេឥឡូវនេះ?

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! ដើមបណ្ដឹងរដ្ឋប្បវេណីដែលអង្គជំនុំជម្រះបានកោះហៅ គាត់មានវត្តមានរួចហើយ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ដើម្បីចូលមកកាន់បន្ទប់សវនាការ។ សូមអរគុណ។

[១១:១៨:២៥]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ជម្រាបសួរលោក លោកស្រីចៅក្រម ដូចខ្ញុំជម្រាបពីព្រឹកមិញ លោក នួន ជា នឹងបោះបង់សិទ្ធិរបស់គេក្នុងការចូលរួមផ្ដល់សក្ខីកម្មជាមួយ-- ស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺថាគាត់មិនត្រូវបានអនុញ្ញាតឲ្យទៅក្នុងមន្ទីរឃុំឃាំងទេ គឺឲ្យនៅក្នុងបន្ទប់ខាងក្រោមនេះ។ តើអ៊ីចឹងមែនទេ? ដោយសារក្រុមរបស់យើងខ្ញុំបានបញ្ជាក់ហើយថា គាត់បានបោះបង់សិទ្ធិរបស់គេដោយមិនចូលរួមទាល់តែសោះនៅក្នុងពេលនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចជាឆ្លើយច្បាស់លាស់ហើយ ប្រហែលជាសាធារណជន និងភាគីដទៃទៀតជ្រាបហើយ។ អត់មានសម្រេចអីម្ដងទៀតទេ។

មន្ត្រីតុលាការនាំ-- អញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណី TCCP185 ចូលកាន់សវនាការ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:២០:២០]

មុននឹងស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបដំបូង។ អង្គជំនុំជម្រះសូមរំឭកនិងជម្រាបដល់ភាគីថា កាលពីថ្ងៃចន្ទអង្គជំនុំជម្រះបានជូនដំណឹងទៅភាគីរួចហើយថា អង្គជំនុំជម្រះមានបំណងស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP185 និង TCCP123 បន្ទាប់ពីបានដោះស្រាយបញ្ហាបច្ចេកទេសបញ្ហាពាក់ព័ន្ធមួយចំនួន។ អង្គភាពបកប្រែភាសាទើបបានវាយតម្លៃអំពីសមត្ថភាពផ្នែកភាសារបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនពីររូបខាងលើនេះ។ ដោយហេតុថាភាសាខ្មែរ ពុំមានជាភាសាកំណើតរបស់ពួកគាត់ទេ ថ្វីបើពួកគាត់នឹងនិយាយ និងផ្ដល់សក្ខីកម្មជាភាសាខ្មែរ នៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏ភាគីត្រូវសួរជាសំណួរខ្លីៗ និងងាយយល់តាមដែលអាចធ្វើទៅបាន។

[១១:២១:៣៥]

នៅបន្ទប់សវនាការ អ្នកបកប្រែផ្ទាល់មាត់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង អង្គុយក្បែរដើម្បី-- ដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនេះ ដើម្បីជួយដល់ពួកគាត់។ ទោះជាយ៉ាងណាក្ដី ការប្រាស្រ័យទាក់ទងនៅក្នុងបន្ទប់សវនាការរវាងអ្នកបកប្រែផ្ទាល់មាត់ និងដើមបណ្ដឹងរដ្ឋប្បវេណីពីររូប ខាងលើ នឹងធ្វើជាភាសាខ្មែរ។ កាលពីថ្ងៃចន្ទ នេះដែរ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើមួយ ដោយលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP123 ពុំអាចបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះបានឡើយ ដោយសារសុខភាពមិនអំណោយផល។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមបំភ្លឺថា នៅពេលបុគ្គលណាម្នាក់ត្រូវបានកោះហៅឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខ អង្គជំនុំជម្រះ គឺមានតែអង្គជំនុំជម្រះតែប៉ុណ្ណោះដែលមានសិទ្ធិសម្រេចថា បុគ្គលនោះត្រូវបង្ហាញខ្លួន ឬ មិនត្រូវបង្ហាញខ្លួន។ ភាគីពុំអាចសម្រេចលើបញ្ហានេះ ដោយខ្លួនឯងបានឡើយ។

[១១:២២:៥៤]

អង្គជំនុំជម្រះយល់ថា ការវាយតម្លៃអំពីស្ថានភាពសុខភាពរបស់សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP123 គឺជាការពុំចាំបាច់ឡើយ។ ប៉ុន្តែក្រោយពីទទួលបានការកោះហៅ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវចូលបង្ហាញខ្លួននៅតុលាការ ដើម្បីឆ្លើយតបទៅនឹងការកោះហៅ។ កាលពី ថ្ងៃចន្ទ អង្គជំនុំជម្រះបានទទួលដំណឹងពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញថា ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានរហស្សនាមសម្គាល់ដូចខាងលើ មានបំណងផ្ដល់សក្ខីកម្ម និងជួយដល់អង្គជំនុំជម្រះតាមការ ចាំបាច់។

[១១:២៣:៤៦]

បញ្ហាមួយទៀត នៅពេលបន្ទាប់ នៅពេលណាដែលអង្គជំនុំជម្រះសាលាដំបូង បានទទួលដំណឹង អំពីអង្គភាពសោតទស្សន៍ថា ប្រព័ន្ធសោតទស្សន៍សម្រាប់សាក្សីដំបូងឈ្មោះ ឡុង នរិន្ទ ត្រៀមខ្លួនរួច រាល់នឹងអាចដំណើរការបាន អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគី និងសាធារណជនថា ក្នុងចំណោម សាក្សីទាំងអស់ មានសាក្សីមួយរូប ដែលអង្គជំនុំជម្រះនឹងស្ដាប់ចម្លើយតាមប្រព័ន្ធសោតទស្សន៍ ដែល សាក្សីរូបនេះជាមនុស្សមានវ័យចាស់ជរា មានសុខភាពទ្រុឌទ្រោម សុខភាពរបស់គាត់មានភាពមិននឹង នរពីមួយថ្ងៃទៅមួយថ្ងៃ គាត់រស់នៅតំបន់ដាច់ស្រយាល ហើយអង្គជំនុំជម្រះបានជួបបញ្ហាបច្ចេកទេស ជាច្រើនក្នុងការដាក់ឲ្យដំណើរការប្រព័ន្ធសោតទស្សន៍ ដើម្បីស្ដាប់សក្ខីកម្មរបស់សាក្សីរូបនេះ។ ហេតុ

ដូច្នេះ នៅពេលដែលអង្គជំនុំជម្រះបានទទួលដំណឹងថា ប្រព័ន្ធសោតទស្សន៍អាចដំណើរការបាន ហើយសាក្សីអាចផ្តល់សក្ខីកម្មបាននោះ ពេលនោះអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់សាក្សីរូបនោះភ្លាមៗ ដោយមិនបង្អង់ពេលយូរទេ ទោះបីត្រូវឃ្លាតចាកពីលំដាប់លំដោយសាក្សីដែលត្រូវផ្តល់សក្ខីកម្មដូចដែលបានជូនដំណឹងជូនភាគីនានាកន្លងមកក៏ដោយ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះចាប់ផ្តើមសួរស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**ស៖** ដើមបណ្តឹងរដ្ឋប្បវេណី តើលោកមានឈ្មោះថា ក្លាន វ៉ុត អ៊ីចឹងពិតមែនដែរ ឬទេ?

**លោក ក្លាន វ៉ុត៖**

**ឆ៖** វ៉ុតៗ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥៥-- ៦៥។ អាយុ ដោយប្រាប់ត្រង់ ទ្រឹស្តី អត់ចេះអក្សរអត់ចេះអី តាំងពីជំនាន់កើត ម៉ែបង្កើតអត់ចេះសរសេរខែថ្ងៃទេ គ្រាន់តែវិភាគទ្រឹស្តី។

[១១:២៦:៣៨]

**ស៖** តើលោកជាជនជាតិអ្វីដែរ?

**ឆ៖** ជនជាតិកាចក់។ ជនជាតិកាចក់ ទាំងអស់មួយខេត្តរតនគិរីមានប្រាំភូមិ ភាគតិច។

**ស៖** តើលោកមានទីកន្លែងកំណើតនៅកន្លែងណា? ឈប់កុំអាលឆ្លើយ ចាំមើលភ្លើងក្រហមបាទ, ទីកន្លែងកំណើតរបស់លោកនៅកន្លែងណា?

**ឆ៖** ភូមិអ៊ុន។

**ស៖** ភូមិអ៊ុន ហ្នឹងនៅឯណាទៅ នៅខេត្តរតនគិរី? នៅឯណាបញ្ជាក់ឃុំ ស្រុក ខេត្ត?

**ឆ៖** ភូមិអ៊ុន ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី។

**ស៖** ហើយចុះសព្វថ្ងៃនេះតើលំនៅដ្ឋានរបស់លោក លោកនៅកន្លែងណាដែរ?

**ឆ៖** នៅភូមិកំណើត។

**ស៖** លោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** សព្វថ្ងៃហ្នឹងគេរំដោះថ្មីហ្នឹង នៅប្រជាជនថ្មី។

[១១:២៨:១៦]

**ស៖** ប្រពន្ធរបស់លោកឈ្មោះអ្វី?

**ឆ៖** ខ្ញុំប្រាប់ត្រង់ ប្រពន្ធមុនហ្នឹងស្លាប់ហើយ។ បើអង្កាល់យកប្រពន្ធថ្មី ប្រពន្ធចាស់ ប្រពន្ធងាប់នោះ។

**ស៖** ប្រពន្ធឥឡូវហ្នឹងណា ប្រពន្ធបច្ចុប្បន្នហ្នឹងណា?

**ឆ៖** ប្រពន្ធឈ្មោះ ជនជាតិកាចក់ដែរ។

**អ្នកបកប្រែ៖**

សូមអនុញ្ញាតលោកប្រធានឲ្យការឃ្លាត ឲ្យរង់ចាំឲ្យអ្នកបកប្រែ អនុញ្ញាតអ្នកបកប្រែចប់សិនទើបអាចឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយបាន។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ប្រពន្ធលោកឥឡូវនេះឈ្មោះអ្វី?

**ឆ៖** (ឮមិនច្បាស់) មិម។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ចាស់ហើយអត់មានកូនហើយ យកគ្នាបានប្រាំឆ្នាំនេះហើយ។ ចាស់អត់មានកូនទៅទេ។

**ស៖** ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តើលោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** រកស៊ី--

**ប្រធានអង្គជំនុំ៖**

ឆ្លើយ ចាំមើល-- អ្នកដែលជំនួយការនោះ រៀបរយឲ្យបានល្អមើល ម៉េចក៏មាន--

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំសុំអាចលើកឡើងពីចំណុចនៃការសួរតាមលំដាប់លំដោយសម្រាប់ទៅក្រុមសួរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

**លោក ម៉ៃខល ផេសមិន៖**

(គ្មានការបកប្រែ)

[១១:៣១:០៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបលោករួចហើយ តាមអនុស្សរណៈនៅក្នុងការកំណត់អំពីលំដាប់សួរ បានជម្រាបរួចហើយ ហើយពេលមុនដំបូង មុននឹងដំណើរការក៏អង្គជំនុំជម្រះបានជម្រាបលោករួចហើយដែរ។ អង្គជំនុំជម្រះមិនអនុញ្ញាតទេ។

យ៉ាងម៉េចទៅ?

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានដឹងអំពីអនុស្សរណៈនោះ ប៉ុន្តែខ្ញុំសូមលើកនូវបញ្ហាមួយផ្សេងទេ គឺថាតើសាក្សីរូបនេះ បានស្បថហើយឬនៅ? ពីព្រោះថា គាត់ត្រូវលើកអំពីព្យសនកម្ម និយាយអំពីអង្គហេតុ ឬក៏និយាយអំពីព្យសនកម្ម? បើសិនណាជាដូច្នេះមែន យើងខ្ញុំយល់ឃើញថា សាក្សីរូបនេះគួរណាតែឲ្យស្បថសិន។ ខ្ញុំបានដឹងអំពីដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ខ្ញុំបានដឹង ក៏ប៉ុន្តែត្រូវតែស្បថសិនមុននឹងចូលមកតុលាការ។

[១១:៣២:៥១]

**ប្រធានអង្គជំនុំ៖**

នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌខ្មែរ ឆ្នាំ២០០៧ ដែលកំពុងជាធរមាន ហើយមានតម្លៃអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនតម្រូវឲ្យដើមបណ្ដឹងរដ្ឋប្បវេណីស្បថឡើយ។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ សំណួរថាតើដើមបណ្ដឹងរដ្ឋប្បវេណីនិយាយអំពីព្យសនកម្ម ឬក៏និយាយអំពីអង្គហេតុ បើសិនណាជាដូច្នេះមែន ថាតើចម្លើយរបស់គាត់ហ្នឹង វាត្រូវមានតម្លៃប៉ុនណានោះ? ខ្ញុំមិនដឹងថាតើជំហររបស់អង្គជំនុំជម្រះយ៉ាងណានោះទេ។

[១១:៣៤:១៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហមេធាវីនាំមុខជាតិ!

**លោក ពេជ អង្គ៖**

បាទ, សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម តាមការពិតសំណួររបស់លោកមេធាវីខាងការពារក្តីមិនសមស្របទេ។ អនុស្សរណៈរបស់លោកប្រធានក៏បានលើកច្បាស់លាស់។ មេម៉ូ លេខ១៤១ បានលើកច្បាស់លាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចនិយាយទាំងអង្គហេតុផង ទាំងអង្គច្បាប់ផង។ ដូច្នេះ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីនិយាយអំពីអង្គហេតុ មិនមានវិធានណាដែលតម្រូវឲ្យគាត់ត្រូវបានប្រែក្លាយលក្ខណៈទៅជាសាក្សីនោះទេ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, សូមអរគុណលោកប្រធាន។

បាទ, គឺថាខ្ញុំសូមពន្យល់បន្តិចបន្តួច ពីព្រោះខ្ញុំគិតថា គឺថាបទប្បញ្ញត្តិនេះដែលកើតចេញពីច្បាប់កម្ពុជា ដែលថាចម្លងចេញពីច្បាប់បារាំង ហើយវាមានលក្ខណៈច្បាស់លាស់ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវចាត់ទុកទៅជាភាគីនៅក្នុងការជំនុំជម្រះសេចក្តី។ អ៊ីចឹង នៅក្នុងឋានៈនេះ គឺថាខ្លួនអាចនិយាយដោយមិនចាំបាច់ស្បថនោះទេ ហើយគាត់ក៏អាចធ្វើផ្តល់សក្ខីកម្ម និយាយអំពីព្យសនកម្មដែលថាគាត់បានទទួលរងឬក៏អង្គហេតុដែលគាត់រៀបរាប់ប្រាប់នោះ ដែលមានទំនាក់ទំនងទៅនឹងអង្គហេតុ ពាក់ព័ន្ធទៅនឹងជនជាប់ចោទនោះ ហើយបន្ទាប់មកទៀត គឺថាយើងត្រូវតែកំណត់ពីតម្លៃរបស់សក្ខីកម្មរបស់គាត់។ អ៊ីចឹងយើងនឹងពិភាក្សានៅពេលក្រោយ អ៊ីចឹងមិនមានបញ្ហា ហើយឲ្យមានមន្ទិលនោះទេ។

[១១:៣៦:៣៩]

**លោក គង់ សំអុន៖**

លោកប្រធាន! ខ្ញុំសូមអនុញ្ញាត កត់សម្គាល់ទៅលើអ្នកបកប្រែ។ អម្បាញ់មិញលោកប្រធានមានប្រសាសន៍ថា លោកម្នាក់ដែលអញ្ជើញមកអមជាមួយនេះ អាចថាជាអ្នកបកប្រែដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្រើភាសាខ្មែរ ជាភាសាកំណើតទេ។ ដូច្នេះ យោងតាមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ នេះ មាត្រា១៥៥ អនុញ្ញាតឲ្យក្រុមប្រឹក្សាជំនុំជម្រះរកអ្នកបកប្រែដើម្បីមកជំនួយដូច្នេះបាន ក៏ប៉ុន្តែកាតព្វកិច្ចរបស់អ្នកបកប្រែត្រូវធ្វើដូចមានចែងក្នុងមាត្រា១៥៤។ ដូច្នេះ គាត់ត្រូវធ្វើការស្បថ

ជាមុនសិន ដើម្បីបញ្ជាក់ពីការបកប្រែរបស់គាត់ត្រឹមត្រូវទៅតាមសមត្ថភាពរបស់គាត់។ សូមអរគុណ។

[១១:៣៧:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ,អរគុណនូវការកត់សម្គាល់នេះ។ អង្គជំនុំជម្រះសូមជម្រាបទៅលោកមេធាវីថា ការសម្រួលនៅក្នុងការបញ្ជាក់បំពេញបន្ថែមនូវគ្រាមភាសានេះ មិនមែនជាក្នុងនាមអ្នកបកប្រែដែលមានវិជ្ជាជីវៈ ដោយគាត់និយាយភាសារបស់គាត់ ហើយបកប្រែជាភាសាខ្មែរនោះទេ។ គាត់ប្រើភាសាខ្មែរជាមូលដ្ឋាន ប៉ុន្តែគ្រាន់តែករណីណាដែលការប្រើពាក្យពេចន៍ខ្លះ វាមានកម្រិត គ្រាន់តែជួយបញ្ជាក់បន្ថែមប៉ុណ្ណោះ ដោយយើងមិនមានធនធានជំនាញបកប្រែភាសាជនជាតិមកភាសាខ្មែរទេ។

[១១:៣៨:២៨]

អ៊ីចឹងហើយបានអង្គតុលាការសម្រេចមិនចាត់តាំងទេ ដោយសារការចាត់តាំង ទាល់តែអ្នកជំនាញ។ ក្នុងនេះ គឺមិនមែនជាអ្នកជំនាញទេ គ្រាន់តែជំនួយបំពេញបន្ថែមលើចំណុចខ្លះប៉ុណ្ណោះ ដើម្បីសម្រួលឲ្យការសួរដេញដោលនោះប្រព្រឹត្តទៅបានល្អ មានខ្លឹមសារដែលអាចស្ដាប់យល់ តែប៉ុណ្ណឹងទេ។ នេះគឺអង្គជំនុំជម្រះបានគិតគូរពីលទ្ធភាពនៃមូលហេតុដែលធ្វើដូច្នេះ ដោយសារមូលហេតុនៃគុណវុឌ្ឍិរបស់គាត់មិនមែនជាអ្នកបកប្រែដែលមានភាពជំនាញនោះទេ។

បាទ, ជាកិច្ចបន្តដើម្បីជាការអនុវត្តនូវបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង និងតាមដីកាចាត់តាំងភារកិច្ចឲ្យសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះផ្ដល់វេទិកាសហមេធាវីនាំមុខតាំងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ក្លាន រ៉ុត នេះ។ សូមអញ្ជើញ!

[១១:៣៩:៥១]

**លោក ពេជ អង្គ៖**

បាទ, សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម។ ពេលនេះ មេធាវីនាំមុខសូមអនុញ្ញាតលោកប្រធានផ្ទេរសិទ្ធិនៅក្នុងការសួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ជូនទៅជាដំបូងទៅលោកស្រី ម៉ុច សុវណ្ណារី ហើយបន្ទាប់ពីលោកស្រី ម៉ុច សុវណ្ណារី បានលើកជាសំណួរហើយ ផ្ទេរសិទ្ធិជូនទៅលោកស្រី គ្រីស្ទីន ម៉ាទីណូ។

បាទ, សូមលោកប្រធានអនុញ្ញាត!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំ។ សូមអញ្ជើញលោកមេធាវី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**លោកស្រី ម៉ុច សុវណ្ណារី៖**

អរគុណលោកប្រធាន។ ជាដំបូង នាងខ្ញុំសូមគោរពអង្គជំនុំជម្រះទាំងមូល ហើយសូមជម្រាបសួរដល់លោកអ៊ំ ក្លាន វ៉ុត។ អ៊ីចឹងខ្ញុំនឹងចាប់ផ្តើមសួរសំណួរមួយចំនួនដល់លោកអ៊ំ ហើយបើសិនជាសំណួរដែលខ្ញុំសួរ ខ្ញុំនិយាយញាប់ពេក ឬក៏មិនច្បាប់ សូមអ៊ំប្រាប់ខ្ញុំ ខ្ញុំនឹងសម្រួលសំណួរនោះឡើងវិញ។

[១១:៤០:៥៣]

ជាដំបូងខ្ញុំនឹងសួរអ៊ំទាក់ទងជាមួយនឹងប្រវត្តិដែលអ៊ំចូលរួមជាមួយនឹងចលនាបដិវត្តន៍ខ្មែរនៅពេលនោះ គឺចាប់តាំងពីពេលដែលអ៊ំចូលរួមបដិវត្តន៍រហូតដល់មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាថ្ងៃដែលចលនាបដិវត្តន៍ខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញ។ លោកអ៊ំយល់ទេ?

**លោក ក្លាន វ៉ុត៖**

យល់ៗ។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ចា៎! អ៊ីចឹងខ្ញុំសូមអនុញ្ញាត សូមសួរនូវសំណួរទីមួយ។ ខ្ញុំចង់សួរជម្រាបសួរលោកអ៊ំថា មុនពេលដែលលោកអ៊ំធ្វើបដិវត្តន៍ តើលោកអ៊ំរស់នៅទីកន្លែងណាដែរ? រួចហើយជីវភាពនៃការរស់នៅរបស់លោកអ៊ំនៅពេលនោះមានស្ថានភាពយ៉ាងម៉េចខ្លះ? ស្រួលយ៉ាងម៉េចខ្លះ? ស្មុគស្មាញយ៉ាងម៉េចខ្លះ? សូមលោកអ៊ំបានជម្រាបជូនអង្គសវនាការនៅពេលនេះ?

**ឆ៖** ខ្ញុំសូមឆ្លើយ កំណើតនៅភូមិអ៊ិន ឃុំតាឡាវ ស្រុក២១ ពីដើមស្រុកអណ្តូងមាសនេះ ស្រុកបរកែវ។

**ស៖** អ៊ីចឹង តើលោកអ៊ំ សូមលោកអ៊ំជម្រាបជូនអង្គសវនាការថា មុនពេលដែលលោកអ៊ំធ្វើបដិវត្តន៍ ហើយលោកអ៊ំរស់នៅទីកន្លែងកំណើតរបស់លោកអ៊ំនៅក្នុងភូមិអ៊ិនហ្នឹង ថាតើស្ថានភាពជីវភាពរបស់លោកអ៊ំយ៉ាងម៉េចដែរ តើលោកអ៊ំរស់នៅសុខស្រួលយ៉ាងម៉េច? ហើយលោកអ៊ំមានបញ្ហាស្មុគស្មាញដែលត្រូវឆ្លងកាត់យ៉ាងម៉េច? សូមលោកអ៊ំឆ្លើយនឹងសំណួរនេះ?

[១១:៤២:៣៥]

**ឆ៖** កាលនោះគឺនៅស្លួនតូចៗរបស់ខ្ញុំ មុនធ្វើបដិវត្តន៍ហ្នឹង ស្រួល ធ្វើតែចម្ការ ធ្វើតែស្រែ រកស៊ី អត់អីទេ ស្រួលបួល។ ដល់គេចលនាធ្វើបដិវត្តន៍ហ្នឹង ខ្ញុំពិបាកស្មុគស្មាញណាស់។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកអ៊ំ។ អ៊ីចឹង នាងខ្ញុំសូមចូលទៅក្នុងសំណួរទីពីរ សូមសួរលោកអ៊ំថា តើលោកបានចាប់ផ្ដើមចូលរួមបដិវត្តន៍ដំបូង នៅពេលណាដែរលោកអ៊ំ?

**ឆ៖** អត់ចំណាំទេ ប៉ុន្តែការងារធ្វើហ្នឹងឆ្នាំៗ អត់ចេះសរសេរអក្សរហ្នឹង ឆ្នាំខែឆ្នាំហ្នឹង។ ធ្វើហ្នឹង មុនដំបូងធ្វើបដិវត្តន៍ហ្នឹងចូលជាមួយខ្មែរក្រហម គេចលនាធ្វើ គេបម្រើៗទាក់ទងឯកសារ ទាក់ទងកម្មាភិបាល អាហ្នឹងមុនដំបូង។ ដាំឲ្យគេបាយ ហ្នឹងហើយគេផ្ដើមចលនា។

**ស៖** ចា៎! អរគុណច្រើនលោកអ៊ំ។ ជាបន្តទៀតនេះ ខ្ញុំសូមសួរលោកអ៊ំថា តើពីដំបូងឡើយតើអ្នកណាគេដែលបានណែនាំអ៊ំ ទៅពន្យល់អ៊ំ បញ្ចុះបញ្ចូលអ៊ំឲ្យចូលរួមបដិវត្តន៍ខ្មែរក្រហមហ្នឹងលោកអ៊ំ?

**ឆ៖** អ៊ំ ថង ស៊ី, អ៊ំរង់, តាវី។ ថង ស៊ី ហ្នឹងជនជាតិឡាវ នៅវ៉ឺនសៃ។ អ៊ំវីហ្នឹង គាត់ជនជាតិខ្មែរ ខេត្តកំពត។ ពួកគាត់ហ្នឹងដឹកនាំខ្ញុំធ្វើបដិវត្តន៍។

**ស៖** អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរបន្តទៀត ខ្ញុំចង់ជម្រាបសួរលោកអ៊ំថា នៅពេលដែលគេបានពន្យល់អ៊ំឲ្យចូលបដិវត្តន៍ដំបូង តើនៅពេលហ្នឹងគេពន្យល់ប្រាប់អ៊ំថាម៉េច ដើម្បីឲ្យអ៊ំចូលរួមក្នុងចលនាបដិវត្តន៍ជាមួយគេហ្នឹង។ អ៊ំចាំពាក្យសម្ដីគេដែលគេពន្យល់ហ្នឹងដំបូងបានទេលោកអ៊ំ?

[១១:៤៤:៣៥]

**ឆ៖** ចាំ អត់ភ្លេចទេ។ គេថាមិត្តវិត បើយើងមិនធ្វើបដិវត្តន៍ យើងអត់បានរស់ទេ បើយើងធ្វើបដិវត្តន៍ហ្នឹងដើម្បីរំដោះជាតិខ្លួនឯង មិនឲ្យខ្មាំងជិះជាន់ ខ្មាំងពីណាខ្មាំង? ពួកសក្តិភូមិ កាន់កាប់រដ្ឋអំណាច គាបសង្កត់ ចាប់ធ្វើប៉ូលិស ឆ្ការផ្លូវ ធ្វើព្រលាន កាប់ផ្លូវ ធ្វើស្ពាន ធ្វើផ្ទះឲ្យគេ ធ្វើបន្ទាយ ធ្វើអីគេ គេចាប់យកៗ អត់ចូលអត់អីទេ អាហ្នឹងគឺថាខ្មាំងជិះជាន់ហើយ។ បើយើងមិនពិចារណាធ្វើបដិវត្តន៍អត់មានផ្លូវដើរទេ។ គេជម្រាបឲ្យ។

**ស៖** អរគុណលោកអ៊ំ អ៊ីចឹង នៅពេលដែលគេបញ្ចុះបញ្ចូលអ៊ំឲ្យចូលបដិវត្តន៍ដំបូងហ្នឹង តើអ៊ំយល់ទេពាក្យថា "ធ្វើបដិវត្តន៍" ហ្នឹង ថាតើមានន័យយ៉ាងម៉េចពាក្យបដិវត្តន៍ហ្នឹង លោកអ៊ំយល់ទេនៅពេលហ្នឹង?

**ឆ៖** អត់ៗ ខ្ញុំសួរៗ ថាយ៉ាងម៉េចបានធ្វើបដិវត្តន៍ៗបដិវត្តន៍ដើម្បីធ្វើស្អី? ទីមួយ ក្ដាប់ប្រជាជនធ្វើស្រែ ធ្វើស្រែធ្វើសម្ការ ដើម្បីមានសេដ្ឋកិច្ចហ្នឹង បានយើងធ្វើបដិវត្តន៍ឈ្មោះ។ បើអត់មានសេដ្ឋកិច្ចអត់

ឈ្នះទេ ធ្វើបដិវត្តន៍។

**ស៖** អរគុណច្រើនលោកអ៊ំ បន្តទៅទៀតនេះ ខ្ញុំចង់ជម្រាបសួរលោកអ៊ំទៀតថា ពេលហ្នឹង ហេតុអ្វីបានជាក្រោយពេលដែលគេពន្យល់ហើយ ហេតុអ្វីបានជាលោកអ៊ំសម្រេចចូលរួមធ្វើបដិវត្តន៍? ហើយពេលដែលអ៊ំសម្រេចចិត្តចូលរួមហ្នឹង តើអ៊ំបង្ខំចិត្តត្រូវតែចូលរួម ឬក៏អ៊ំស្ម័គ្រចិត្តចូលរួមនៅក្នុងបដិវត្តន៍ហ្នឹង?

**ឆ៖** ខ្លាចគេ ខ្លាចអំណាចជាតិគេ អត់មានផ្លូវដើរ អាហ្នឹងហើយធ្វើ ខំធ្វើ។ ក្នុងចិត្តអត់ចង់ទេធ្វើ ដោយសារគេបង្ខំ។

**ស៖** អរគុណច្រើនលោកអ៊ំ អ៊ីចឹងខ្ញុំមានសំណួរទៀត។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំថា នៅពេលដែលអ៊ំចូលធ្វើបដិវត្តន៍ជាលើកដំបូង តើអ្នកដែលនាំអ៊ំចូលឲ្យធ្វើបដិវត្តន៍ហ្នឹង គេបានតម្រូវឲ្យអ៊ំធ្វើការងារអ្វីខ្លះដែរ លោកអ៊ំ?

**ឆ៖** ដំបូងជាក់ស្ដែង ទីមួយដើម្បីទាក់ទងសេដ្ឋកិច្ចគេ ទាក់ទងផ្លូវការជូនសំបុត្រស្នាម ជូនកម្មាភិបាល ទីពីរទៀត គិតគូរស្បៀងអាហារ ពេលគេប្រជុំហ្នឹង ផ្អែកទៅលើខ្ញុំផ្នែកសេដ្ឋកិច្ច បម្រើការងារគេប្រជុំ អង្គប្រជុំគេហ្នឹង។ ទីបី គេពឹងផ្អែកលើខ្ញុំ គឺចាត់ចែងខ្ញុំធ្វើផ្ទះ ធ្វើកន្លែងគេនៅពួននៅព្រៃកាលហ្នឹងសម្ងាត់ ខ្លាចខ្មាំង ពីណាខ្មាំង? ខ្លាចទាហាន លន់ នល់ បើ លន់ នល់ ដឹង អ្នកធ្វើកម្មាភិបាលកាត់កចោល។ អាហ្នឹងគេឲ្យខ្ញុំធ្វើកន្លែងរស់នៅអ៊ំៗហ្នឹង តាពក, ឈ្មោះ អ៊ំ អៀង សារី ហ្នឹង។ អាហ្នឹងហើយ សូមអស់។

[១១:៤៧:៣១]

**ប្រធានអង្គជំនុំ៖**

មេធាវីឈប់ បង្អង់បន្តិចឃ្លាតគ្នាបន្តិច ដើម្បីកុំឲ្យការបកប្រែហ្នឹង វាទាន់ ព្រោះអំមិញវាបកប្រែអត់ទាន់។ អញ្ជើញ!

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកអ៊ំទៀតថា អំមិញលោកអ៊ំបានប្រាប់ថា អ្នកដែលដឹកនាំបដិវត្តន៍ហ្នឹង គេឲ្យអ៊ំរត់សំបុត្រ រត់អីហ្នឹង។ អ៊ីចឹង នៅពេលហ្នឹងអ៊ំធ្វើជានីរសារឲ្យពួកគាត់ ឬក៏យ៉ាងម៉េចដែរលោកអ៊ំ?

**ឆ៖** ធ្វើនីរសារៗគេ ទាក់ទងសំបុត្រ ទាក់ទងកម្មាភិបាល។

**ស៖** អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកអ៊ំបន្តទៀតថា ធ្វើនីរសាររត់សំបុត្រឲ្យគេហ្នឹង អ៊ំរត់សំបុត្រពីណាឲ្យទៅអ្នកណា?

**ឆ៖** តាំងពីនៅស្រុកអណ្ដូងមាសដល់ស្រុកបរកែវ ទាក់ទងស្រុកលំផាត់ ផ្លូវការ និងផ្លូវសម្ងាត់របស់អ៊ំៗទៅមក។

**ស៖** អរគុណលោកអ៊ំ។ មុនហ្នឹងលោកអ៊ំបានជម្រាបជូនសវនាការទៀតថា គេឲ្យលោកអ៊ំហ្នឹងជួយធ្វើខាងផ្នែកផ្គត់ផ្គង់សេដ្ឋកិច្ច អ៊ីចឹង លោកអ៊ំអាចជម្រាបជូនអង្គសវនាការបានទេថា តើលោកអ៊ំធ្វើយ៉ាងម៉េចផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចដល់បដិវត្តន៍ហ្នឹងលោកអ៊ំ?

**ឆ៖** វាថា បើយើងអប់រំនយោបាយ បើអត់មានសេដ្ឋកិច្ច វាអត់បាយ តស៊ូបដិវត្តន៍អត់បានទេ។

**ស៖** អ៊ីចឹង គេតម្រូវឲ្យលោកអ៊ំធ្វើអីទៀតជាមួយនឹងប្រជាជនដែលលោកអ៊ំត្រូវទៅទាក់ទងជាមួយគេឲ្យក្រុមធ្វើចលនាបដិវត្តន៍ហ្នឹង?

**ឆ៖** កាលណាហ្នឹងធ្វើប្រធានភូមិ គេចាត់ចែងឲ្យធ្វើប្រធានភូមិ។

**ស៖** សូមលោកអ៊ំបញ្ជាក់ម្ដងទៀតបានទេ ពីណាឲ្យលោកអ៊ំធ្វើប្រធានភូមិ លោកអ៊ំ?

**ឆ៖** ពួកអ៊ំ ថង ស៊ី ជាមួយលោកអ៊ំ វង់។ អ៊ំ វង់, បងវី ជនជាតិខ្មែរ។

**ស៖** ចាស, អរគុណច្រើនលោកអ៊ំ។ ខ្ញុំចង់សួរសំណួរលោកអ៊ំបន្តមកទៀតថា នៅក្នុងតួនាទីជាមេភូមិហ្នឹង តើខាងបដិវត្តន៍ហ្នឹងគេតម្រូវឲ្យអ៊ំធ្វើការងារអីគេខ្លះសម្រាប់គេ ដែលដើរតួនាទីជាមេភូមិហ្នឹងត្រូវធ្វើអីគេខ្លះ?

**ឆ៖** ធ្វើមេភូមិហ្នឹងដើម្បីចាត់តាំងក្រុម។ មួយភូមិមាន៥ក្រុម ៤ក្រុម ដើម្បីបង្កបង្កើនផល។

**ស៖** លោកអ៊ំបានជម្រាបជូនថា តួនាទីរបស់អ៊ំជាមេភូមិនៅពេលហ្នឹង គឺគេតម្រូវឲ្យលោកអ៊ំហ្នឹងធ្វើការអប់រំប្រជាជនដើម្បីឲ្យប្រជាជនខំបង្កបង្កើនផល។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកអ៊ំថា របៀបដែលគេបង្កបង្កើនផលនៅពេលហ្នឹង តើគេធ្វើរបៀបម៉េចដែរលោកអ៊ំ? តើគេបង្កបង្កើនផលជាលក្ខណៈឯកជន ឬក៏មានអ្វីផ្សេងដែលគេតម្រូវថា ត្រូវតែធ្វើរបៀបណាៗដែរលោកអ៊ំ?

**ឆ៖** កាលហ្នឹងគេថាអ៊ីចេះបើថា បើមានផលហើយ ដើម្បីជួយបដិវត្តន៍។

**ស៖** ចាស, អរគុណលោកអ៊ំ។ អ៊ីចឹងតើខាងបដិវត្តន៍ហ្នឹងគេមានតម្រូវឲ្យលោកអ៊ំថា បានផលធ្វើស្រែបានផលហើយ តើត្រូវតម្រូវត្រូវផ្គត់ផ្គង់បដិវត្តន៍ប៉ុនណាៗ តើគេមានត្រូវអ៊ីចឹងទេលោកអ៊ំ?

[១១:៥១:៤៣]

**ឆ៖** គេយកប្រពន្ធមួយប៉ោត ប្ដីមួយប៉ោត មួយគ្រួសារពីរប៉ោត បម្រើឲ្យបដិវត្តន៍។

**ស៖** ចាស, អ៊ីចឹងបានន័យថា ក្នុងគ្រួសារលោកអ៊ំមានពីរនាក់ មានប្ដីមួយប្រពន្ធមួយ អ៊ីចឹងលោកអ៊ំត្រូវផ្គត់ផ្គង់ដល់បដិវត្តន៍ពីរប៉ោត។ ប្រពន្ធមួយប៉ោត លោកអ៊ំមួយប៉ោត។ អ៊ីចឹងមួយប៉ោតហ្នឹងមានប៉ុន្មានគីឡូរដែរលោកអ៊ំ ស្រូវ?

**ឆ៖** ១២គីឡូ។ ប៉ោតបួនជ្រុងគេដាក់អាប្រេងកាតនុ៎ងមានរូបមាន់នុ៎ង ពួកខ្ញុំថ្លឹងមក១២ប៉ោត។

**ស៖** ចាស, អរគុណលោកអ៊ំ។ អ៊ីចឹងខ្ញុំចង់ជម្រាបសួរថា នៅពេលដែលលោកអ៊ំយកពីរប៉ោតហ្នឹងទៅផ្គត់ផ្គង់បដិវត្តន៍ហ្នឹង តើលោកអ៊ំស្ម័គ្រចិត្តឲ្យគេ ឬក៏លោកអ៊ំត្រូវបានគេបង្ខំឲ្យថាត្រូវតែឲ្យដោយខានមិនបានអ៊ីចឹង? ឬក៏អ៊ំស្ម័គ្រចិត្តជាអ្នកប្រគល់ឲ្យដើម្បីផ្គត់ផ្គង់បដិវត្តន៍?

**ឆ៖** ដោយសារខ្លាច។ បើមិនលះបង់អត់បានទេ និងយើងជួយបដិវត្តន៍ ញើសឈាមយើងដើម្បីបក្សទទួល គឺថាអ៊ីចឹង។

**ស៖** ចាស, អរគុណលោកអ៊ំ។ ខ្ញុំនឹងសួរសំណួរបន្តមកទៀត។ ខ្ញុំចង់ជម្រាបសួរលោកអ៊ំថា ក្រៅអំពីលោក ថង ស៊ី ដែលលោកអ៊ំបានប្រាប់ថា ជាអ្នកណែនាំឲ្យលោកអ៊ំចូលធ្វើបដិវត្តន៍ហ្នឹង អ៊ីចឹងខ្ញុំចង់សួរថា តើមានអ្នកដឹកនាំនយោបាយខ្មែរក្រហមធំៗណាផ្សេងទៀត ដែលគេបានមកទាក់ទងឲ្យលោកអ៊ំធ្វើការងារឲ្យគេទេ?

[១១:៥៣:២០]

**ឆ៖** អំមិញមានៗនេះអ៊ំ អៀង សារី ហ្នឹង។

**ស៖** អ៊ីចឹងក្រៅពីលោក អៀង សារី តើមានថ្នាក់ដឹកនាំជាន់ខ្ពស់ណាផ្សេងទៀតទេ ដែលទាក់ទងលោកអ៊ំឲ្យធ្វើការ?

**ឆ៖** គាត់មានតែម្នាក់គាត់។ អត់ឃើញអ្នកណាទេ និយាយស្មោះត្រង់។

**ស៖** អរគុណលោកអ៊ំ។ អ៊ីចឹងខ្ញុំសូមជម្រាបសួរលោកអ៊ំបន្តទៀតថា លោកអ៊ំបានជួបជាមួយនឹងលោក អៀង សារី បានស្គាល់គាត់ប្រហែលជានៅក្នុងពេលណាដែរលោកអ៊ំ?

**ឆ៖** ឆ្នាំគាត់ចេញទៅកោះញែក នៅអណ្ដូងមាស។ អត់ដឹងឆ្នាំណា។ ឆ្នាំរដ្ឋប្រហារ លន់ នល់ហ្នឹងក្រោយ មុនហ្នឹង។ មិនដឹងឆ្នាំអី អត់ចំណាំ។

**ស៖** អរគុណលោកអ៊ំ។ អ៊ីចឹងតើលោកអ៊ំឧស្សាហ៍ឃើញគាត់ញឹកញាប់ទេ? ធ្លាប់ជួបជាមួយនឹងគាត់ញឹកញាប់ទេ?

**ផ៖** គាត់ហៅខ្ញុំប្រជុំមានពីរលើក។ ប៉ុណ្ណឹងទេ។

[១១:៥៤:៣៩]

**ស៖** ចាស, អំមិញលោកអ៊ំថា គាត់ហៅលោកអ៊ំទៅប្រជុំ។ អ៊ីចឹងខ្ញុំចង់សួរលោកអ៊ំបន្តទៀតថា នៅពេលដែលប្រជុំហ្នឹងថាតើគាត់បាននិយាយអ្វីខ្លះនៅក្នុងពេលប្រជុំហ្នឹង ឬក៏បានបង្រៀនអីខ្លះដល់លោកអ៊ំនៅពេលហ្នឹងដែរទេ?

**ផ៖** មាន, គឺថាបង្រៀនលក្ខន្តិកៈរបស់បក្ស។

**ស៖** លោកអ៊ំចាំបានទេថា អត្ថន័យខ្លឹមសារ ដែលគាត់បង្រៀន ដែលគាត់និយាយនៅពេលហ្នឹង ថាតើគាត់និយាយរបៀបម៉េចដែរលោកអ៊ំ? គាត់និយាយអ្វីខ្លះប្រាប់លោកអ៊ំ?

**ផ៖** គាត់បង្រៀនឲ្យថា ឥឡូវហៅបងប្អូន គេហៅហ្នឹងថ្នាក់ឃុំ ថ្នាក់ស្រុក ប្រធានភូមិ គេហៅដើម្បីគេពង្រឹងគោលជំហរឲ្យនឹងនរ ធ្វើបដិវត្តន៍ តស៊ូការលំបាកវេទនា។ បដិវត្តន៍នេះយូរអង្វែងបានហើយ បានចប់ អត់ចេះចប់ទេ។ ពេលណាយើងអត់មានគោលជំហរតស៊ូនុ៎ង អត់កើតទេធ្វើបដិវត្តន៍។ បើមិនធ្វើបដិវត្តន៍ យើងស្លាប់អស់។

**ស៖** ចាស, ដោយសារនៅភូមិភាគព្រៃសានហ្នឹង វានៅជិតខាបងប្អូនវៀតណាមដែរ។ អ៊ីចឹងតើគាត់មានប្រាប់អំពីអ្វី ពីគោលនយោបាយ ពីខាងថ្នាក់អង្គការលើមកថា ទាក់ទងជាមួយនឹងវៀតណាមហ្នឹង តើយ៉ាងម៉េចដែរទៅលោកអ៊ំ? គាត់មានប្រាប់ពីគោលនយោបាយជាមួយនឹងវៀតណាមហ្នឹងដែរទេលោកអ៊ំ?

[១១:៥៥:៥៦]

**ផ៖** មុនដំបូងហ្នឹង កាលគាត់មកប្រជុំអប់រំពួកខ្ញុំថា ប្រកាសអប់រំពុកម៉ែ-- អប់រំឋានៈភូមិ ប្រធានភូមិ ប្រធានស្រុក យួនកុំហៅ យួនៗ យើងហៅបងប្អូនវៀតណាម អាហ្នឹងបានវាសមគ្នា។ យើងនិយាយវាទាន់ បើថាហៅយួនៗ ដូចយើងប្រឆាំងគេ។ គាត់ថាបងប្អូនយើងជាមួយវៀតណាម កម្ពុជា-លាវ បងប្អូនជីដូនមួយ។ គាត់ថាអ៊ីចឹង។ ដល់ចុងក្រោយទៀត ចោទថា ខ្ញុំចូលបក្សសម្ព័ន្ធវៀតណាម បាននុ៎ងហើយគាត់ចាប់ខ្ញុំឃុំឃាំងនៅភ្នំពេញហ្នឹង។ ថ្ងៃខែ ថ្ងៃ៩ ខែ៩ ឆ្នាំ៧៨។

**ស៖** ចាស, អរគុណលោកអ៊ំ ខ្ញុំនឹងទៅដល់សំណួរហ្នឹង តែខ្ញុំនឹងសួរសំណួរបន្តទៅទៀតនៅក្នុងរយៈពេលមុនពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញណ៎ាលោកអ៊ំ។ អ៊ីចឹងខ្ញុំចង់សួរជម្រាបសួរលោកអ៊ំទៀតថា នៅពេលហ្នឹង លោកអ៊ំដឹងទេថា លោក អៀង សារី ហ្នឹងមានតួនាទីជាអ្វីដែរ?

[១១:៥៦:៥៣]

**ផ៖** គណៈភូមិភាគព្ហ៍សាន។ គេហៅគណៈភូមិភាគព្ហ៍សាន ពួកខ្ញុំអត់ដឹងថាភូមិភាគព្ហ៍សាន មិនដឹងជាយ៉ាងម៉េច គេថាភូមិភាគព្ហ៍សាន។

**ស៖** ចាស, អរគុណលោកអ៊ំ។ អ៊ីចឹងតើលោកអ៊ំដឹងទេថា នៅពេលហ្នឹងគណៈភូមិភាគព្ហ៍សាន ហ្នឹងមានអ្នកណាគេខ្លះដែរលោកអ៊ំ?

**ផ៖** ដឹងឮគេថាគណៈភូមិភាគហ្នឹង ប្រធានគេហ្នឹង តាពត, អៀង សារី, អ៊ំ នួន ជា, ខៀវ សំផន គឺគណៈៗភូមិភាគៗ។ កាលហ្នឹងឃើញមុខទាំងអស់ អ៊ំៗបួននាក់ហ្នឹងឃើញទាំងអស់ ពេលគេធ្វើបុណ្យៗពួកមកពីវៀតណាមនុ៎ង គេធ្វើបុណ្យពួកមកពីវៀតណាតនុ៎ង អាហ្នឹងឃើញពួកគាត់បួននាក់ហ្នឹង។

**ស៖** អរគុណលោកអ៊ំ។ អម្បាញ់មិញលោកអ៊ំ និយាយទាក់ទងជាមួយនឹងឈ្មោះអ៊ំ ពក។ អ៊ីចឹងខ្ញុំចង់ឲ្យអ៊ំបញ្ជាក់បន្តិចថា អ៊ំ ពក ហ្នឹងជាអ្នកណាគេដែរ? ឈ្មោះពេញគាត់ជាអ្នកណាដែរ?

**ផ៖** តាពតៗ។

**ស៖** អ៊ំ ពក ហ្នឹងជាអ្នកណាគេលោកអ៊ំ?

**ផ៖** ប៉ុល ពត ហ្នឹងហើយ តាពត។

[១១:៥៨:២៥]

**ស៖** អរគុណលោកអ៊ំ ខ្ញុំសូមអនុញ្ញាតបន្តសំណួរតទៀត។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកអ៊ំនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត នៅក្នុងទំព័រទីបី ជាភាសាខ្មែរ។ លោកអ៊ំបានឆ្លើយថា នៅក្នុងឆ្នាំ១៩៧០ លោកអ៊ំ និងអ្នកភូមិផ្សេងទៀតត្រូវបានគេហៅឲ្យចូលក្នុងព្រៃ សង់ផ្ទះ និងមន្ទីរឲ្យ ប៉ុល ពត ហើយនិង អៀង សារី។ តើអ៊ីចឹងមែនទេលោកអ៊ំ?

**ផ៖** មែនៗ ពិតអ៊ីចឹង។

**លោក ម៉ៃខល កាណាវាស៖**

ជំទាស់ ព្រោះថាសំណួរនេះគឺជាសំណួរនាំមុខ ដែលនាំឲ្យដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានចម្លើយ។ គាត់ៗ ដើមបណ្ដឹងរដ្ឋប្បវេណីមិនចាំ ប៉ុន្តែគាត់សួរទៅដោយសំអាងទៅលើចម្លើយមួយចំនួនដែលយកមកចោទទៅជាសំណួរនាំមុខ។ ដូច្នេះ ខ្ញុំសូមជំទាស់ទៅនឹងការសួរបែបនេះ។

[១១:៥៩:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោកមេធាវី ដែលធ្វើការជំទាស់ ហើយដោយសំណួរនាំមុខ គឺអង្គជំនុំជម្រះបានរំឭកកាលពីថ្ងៃចន្ទត្រឹមត្រូវណាស់ ថាប្រការដែលចៀសវាងនូវការតាំងសំណួរផ្សេងៗ នៅក្នុងនោះគឺមានទាំងសំណួរនាំមុខផង ដែលភាគីមិនគប្បីចាត់សួរសំណួររបៀបនេះទៅគោលដៅនៃការសួរទេ។

ហេតុដូច្នេះ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលជំនួសមុខឲ្យមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រៀបចំនូវសំណួរឲ្យបានត្រឹមត្រូវ ចៀសវាងនូវសំណួរដែលច្បាប់ហាមមិនឲ្យសួរ។ ជាក់ស្ដែងអង្គជំនុំជម្រះបានជម្រាប រំឭកជូនរួចហើយមុនពេលសួរដេញដោល។

[១២:០០:៣២]

អរគុណ។ ឥឡូវនេះដល់ម៉ោងសមល្មមនឹងឈប់សម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទពីររូបត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយនិងឲ្យនាំគាត់ត្រឡប់មកវិញនៅរសៀលនេះវេលាម៉ោង-- ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០២ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ហើយមុននឹងប្រគល់វេទិកាទៅមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានមេធាវីតំណាងជាអ្នកទទួលសិទ្ធិក្នុងការសួរ។ សូមរំឭកដល់មេធាវីថា ការកត់សម្គាល់ឃើញរបស់អង្គជំនុំជម្រះលោកស្រីមេធាវីនិយាយញាប់ អ៊ីចឹងសូមនិយាយឲ្យបានយឺត ដើម្បីឲ្យអ្នកបកប្រែអាចបកប្រែភាសា

ទាន់ ទីមួយ។ ទីពីរ ទុកគម្លាតគ្នារវាងការបកប្រែចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយនឹងសំណួរថ្មី ដើម្បីឱកាសឲ្យការបកប្រែហ្នឹងបានអស់សេចក្តី។

អង្គជំនុំជម្រះប្រគល់វេទិកានេះជូនទៅមេធាវី។ សូមអញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន! មុននឹងចាប់ផ្តើមសួរលោក ក្លាន រ៉ិត បន្តទៀតនេះ ខ្ញុំសូមចោទសំណួរមួយសំណួរដល់អង្គជំនុំជម្រះថា អង្គជំនុំជម្រះនៅក្នុងអនុស្សរណៈ E145 បាននិយាយថា ភាគីអាចស្នើសុំដោយផ្ទាល់មាត់ និងសុំសួរសាក្សី ឬក៏ភាគីទៅលើប្រធានបទដែលហួសពីការជំនុំជម្រះ ហ្នឹងទីមួយ ហើយប្រធានបទដែលអាចទាក់ទងទៅនឹងសំណុំរឿង០០២ តែម្តង។ តើដើម្បីឲ្យដំណើរការល្អនោះ តើយើងអាចឲ្យភាគីទាំងអស់នោះ ដែលថា ភាគីអាចចង់សុំធ្វើសួរបែបហ្នឹងយើងអាចសួរបានទេ? យើងអាចធ្វើយ៉ាងម៉េចដើម្បីរៀបចំការចោទសំណួររបស់យើងឲ្យល្អនោះ? ខ្ញុំគិតថា ជាការសំខាន់ ហើយយើងចង់បានព័ត៌មានបែបនេះ។

[១៣:៣៣:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ តាមអនុស្សរណៈដូចលោកស្រីមេធាវីបានលើកឡើង ហើយបន្ថែមពីលើនេះ អង្គជំនុំជម្រះបានណែនាំកាលពីព្រឹកថ្ងៃចន្ទ អំពីនីតិវិធីនៃការសួរដេញដោលរវាងការសួរដេញដោលចំពោះជនជាប់ចោទ ហើយនិងដេញដោលចំពោះសាក្សី ឬ/និង ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះវគ្គ-- នៅក្នុងការជំនុំជម្រះដំណាក់កាលទីមួយ ដែលយើងអាចហៅម្យ៉ាងទៀតថា សំណុំ០០២/០១។ ការសួរដេញដោលចំពោះជនជាប់ចោទ គឺអង្គជំនុំជម្រះបានកម្រិតត្រឹមតែវគ្គទីមួយ មួយវគ្គម្តងៗនៃបញ្ហាដែលលើកឡើង ដូចជាសវនាការលើកនេះ យើងបានកំណត់ត្រឹមតែបណ្តាកថាខណ្ឌទាំងឡាយ ដែលអង្គជំនុំជម្រះបង្គាប់ឲ្យក្រឡាបញ្ជីអាននូវអង្គហេតុ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដែលជាបទអង្គហេតុមានលក្ខណៈទូទៅ ហើយនិងសាវតារ ប្រវត្តិសាវតាររបស់ជនជាប់ចោទនីមួយៗមានលក្ខណៈដោយឡែក។ នេះសម្រាប់ជនជាប់ចោទ។

ដោយឡែកសម្រាប់ការសួរដេញដោយចំពោះសាក្សី ឬ/និង ដើមបណ្តឹងរដ្ឋប្បវេណី ភាគីអាចសួរពន្លាតកម្រិតត្រឹមសំណុំរឿងលេខ០០២/០១ គឺបណ្តាលអង្គហេតុទាំងឡាយ ដែលលើកយកមកធ្វើសវនាការសម្រាប់ដំណាក់កាលទីមួយ គឺជម្លៀសទីមួយ និងជម្លៀសទីពីរតែប៉ុណ្ណោះ ដែលមានឯកសារ

ជម្រាបជូនរួចហើយ។ ទំនងជាច្បាស់ហើយ ដូចជាមិនអីដែលមិនច្បាស់នោះទេ។

[១៣:៣៦:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដើម្បីឲ្យច្បាស់នោះ បើសិនជាភាគីណាមួយមានចេតនាចង់សុំលក្ខខណ្ឌពិសេសមួយដើម្បីចោទសំណួរទៅលើប្រធានបទផ្សេងនោះ តើអង្គជំនុំជម្រះនឹងជំទាស់ ឧទាហរណ៍ដូចទាក់ទងនឹងលោក ក្លានវ៉ិត នេះជាដើម។ ព្រោះថាអម្បាញ់មិញនេះ ខ្ញុំយល់ឃើញថាយ៉ាងហោចណាស់មានភាគីណាមួយនោះចង់ចោទសំណួរដែលខុសពីប្រធានបទដែលយើងធ្វើពិភាក្សាថ្ងៃនេះ។

អ៊ីចឹងខ្ញុំសង្ឃឹមថា សួរថាតើអង្គជំនុំជម្រះអនុញ្ញាត ឬមិនអនុញ្ញាត យើងខ្ញុំចង់ដឹងមុននឹងបន្តការសួរសំណួរតទៅទៀតនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះដូចជាកម្រិតកំណត់នូវអង្គហេតុ ដែលជាប្រធានបទនៃការពិភាក្សាសម្រាប់សវនាការដំណាក់កាលទីមួយហ្នឹងច្បាស់លាស់ហើយ ហើយអង្គជំនុំជម្រះដូចបានជម្រាបតាមអនុស្សរណៈកន្លងមកថា ភាគីទាំងឡាយណាដែលប៉ុនប៉ងក្នុងការសួរសំណួរទៅសាក្សីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញចេញផុតពីអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងអនុស្សរណៈរបស់ខ្លួន ស្តីពីបណ្តាអង្គហេតុដែលនឹងលើកយកមកធ្វើសវនាការសម្រាប់ដំណាក់កាលទីមួយ គឺស្មើហ្នឹង ឬក៏ហៅម្យ៉ាងទៀតថា "សំណុំរឿង០០២/០១" នោះ ទំនងជាមិនទទួលបានការអនុម័តយល់ព្រមពីអង្គជំនុំជម្រះឡើយ។ ពាក្យនេះមានន័យស្មើ "អត់"។

[១៣:៣៨:០៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព។ បើខ្ញុំចង់-- សុំឲ្យអង្គជំនុំជម្រះបំភ្លឺអំពីភាគី អំពីអ្វីដែល-- ពាក្យយើងនិយាយថា សំអាងហេតុពិសេសដែលអាចបញ្ជាក់ថាឲ្យអនុញ្ញាតឲ្យចោទសំណួរទាក់ទងទៅតែនឹងផ្នែកទីមួយនៃការកាត់សេចក្តី។ អ៊ីចឹង សព្វថ្ងៃនេះ គឺថាយើងចង់ដឹងថា តើមូលហេតុពិសេសនេះវាយ៉ាងម៉េច សំណួរនេះ គឺធ្វើយ៉ាងណាឲ្យយើងអាចត្រៀមសំណួររបស់យើងបាន។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន សំណួរដែលបានសួរនៅក្នុងរសៀលនេះ គឺបានឆ្លើយតបរួចមកហើយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការជាក្រៅផ្លូវការ។ វាមិនចាំបាច់ចំណាយពេលឥតប្រយោជន៍នៅក្នុងសវនាការនេះលើបញ្ហានេះឡើយ។ ប្រសិនបើភាគីណាមួយចង់លើកឡើងបញ្ហាក្រៅពីអ្វីដែលយើងវិភាគពិភាក្សានេះ គឺត្រូវតែសុំការអនុញ្ញាត ដើម្បីឲ្យឱកាសដល់អង្គជំនុំជម្រះធ្វើការសម្រេច ថាតើគួរអនុញ្ញាតឲ្យលើកឡើងក្រៅពីបញ្ហាហ្នឹងដែរឬទេ?

សំណួរទីពីរវិញក៏បានឆ្លើយតបជាច្រើនសារដែរ នៅក្នុងកិច្ចប្រជុំរៀបចំសវនាការក្រៅផ្លូវការនោះ ដែលយើងខ្ញុំរីករាយនឹងផ្តល់នូវកំណត់ហេតុដែលយើងបានកត់ត្រាទុកនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនោះ ថាតើបញ្ហាទីពីរនេះ បានពិភាក្សាគ្នានិងដោះស្រាយដោយរបៀបណា? ប្រសិនចង់បាន ខ្ញុំអាចជូនបាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ មេធាវីទំនងជាច្បាស់លាស់ហើយ លើបញ្ហានេះ ហើយអង្គជំនុំជម្រះបញ្ជាក់បន្ថែមទៀត ដើម្បីឲ្យកាន់តែច្បាស់លើបញ្ហានេះ គឺសូមលើអង្គហេតុដែលបានកត់ត្រានៅក្នុងឯកសារ E124/7.1/correct2 នេះជាអង្គហេតុ កន្សោមអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់ធ្វើការលើកយកមកពិភាក្សាដេញដោលនៅក្នុងដំណាក់ទីមួយ។

[១៣:៤១:២៣]

ហើយចំណែកឯបញ្ហាផ្សេងទៀត ដែលអាចលាតចេញពីផុតពីការសួរដេញដោលនូវអង្គហេតុដែលមានលេខកូដសម្គាល់ដូចយើងបានបង្ហាញនេះ ភាគីអាចស្នើសុំ។ ពាក្យស្នើសុំនោះ គឺត្រូវបង្ហាញអំពីហេតុកាលៈទេសៈពិសេសទាំងឡាយដែលជាមូលហេតុនាំឲ្យខ្លួនសុំដូច្នេះ។ ហើយការបញ្ជាក់នេះ គឺបន្ថែមទៀត ដូចលោកមេធាវីការពារក្តីអន្តរជាតិការពារលោក អៀង សារី បានបញ្ជាក់ហើយ យើងមានទាំងអនុស្សរណៈ យើងមានទាំងកិច្ចប្រជុំដោះស្រាយផ្លូវការជាហូរហែ ដើម្បីកំណត់នូវបែបផែននៅក្នុងការធ្វើសវនាការនៃការបំបែកកិច្ចដំណើរការនីតិវិធីជាផ្នែកៗដូច្នេះ ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីឲ្យលឿនទៅមុខ ហើយនិងសម្រួលដល់កិច្ចការផ្សេងទៀតនៃកិច្ចដំណើរការរបស់យើង។

ដូច្នេះ គឺបញ្ហានេះ ដូចជាសមល្មមហើយ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន ចំពោះការបំភ្លឺនេះ។ ខ្ញុំអានអនុស្សរណៈនោះហើយ ក៏ប៉ុន្តែគ្រាន់តែចង់ទាញការសន្និដ្ឋានថា ពីការលើកឡើងរបស់លោកប្រធានអម្បាញ់មិញ គឺថាពុំមានភាគីណាមួយដែលថាមានចេតនាចង់សុំឱ្យមានលក្ខខណ្ឌពិសេសមួយ គឺថាក្នុងការចោទសំណួរលើលោក ក្អាន ទ៊ិត នេះលើប្រធានបទផ្សេងទៀតនោះទេ ពីព្រោះថាពុំមានអ្នកណាបានត្រៀមលក្ខណៈឱ្យបានច្បាស់លាស់។ ខ្ញុំគិតថាយើងនឹងចោទសំណួរឱ្យចេញផុតពីប្រធានបទដែលបានកំណត់នោះទេ។

អ៊ីចឹង ខ្ញុំគ្រាន់តែចង់បញ្ជាក់ឱ្យច្បាស់ថាធ្វើម៉េចឱ្យបានដឹងមុនទាំងអស់គ្នា។ សូមអរគុណ។

[១៣:៤៣:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអរគុណ។ ហើយដោយហេតុនេះហើយ ទើបអង្គជំនុំជម្រះបានរំឭកម្តងសាជាថ្មីម្តងទៀត នៅក្នុងអំឡុងពេលនៃមុនចាប់ផ្តើមនូវកិច្ចពិភាក្សានៅព្រឹកថ្ងៃច័ន្ទ។ នេះ ជាកិច្ចប្រឹងប្រែ ដើម្បីរំឭកម្តងហើយម្តង ក្រែងលោមានការភ្លេច ហើយនាំឱ្យមានការរំខានដល់ពេលវេលានៃកិច្ចប្រឹងប្រែងក្នុងកិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿងលេខ០០២ នេះ។

សូមអញ្ជើញលោកមេធាវី!

[១៣:៤៤:០៥]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស, សូមអរគុណលោកប្រធាន។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

ដើម្បីធ្វើជាកំណត់ប្រតិចារឹក ដើម្បីដែលលោកចៅក្រម ឡាវ៉ែន៍ បានលើកឡើង។ ខ្ញុំសូមអានដោយសារតែវាមានសារៈសំខាន់ក្នុងការធ្វើសេចក្តីសន្និដ្ឋានរបស់យើង។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌត្រង់ផ្នែកលេខបី មាត្រា៣១២ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនោះទេ។ ហើយខ្ញុំសូមអនុញ្ញាតឱ្យធ្វើការពន្យល់ឱ្យបានលម្អិតបន្តិចទៅលើចំណុចហ្នឹង ដែលជាចំណុចមួយដែលខ្ញុំចាប់អារម្មណ៍។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, បើសិនជាខ្ញុំមិនច្រឡំទេ គឺថាការកត់សម្គាល់ដែលមេធាវីការពាររបស់ នួន ជា បានលើកឡើងនោះ គឺថាចោទលើកខ្លឹមសារនៃមាត្រា៣០០ ខ្ញុំភ្លេចលេខមាត្រាហ្នឹងហើយ។ ៣១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដែលចែងថាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានគេស្តាប់ក្នុងឋានៈជាសាក្សីនោះទេ។ បាទ អ៊ីចឹង ឬមិនមែនទេ។ លោកអម្បាញ់មិញសួរលើខ្លឹមសារនៃមាត្រាហ្នឹងមែនទេ?

**លោក អេនគ្រូ អ៊ីនូហ្សី៖**

ពិតជាត្រឹមត្រូវ ខ្ញុំចង់សួរទៅលើមាត្រាហ្នឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បញ្ញត្តិហ្នឹង គឺថាមាននៅច្បាប់បារាំង ច្បាប់ខ្មែរក៏មានដែរ គឺថាដើមបណ្តឹងរដ្ឋប្បវេណីមិនស្បថទេ គឺថាគាត់ផ្តល់សក្ខីកម្មលើអង្គហេតុហ្នឹង គេស្តាប់គាត់ហើយ ប៉ុន្តែស្តាប់គាត់ក្នុងឋានៈគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី មិនមែនជាសាក្សីដែលថាត្រូវស្បថនោះទេ។ នេះជាខ្លឹមសារនៃបទប្បញ្ញត្តិហ្នឹង។

**លោក អេនគ្រូ អ៊ីនូហ្សី៖**

សូមអរគុណ។ យើងខ្ញុំអាចធ្វើការពិនិត្យមើលទៅលើមាត្រានោះដើម្បីយកមកធ្វើជាមូលដ្ឋានក្នុងការដាក់សេចក្តីសន្និដ្ឋានរបស់ពួកយើង សូមអរគុណ។

[១៣:៤៧:០៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស! សូមអរគុណជាថ្មីម្តងទៀតដល់លោកប្រធាន។ ខ្ញុំសូមរំឭកលោកអ៊ំបន្តិច កាលពីព្រឹកមិញ យើងចប់នៅត្រង់កន្លែងមួយ ដែលលោកអ៊ំបាននិយាយថា លោកអ៊ំទៅជួយសង់ផ្ទះ និងមន្ទីរឲ្យ ប៉ុល ពត និង អៀង សារី ហើយលោកអ៊ំបានប្រាប់ថា លោកអ៊ំបានទៅជួបជាមួយនឹង ប៉ុល ពត និង អៀង សារី ដោយផ្ទាល់។

**ស៖** អ៊ីចឹងសំណួរខ្ញុំបន្តដែលខ្ញុំចង់សួរលោកអ៊ំ ខ្ញុំចង់សួរលោកអ៊ំថា តើលោកអ៊ំទៅជួបជាមួយនឹងពួកគាត់នៅពេលណា?

**លោក ក្លាន វ៉ិត៖**

**ឆ៖** សូមឆ្លើយឆ្នាំ អត់នៅក្រោយ-- ឆ្នាំមុននេះ ឆ្នាំ៧០។

**ស៖** អ៊ីចឹង នៅពេលដែលលោកអ៊ំទៅជួបជាមួយនឹងពួកគាត់ម្តងៗ តើពួកគាត់ប្រាប់ឲ្យលោកអ៊ំធ្វើអ្វីខ្លះ?

**ឆ៖** ពួកគាត់អត់ប្រាប់អីទេ គឺដើម្បីការពារខ្មាំងចេញចូល ការពារកន្លែងពួកគាត់នៅ ប៉ុន្តែខ្ញុំនៅជិត មានទាហាន មានប៉ូលិស មានចៅហ្វាយស្រុក មានមេឃុំ នៅតាឡាវហ្នឹង។ ខ្ញុំផ្លូវគេចេញចូល ខ្មាំងវាចេញចូល។ ការពារពួកគាត់។

[១៣:៤៨:៤៣]

**ស៖** អរគុណលោកអ៊ំ តើលោកអ៊ំអាចជម្រាបបានទេថានៅពេលហ្នឹងថា លោកអ៊ំមានតួនាទីជាអ្វីដែរបានជាគេទុកចិត្តលោកអ៊ំ ហើយឲ្យលោកអ៊ំទៅសង់ផ្ទះ ហើយចេញចូលមន្ទីរនោះដែលគេអាចប្រើលោកអ៊ំបាន?

**ឆ៖** កាលណោះគេចាត់តាំងខ្ញុំធ្វើប្រធានឃុំ។

**ស៖** លោកអ៊ំអាចជម្រាបបានទេ ពេលហ្នឹងគេតែងតាំងលោកអ៊ំជាមេឃុំអីដែរ លោកអ៊ំឈ្មោះឃុំ?

**ឆ៖** ឃុំតាឡាវ ស្រុកបរកែវ នៅហ្នឹងដែរ ស្រុកអណ្តូងមាស។

**ស៖** អរគុណលោកអ៊ំ អ៊ីចឹងតើលោកអ៊ំអាចជម្រាបជូនអង្គសវនាការបានទេថា ក្នុងនាមជាមេឃុំម្នាក់ ឃុំតាឡាវហ្នឹង តើលោកអ៊ំត្រូវគ្រប់គ្រងមើលប៉ុន្មានភូមិ? ប្រហែលជាប៉ុន្មានគ្រួសារដែរ?

**ឆ៖** ប្រាំមួយភូមិ។ គ្រួសារភ្លេចអស់ហើយ។

[១៣:៥០:១១]

**ស៖** អ៊ីចឹង លោកអ៊ំអាចបញ្ជាក់ជូនអង្គសវនាការម្តងទៀតបានទេថា តួនាទីជាមេឃុំហ្នឹង តើលោកអ៊ំត្រូវធ្វើការងារអីគេខ្លះនៅក្នុងឃុំដែលលោកអ៊ំគ្រប់គ្រងហ្នឹង?

**ឆ៖** ទីមួយ ខ្ញុំប្រធានអប់រំ ប្រធានតាមភូមិ។ ទីពីរ ដើម្បីការពារកុំឲ្យយួនវាចេញចូល មានតែពីរ។

**ស៖** លោកអ៊ំបានបញ្ជាក់អម្បាញ់មិញហ្នឹង ទាក់ទងជាមួយនឹងថាលោកអ៊ំត្រូវការពារកុំឲ្យមានយួនចេញចូល អ៊ីចឹងតើលោកអ៊ំអាចបញ្ជាក់បានទេថា តើនៅពេលហ្នឹង គោលនយោបាយរបស់ខ្មែរ

ក្រហមជាមួយនឹងវៀតណាមហ្នឹង ថាតើវាមានលក្ខណៈយ៉ាងដូចម្ដេចបានជាលោកលោកអ៊ំត្រូវគេបញ្ជាឲ្យការពារកុំឲ្យមានគិញយួនចេញចូលបែបដូច្នោះ?

**ឆ៖** គេខ្លាចបែកការណ៍សម្ងាត់របស់គេ។

**លោក ម៉ែខល កាណាវាស៖**

ជាថ្មីលោកប្រធាន ខ្ញុំសូមជំទាស់ ប្រសិនបើយើងពិនិត្យទៅលើសំណួរ វាជាអង្គហេតុមិនមែនជាភស្តុតាងនោះទេ វាជាបញ្ហាគោលនយោបាយរបស់វៀតណាម។ ដូច្នេះហើយ យើង គាត់ហាក់ដូចជាសួរចំសំណួរ ដើម្បីចង់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះចង់ឆ្លើយ ដូច្នេះ វាជាការដឹកនាំដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ ខ្ញុំស្នើសុំឲ្យមេធាវីសួរសំណួរ អ្វីទៅ នរណាគេ ហេតុអ្វី ហើយវាជាអ្វី ដើម្បីឲ្យសាក្សីពន្យល់ ចៀសវាងកុំឲ្យបង្ហាញអង្គហេតុដើម្បីឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

**លោកស្រី ម៉ុច សុវណ្ណារី៖**

បើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមឆ្លើយនឹងសំណួរនេះ។ នៅពេលដែល ខ្ញុំបានសួរទាក់ទងជាមួយនឹងគោលនយោបាយខ្មែរក្រហម ជាមួយនឹងវៀតណាម ព្រោះខ្ញុំគិតថានេះគឺជាប្រវត្តិសាស្ត្រ។ នេះគឺអ្វីដែលជនជាប់ចោទ គាត់បានលើកឡើងពីដំបូង។ ហើយខ្ញុំគិតថា វាស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះដំណាក់កាលទីមួយនេះ។ ហើយខ្ញុំបានប្រើពាក្យគោលនយោបាយជាមួយនឹងប្រទេសវៀតណាម ដោយសារដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានលើក ឆ្លើយពីមុនដំបូង គាត់បានឆ្លើយថា គាត់ត្រូវបានគេចាត់តាំងឲ្យយាម កុំឲ្យមានគិញយួនចេញចូល ខ្មាំងយួនចេញចូល។ ហេតុដូច្នេះហើយ ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាមានការតម្រូវឲ្យគាត់នៅក្នុងការពារបែបដូច្នោះ។ ដូច្នេះ ហើយបានជាខ្ញុំសួរសំណួរនេះ ហើយខ្ញុំគិតថា សំណួរនេះគឺមិនមែនជាសំណួរនាំមុខទេ ពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានឆ្លើយមុនជាស្រេចអំពីបញ្ហានេះរួចទៅហើយ។

[១៣:៥៣:១៨]

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ចង្អុលបង្ហាញថា សំណួរនេះជាសំណួរនាំមុខដែលថា គេ

ដែលថាដូចមានការបកប្រែនោះគឺថា ត្រូវបានចោទដោយលោក កាណាវាស ផ្ទាល់តែម្តងទៅកាន់ ទៅដល់អ្នកជំនាញខាងផ្លូវច្បាប់ជាន់ខ្ពស់នោះ ចម្លើយតបមកវិញគឺថា សំណួរនាំមុខនោះអាចអនុញ្ញាតឲ្យចោទសួរបាន។ ខ្ញុំមិនដឹងថា ផ្តល់សេចក្តីសង្ខេបនៃកិច្ចប្រជុំនោះទៅលោក កាណាវាស ឬក៏អត់ទេ ក៏ប៉ុន្តែ យ៉ាងហោចណាស់ក៏មានការឆ្លើយតបទាក់ទងទៅនឹងបញ្ហាចោទសំណួរនាំមុខនេះដែរ។

[១៣:៥៤:១១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

លោកសហព្រះរាជអាជ្ញាបានលើកឡើងអំពីសំណួរមុនដែលបានលើកឡើង។ដូច្នេះហើយ ប្រសិនបើដកស្រង់ចេញពីសំណួរនោះ សហព្រះរាជអាជ្ញាគួរតែយកសំណួរនោះពិចារណាទៅលើបរិបទ ថាយើងគួរគិតអំពីសំណួរដែលសួរនៅថ្ងៃនេះដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលជាសំណួរនាំមុខ។ គាត់បានប្រើពាក្យថា “គោលនយោបាយ” ឬ “មាគ៌ា” ថាវា សហព្រះរាជអាជ្ញា គឺគាត់មិនបានលើកអំពីគោលនយោបាយនោះទេ។ ដូច្នេះហើយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចសួរថា តើគោលនយោបាយជាអ្វី? ដោយអនុវត្តដោយរបៀបណា...។ល។ ក៏ប៉ុន្តែ សំណួររបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺហាក់ដូចជាសំណួរ ដើម្បីនាំមុខទៅដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់ចង់បាន។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៥៥:៤៣]

**ប្រធានអង្គជំនុំ៖**

ដោយសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានសួរនេះ គឺផ្អែកលើមូលដ្ឋាននៃកំណត់ហេតុដែលបានធ្វើឡើងកាលពីពេលមុន នៅក្នុងដំណាក់កាលស៊ើបអង្កេត។ ដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីបន្តការសួរតទៅទៀត។

សូមអញ្ជើញ!

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកអ៊ំតទៅទៀតថា នៅក្នុងតំណែងលោកអ៊ំជាមេឃុំតាឡាវ តើអ្នកណាជាអ្នកតែងតាំងលោកអ៊ំឲ្យធ្វើជាមេឃុំ?

**ឆ៖** អ៊ំថង ស៊ី, អ៊ំវង់, អ៊ំយ៉ា អង្កាល់ហ្នឹងឃើញពួកគាត់មកចាត់តាំង។

**ស៖** តើលោកអ៊ំអាចបញ្ជាក់បានទេថា អ៊ំដែលមានឈ្មោះដូចដែលលោកអ៊ំបានរៀបរាប់អម្បាញ់មិញហ្នឹង តើគាត់មានតួនាទីជាអ្វីដែរ នៅក្នុងតំបន់ហ្នឹងលោកអ៊ំ?

**ឆ៖** អង្កាល់ហ្នឹងអ៊ំ ថង ស៊ី ហ្នឹងចៅហ្វាយស្រុក, អ៊ំវង់ ហ្នឹងគណៈភូមិភាគ, អ៊ំយ៉ា គណៈភូមិភាគ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងសួរលោកអ៊ំទាក់ទងជាមួយនឹងដំណាក់កាលនៅពេលដែលខ្មែរក្រហមបានរំដោះទីក្រុងភ្នំពេញបាននៅក្នុងខែមេសា ឆ្នាំ១៩៧៥។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកអ៊ំថា ពេលហ្នឹងហេតុអ្វីបានជាលោកអ៊ំដឹងថា ខ្មែរក្រហមបានវាយប្រហារភ្នំពេញ ហើយបានរំដោះភ្នំពេញនៅក្នុងពេលនុ៎ង?

**ឆ៖** ដោយសារមាន លន់ នល់ រដ្ឋប្រហារ ខ្មែរវ៉ៃខ្មែរ អ៊ីចឹង។ ហ្នឹងបានដឹង។

**ស៖** នៅពេលដែលខ្មែរក្រហមបានទទួលជ័យជម្នះរំដោះបានភ្នំពេញ នៅក្នុងថ្ងៃទី១៧ ខែមេសា នៅក្នុងឆ្នាំ១៩៧៥ តើពេលនុ៎ងលោកអ៊ំនៅកន្លែងណាដែរលោកអ៊ំ?

[១៣:៥៨:៣៨]

**ឆ៖** នៅភូមិអ៊ុន ដដែល។

**លោក អាកទូរ វែកកែន៖**

ខ្ញុំសូមអនុញ្ញាតនិយាយបន្តិច។ លោកប្រធានទើបតែបានចង្អុលបង្ហាញថា ក្នុងដីកាដំណោះស្រាយនុ៎ងបានរៀបរាប់ពីអង្គហេតុមួយចំនួន ខ្ញុំឥឡូវនេះដូចជាព្រួយបារម្ភខ្លាំងណាស់ អំពីទស្សនៈរបស់ដីកាដំណោះស្រាយនេះ បើសិនជាដីកាដំណោះស្រាយនេះរៀបរាប់ពីអង្គហេតុនេះ ខ្ញុំ-- ឥឡូវខ្ញុំចោទសំណួរថាតើហេតុអីបានយើងនៅទីនេះកំពុងតែពិភាក្សាពីការជម្រះសេចក្តីនេះ ដែលខ្ញុំយល់ឃើញថា ដែលថា ចំពោះខ្ញុំវិញ ខ្ញុំថាយើងមិនត្រូវអានដីកាដំណោះស្រាយហ្នឹងឡើងវិញទេ ដូចដែលសហភាតារបស់ កាណាវាស បានលើកឡើងអម្បាញ់មិញអ៊ីចឹង គឺថាការដែលដឹងថាតើមានគោលនយោបាយ ឬក៏មានការអនុវត្តគោលនយោបាយនោះ តើនេះជា ថាអាចជាប្រធានបទយកមកចោទសួរនៅក្នុងការជំនុំជម្រះនេះដែរទេ? បើអង្គជំនុំជម្រះគិតថា ថ្ងៃនេះគឺថាយើងអាចគិតថា យកអដីកាដំណោះស្រាយនេះ

ជាការត្រឹមត្រូវ ហើយស្រេចហើយនោះ មិនបាច់ពិភាក្សាអីគ្នាទៀតទេ។ ខ្ញុំគិតថា ជាការសំខាន់ណាស់ក្នុងការពិភាក្សាបន្តទៅទៀត សួរដេញដោលគ្នាទៀត នេះជាគោលគំនិតរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដូចជាមានការចំណាប់អារម្មណ៍ អត់មានខ្លឹមសារអីសោះ។ មិនមានសំណួមពរអីជាក់លាក់ទេ គ្រាន់តែជាការរំខានដល់ពេលវេលានៃសវនាការប៉ុណ្ណោះ។

អង្គជំនុំជម្រះបានជម្រាបច្បាស់លាស់អំពីកិច្ចដំណើរការនីតិវិធីរួចហើយ ទាំងលាយលក្ខណ៍អក្សរ ទាំងផ្ទាល់មាត់។ បែរជាមកដល់ពេលនេះ ទើបតែឆ្លល់ ទើបតែធ្វើការកត់សម្គាល់ ដោយគ្មានការបង្ហាញនូវសំណួមពរ ឬសំណើអីច្បាស់លាស់ទេ។

អញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តនូវសំណួរ!

[១៤:០២:១០]

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

ចាស, សូមអរគុណដល់លោកប្រធានជាថ្មី។

**ស៖** ខ្ញុំចង់ជម្រាបសួរលោកអ៊ំទៀតថា ក្រោយដែលខ្មែរក្រហមរំដោះទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ហើយ តើលោកអ៊ំធ្លាប់ត្រូវបានគេអញ្ជើញឲ្យមកភ្នំពេញ ដើម្បីរៀនសូត្រវគ្គនយោ-បាយណាមួយទេលោកអ៊ំ?

**ឆ៖** មានមកប្រជុំ មកប្រជុំមានពីរលើក។ អ្នក-- គ្រូបង្រៀនហ្នឹងអ៊ំ នួន ជា ខ្ញុំឃើញមុខគាត់។

[១៤:០២:៥៥]

**ស៖** អរគុណលោកអ៊ំ។ លោកអ៊ំថា លោកអ៊ំត្រូវបានគេអញ្ជើញឲ្យមកទីក្រុងភ្នំពេញ ដើម្បីរៀនសូត្រវគ្គនយោបាយ ដែលមានលោក នួន ជា គាត់ជាអ្នកបង្រៀនចំនួនពីរលើក។ អ៊ីចឹង ខ្ញុំចង់ជម្រាបសួរលោកអ៊ំថា នៅក្នុងលើកទីមួយ--។

**លោក ម៉ៃខល ផេសមិន៖**

សូមអធ្យាស្រ័យ តើខ្ញុំសូមធ្វើការជំទាស់មុនពេលដែលដើមបណ្តឹងរដ្ឋប្បវេណីឆ្លើយតបទៅនឹងសំណួរនេះ។ យើងហាក់ដូចជាដើរចេញ សួរសំណួរក្រៅវិសាលភាពនៃការជំនុំជម្រះលើកទីមួយ ដែលថាវាហាក់ដូចជាពាក់ព័ន្ធទៅនឹងការជំនុំជម្រះផ្នែកទីពីរប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។

[១៤:០៣:៤៧]

**ប្រធានអង្គជំនុំ៖**

ជំទាស់គ្មានប្រសិទ្ធិភាព។ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវឆ្លើយនឹងសំណួរនេះ ពីព្រោះសំណួរនេះពាក់ព័ន្ធជាមួយនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

អ៊ីចឹងដើម្បីជួយដល់ដើមបណ្ដឹងរដ្ឋប្បវេណី នាងខ្ញុំសូមសួរសំណួរឡើងវិញ។

**ស៖** នាងខ្ញុំសូមសួរលោកអ៊ំថា នៅលើកទីមួយដែលលោកអ៊ំត្រូវបានអញ្ជើញឲ្យចូលរួមរៀនសូត្រវគ្គនយោបាយនៅភ្នំពេញ ដែលមានលោក នួន ជា អ្នកបង្រៀនហ្នឹង។ ខ្ញុំសូមជម្រាបសួរលោកអ៊ំថា តើនៅពេលនោះលោក នួន ជា បានបង្រៀនអ្វីខ្លះដល់ពួកលោកអ៊ំ?

[១៤:០៤:៣៥]

**ឆ៖** ខ្លឹមសារហ្នឹង ខ្ញុំក្ដាប់គេឃោសនា គាត់ថាប្រទេសជាតិឯករាជ្យហើយ ទាល់តែយើងគ្រប់គ្រង ម្ចាស់ការរៀងៗ តាមកន្លែងរស់នៅ ដែលមានគណៈគេចាត់តាំង មានភូមិភាគ មានតំបន់ មានស្រុកមានឃុំ។ ឥឡូវប្រទេសជាតិឯករាជ្យហើយ។ មានតែប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមសួរសំណួរបន្តទៀត អ៊ីចឹងនៅពេលដែលប្រជុំលើកទីមួយរៀនសូត្រវគ្គនយោបាយហ្នឹង តើមានអ្នកណាខ្លះដែលត្រូវបានអញ្ជើញឲ្យចូលរួមរៀនជាមួយនឹងលោកអ៊ំដែរ នៅក្នុងវគ្គហ្នឹង?

**ឆ៖** ច្រើនគណៈភូមិភាគ កាលណាគេសម្រេចការងារប្រជុំ បើមិនមកគេហៅ ចេះតែទៅ។

**ស៖** តើលោកអ៊ំអាចជម្រាបអង្គសវនាការបានទេថា កាលប្រជុំនៅពេលហ្នឹង តើធ្វើនៅក្នុងរយៈពេលប៉ុន្មានថ្ងៃដែរ លោកអ៊ំ?

**ឆ៖** ថាក្នុងដប់ថ្ងៃហ្នឹង កំណត់ថាប្រាំថ្ងៃ។

**ស៖** លោកអ៊ំបានបញ្ជាក់ថា លោកអ៊ំបានចូលរួមរៀនសូត្រនៅភ្នំពេញហ្នឹងមានរយៈពេលពីរលើក ហើយលើកទីពីរហ្នឹងក៏លោក នួន ជា ជាអ្នកបង្រៀនដែរ។ អ៊ីចឹងខ្ញុំចង់សួរលោកអ៊ំថា តើលោកអ៊ំចាំទេថា នៅលើកទីពីរហ្នឹងលោក នួន ជា គាត់បានបង្រៀនអ្វីខ្លះ?

**ឆ៖** ដដែល។ ខ្ញុំអត់ដឹងអីទេ សំបុត្រក៏ចេះ និយាយខ្មែរក៏អត់ចេះ មកដោយសារខ្លាចគេហៅអាហ្នឹងខ្ញុំបានមក ដូចសព្វថ្ងៃដែរ។

**ស៖** អ៊ីចឹង ខ្ញុំសូមជម្រាបសួរលោកអ៊ំតទៀតថា ក្រៅពីលោក នួន ជា នៅពេលដែលរៀនសូត្រវគ្គនយោបាយពីរលើកហ្នឹង តើមានថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហមណាផ្សេងពីគាត់ទៀត ដែលបានឡើង

ទៅបង្រៀនពួកលោកអ៊ំដែរទេ?

[១៤:០៦:៤៩]

**ឆ៖** អត់មានៗ។

**ស៖** អ៊ីចឹង នៅពេលដែលលោកអ៊ំបានចូលរួមរៀនសូត្រវគ្គនយោបាយហ្នឹង ថាតើអ៊ំមានបានៗ ទទួលឯកសារអប់រំអីផ្សេងៗ គេមានចែកឯកសារជូនសិក្ខាកាមដែលចូលរួមនៅក្នុងប្រជុំហ្នឹងដែរទេ លោកអ៊ំ?

**ឆ៖** មានគេចែកឯកសារ គេចេះគេយក ខ្ញុំអត់ចេះអត់យកទេ។ ទៅវិញខ្លួនទទេហ្នឹងហើយ អត់មានកាបូប ខ្ញុំអត់មានអីទេ ខ្ញុំអត់ចេះអក្សរ។

**ស៖** លោកអ៊ំបញ្ជាក់ថា មានគេចែកឯកសារ តែលោកអ៊ំអត់បានទទួលឯកសារហ្នឹងទេ តើលោកអ៊ំអាចដឹងថា ឯកសារហ្នឹងវាជាស្អីដែរឬទេ? តើវាជាឯកសារដូចគ្នានឹងអ្វីដែលថ្នាក់ដឹកនាំខ្មែរក្រហមគាត់បានបង្រៀននៅពេលដែលកំពុងតែរៀនសូត្រហ្នឹង ឬក៏វាជាឯកសារណាមួយដែលអ៊ំអាចដឹងថា វាជាឯកសារអីដែរទេអ៊ំ?

[១៤:០៨:០២]

**ឆ៖** ឯកសារហ្នឹងខ្ញុំនៅក្តាប់ គឺថា រៀនលក្ខន្តិកៈរបស់បក្ស។ ឯកសារលក្ខន្តិកៈរបស់បក្ស បើយើងមិនរៀន យើងអត់មានគោលជំហរទៅធ្វើបដិវត្តន៍ បដិវត្តន៍វាយូរអង្វែងបានហើយ បើយើងមិនតស៊ូវណ្ណៈលះបង់គ្រួសារ លះបង់ជីវិត អត់រស់ អត់កើត។ អាហ្នឹងគេថារៀនឲ្យលក្ខន្តិកៈរបស់បក្ស។ ខ្ញុំអត់ដឹងគេថា បក្សហ្នឹងម៉េច? មិនដឹងថ្ម មិនដឹងទឹក មិនដឹងឈើ ចេះតែក្តាប់គេទៅទេ។

**ស៖** អ៊ីចឹងអ៊ំអត់ដឹងថា ឯកសារហ្នឹងមាន-- អ៊ំដឹងថាឯកសារហ្នឹងវាគឺជាលក្ខន្តិកៈបក្ស។ អ៊ីចឹងតើអ៊ំអាច ពេលហ្នឹងគេមានបង្រៀនពីអត្ថន័យនៃឯកសារថា អូ៎ នៅក្នុងឯកសារហ្នឹងអត្ថន័យរបៀបម៉េចទេ? គេបង្រៀនឲ្យអ៊ំធ្វើរបៀបម៉េចៗ? អ៊ំមានចាំអាហ្នឹងបានទេ អត្ថន័យរបស់ឯកសារហ្នឹងលោកអ៊ំ?

**ឆ៖** បាទចាំ។ ទីមួយ គឺថា គោលជំហរតស៊ូយូរអង្វែង។ ទីមួយ ឲ្យសកម្មពលកម្ម។ ទីពីរ ឲ្យសីលធម៌។ ទីបី ឲ្យស្មោះត្រង់ ឲ្យកុំអួតកុំអាងខ្លាចខ្លាំងចាប់យើង។ អាហ្នឹងគឺថារបៀបលក្ខន្តិកៈ អ៊ីចឹង គេប្រាប់ខ្ញុំ ដោយសារខ្ញុំមនុស្សល្ងង់មិនចេះអក្សរ ខ្ញុំសួរ។ យ៉ាងម៉េចលក្ខន្តិកៈ?ៗ គេថាអ៊ីចេះៗ។ ទីមួយគោលនយោបាយតស៊ូអង្វែង។ ទីពីរ សកម្មការពលកម្ម។ ទីបី ឲ្យសីលធម៌ៗជាមួយបក្ស ជាមួយប្រជារាស្ត្រ កុំនិយាយអួត និយាយអាងយើងធ្វើអ្នកធំអ៊ីចេះៗអ៊ីចុះ បើយើងនិយាយអ៊ីចឹងខ្លាំងវាចាប់

យើងកាត់ក ស្លាប់ យើងឆាប់ស្លាប់។ អាហ្នឹងគេថាលក្ខន្តិកៈរបស់បក្ស។ អ៊ីចឹងបានដឹង។

[១៤:១០:០៨]

**ស៖** ចាស អ៊ីចឹង ខ្ញុំសូមសួរលោកអ៊ំទៀតថា នៅពេលដែលលោកអ៊ំត្រូវបានគេកោះឲ្យមករៀននៅភ្នំពេញហ្នឹង ថាអ៊ំទទួលបានដំណឹងមកពីណាគេ? តើអ្នកណាគេជាអ្នកហៅអ៊ំថា ត្រូវមករៀននៅភ្នំពេញនៅពេលហ្នឹងអ៊ំ?

**ឆ៖** មានសំបុត្រគេផ្ញើតាំងពីភូមិភាគ តំបន់ តំបន់ដល់ស្រុក ស្រុកដល់ឃុំ។ កាលហ្នឹងខ្ញុំធ្វើប្រធានឃុំ។ ស្រុកទាក់ទងតាមខ្សែរយៈការចាត់តាំងរបស់គេ។

**ស៖** អ៊ីចឹងបន្ទាប់ពីលោកអ៊ំៗបានមានប្រសាសន៍ថាលោកអ៊ំបានធ្វើជាប្រធានឃុំតាឡាវ តាំងពីមុនខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញនៅក្នុងឆ្នាំ៧៥។ អ៊ីចឹង ខ្ញុំចង់សួរលោកអ៊ំថា ក្រោយពេលដែលខ្មែរក្រហមរំដោះបានភ្នំពេញ នៅក្នុងឆ្នាំ១៩៧៥ ហ្នឹង ថាតើលោកអ៊ំមានតួនាទីជាអ្វីដែលនៅក្នុងរចនាសម្ព័ន្ធរបស់ខ្មែរក្រហម លោកអ៊ំ?

**ឆ៖** ក្រោយពីនុ៎ង ដល់ឆ្នាំ៧៦ គេចាត់តាំងខ្ញុំអនុស្រុក។

**ស៖** អ៊ំថាគេបានចាត់តាំងអ៊ំធ្វើជាអនុស្រុក អ៊ីចឹងអ៊ំអាចប្រាប់ស្រុកហ្នឹងបានទេ ស្រុកហ្នឹងមានឈ្មោះអ្វីដែរ?

**ឆ៖** កាលហ្នឹងគេហៅស្រុក២១ តំបន់១០១ ស្រុក២១។

**ស៖** លោកអ៊ំបានជម្រាបថា លោកអ៊ំ គឺជាត្រូវបានគេតែងតាំងជាអនុស្រុក២១ នៅក្នុងតំបន់១០១។ អ៊ីចឹង តើលោកអាចជម្រាបជូនអង្គសវនាការបានទេពីរចនាសម្ព័ន្ធនៅក្នុងភូមិភាគដែលលោកអ៊ំកំពុងតែនៅហ្នឹង។ ថាតើនៅក្នុងគណៈភូមិភាគគេហ្នឹងមានអ្នកណាខ្លះដែលជាអ្នកដឹកនាំនៅក្នុងភូមិភាគហ្នឹង លោកអ៊ំ?

[១៤:១២:១៦]

**ឆ៖** អ៊ំ វង់, ធិន។ ធិន ហ្នឹងប្រធានតំបន់។ អ៊ំវង់ គណៈភូមិភាគ នៅស្ទឹងត្រែង។

**ស៖** ខ្ញុំសូមសួរអ៊ំបញ្ជាក់ថែមម្តងទៀតថា នៅក្នុងគណៈភូមិភាគព្រៃសានហ្នឹង ថាតើមានអ្នកណាគេខ្លះ ជាអ្នកគ្រប់គ្រង អ៊ំ?

**ឆ៖** ខ្ញុំរៀបរាប់ គេហៅគណៈភូមិភាគ តាពត, អៀង សារី , អ៊ំ នួន ជា, អ៊ំយ៉ា, អ៊ំមី, អ៊ំខាត់ហ្នឹងគឺថាគណៈភូមិភាគ។ គ្នាគេៗរាប់ឲ្យដឹង។ ខ្ញុំអត់ដឹងទេ។ ខ្ញុំរាប់ ខ្ញុំដឹងថាអានេះ គឺថាគណៈភូមិភាគ

ពួកប្រាំនាក់នេះ។ ហ្នឹងខ្ញុំបានស្គាល់។

[១៤:១៣:២០]

**ស៖** អ៊ីចឹងអ៊ំអាចជម្រាបជូនបានទេថា នៅក្នុងភូមិភាគព្លសានហ្នឹង ថាតើមានស្រុកអ្វីខ្លះ លោកអ៊ំ?

**ឆ៖** កាលនោះចាត់តាំងបីស្រុក។ ស្រុក២១ ខ្ញុំ។ ស្រុក២២ ប៊ូខារ។ ស្រុក២៣ ប៉យ។ បីស្រុក។

**ស៖** អម្បាញ់មិញលោកអ៊ំបានជម្រាបជូនអង្គសវនាការពីស្រុកបី ដែលនៅក្នុងតំបន់១០១ មានស្រុក២១ ស្រុក២២ ហើយនិងស្រុក២៣ ហើយលោកអ៊ំបានជម្រាបថានៅក្នុងស្រុក២២ ហ្នឹង គឺដឹកនាំដោយ ប៊ូខារ។ ស្រុក២៣ ដឹកនាំដោយឈ្មោះ ប៉យ។ អ៊ីចឹងខ្ញុំចង់សួរលោកអ៊ំថា ស្រុក២១ តើអ្នកណាជាអ្នកដឹកនាំដែរ លោកអ៊ំ?

**ឆ៖** ខ្ញុំជាអនុប្រធាន អ្នកដឹកនាំ ធិន ឈ្មោះ ធិន។ ប្រធានតំបន់ផង ប្រធានស្រុកផង។ ដោយសារអីគេចាត់តាំងអ៊ីចឹង? ខ្ញុំចៀសវាងបីថ្ងៃ ខ្ញុំអត់ទទួលទេ ខ្ញុំអត់ចេះអក្សរ។ ខ្ញុំចេះភាសាឡាវ ភាសាខ្មែរ។ ខ្ញុំចៀសវាងមិនចង់ធ្វើបដិវត្តន៍ហ្នឹងហើយ គេបង្ខំ គេឲ្យអនុវត្ត នោះគេយក តាធិន ហ្នឹងប្រធានតំបន់ផង ប្រធានស្រុកផង។

**ស៖** អម្បាញ់មិញហ្នឹងលោកអ៊ំ បានមានប្រសាសន៍ពីប្រធានស្រុក២២ លោកអ៊ំប្រាប់ថា ដឹកនាំដោយឈ្មោះ ប៊ូខារ អ៊ីចឹងខ្ញុំចង់ជម្រាបសួរលោកអ៊ំថា លោកអ៊ំដឹងថាក្រោយមកមានអ្វីបានកើតឡើងចំពោះរូបបុគ្គលឈ្មោះ ប៊ូ ខារ ហ្នឹងដែរឬទេ លោកអ៊ំ ប្រធានស្រុក២២ហ្នឹង?

**ឆ៖** ខ្ញុំឮពីគេ ប្រធានតំបន់ប្រធានស្រុកហ្នឹងហើយ ធិន គាត់ប្រាប់គេចូលបដិវត្តន៍វៀតណាមទាក់ទងជាមួយយួនឲ្យអង្ករ ឲ្យមាន់ឲ្យអីហ្នឹង គេចាប់គាត់ហ្នឹង គេចាប់ ប៊ូ ខារ ហ្នឹង។ ប៊ូ ខារ ចិញ្ចឹមយួន នៅជាមួយគាត់ នៅឃុំគាត់នុ៎ង។ ខ្ញុំក្ដាប់ ធិន ប្រាប់ខ្ញុំ។ ខ្ញុំបានដឹង។

[១៤:១៥:៤២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមអភ័យទោស ខ្ញុំសូមកាត់ម្ដងទៀត។ ខ្ញុំហាក់ដូចជាឃើញថាចម្លើយដែលបានឆ្លើយតបនេះ វាមិនពាក់ព័ន្ធទៅនឹងដំណាក់កាល-- សវនាការផ្នែកទីមួយនោះទេ។ វាហាក់ដូចជាវាពាក់ព័ន្ធទៅនឹងការជម្លៀសទៅវិញ។

**ប្រធានអង្គជំនុំ៖**

មេធាវីបានកត់សម្គាល់ឃើញថាសមស្របហើយ ហើយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមបង្វែរអារម្មណ៍ និងសម្រិតសម្រាំងនូវសំណួរទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលយើងកំណត់យកមកធ្វើសវនាការដំណាក់កាលទីមួយនេះ ចៀសវាងឃ្លាតឆ្ងាយដែលជាការឥតប្រយោជន៍។

[១៤:១៦:៤៥]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណលោកប្រធាន ចំពោះការរំឭក ដោយសារគាត់បាននិយាយទាក់ទងជាមួយនឹងរចនាសម្ព័ន្ធ ហើយដល់ឈ្មោះហ្នឹងទៅ ដោយសារខ្ញុំមើលនៅក្នុងសំណុំរឿង ឃើញចម្លើយសាររបស់ឈ្មោះហ្នឹង។ អ៊ីចឹងទៅ ខ្ញុំគិតថាអ្វីដែលគាត់និយាយហ្នឹង គឺជាការពិត។ ខ្ញុំសូមបញ្ជាក់ម្តងទៀត អរគុណលោកប្រធាន ដែលលោកប្រធាន-- គេថាអត់មានការបកប្រែលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលពិនិត្យមើលការបកប្រែ អត់មានការបកប្រែជាភាសាបរទេសទេ។

**អ្នកបកប្រែ៖**

សូមអញ្ជើញលោកប្រធាន សូមអញ្ជើញបន្តបាទ!

**ប្រធានអង្គជំនុំ៖**

អ៎ ណោះ អញ្ជើញ!

[១៤:១៧:២៦]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស លោកប្រធាន ចំពោះការរំឭក ហើយនៅពេលដែលខ្ញុំសួរហ្នឹងដេញទៅ ដោយសារគាត់និយាយទាក់ទងជាមួយនឹងរចនាសម្ព័ន្ធភូមិភាគឦសាននៅក្នុងស្រុកហ្នឹង រួចហើយរាប់ៗ ដល់ឈ្មោះហ្នឹងទៅ ធ្វើឲ្យខ្ញុំនឹកឃើញថា នៅក្នុងសំណុំរឿងគឺយើងមារចម្លើយសារភាពរបស់បុគ្គលទាំងពីរនាក់ដែលមានឈ្មោះ ប៊ូ ខាវ ហើយនិង ប៉យ ហ្នឹង។ អ៊ីចឹង ខ្ញុំគិតថាសក្ខីកម្មរបស់គាត់គឺមានលក្ខណៈសមស្រប។ ចម្លើយសារភាពរបស់ ប៊ូ ខាវ ហ្នឹង គឺនៅក្នុងឯកសារ D175/3.77។ ហើយចម្លើយសារភាពរបស់ ប៉យ ហ្នឹង គឺមាននៅក្នុងឯកសារលេខ D155/5.43។ អរគុណលោកប្រធាន ហើយខ្ញុំនឹងបន្តទៅសំណួរបន្ទាប់។

[១៤:១៨:១២]

**ប្រធានអង្គជំនុំ៖**

វាមិនសំខាន់ថា ឯកសារហ្នឹងនៅក្នុងសំណុំរឿងនោះទេ។ សំខាន់ថាឯកសារហ្នឹង នៅក្នុងសំណុំរឿងហើយ ហើយឯកសារនុំងមានការពាក់ព័ន្ធផ្ទាល់មកអង្គហេតុទាំងឡាយ ដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការនៅដំណាក់កាលទីមួយ។ អ៊ីចឹង មិនមែនគ្រាន់តែអត្ថិភាពឯកសារនៅក្នុងសំណុំលើកត្រង់ណាក៏បាននោះទេ។ វាត្រូវតែជ្រើសរើសនូវភាពពាក់ព័ន្ធមកនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់នៅក្នុងកិច្ចដំណើរការសម្រាប់ធ្វើសវនាការទីមួយ។ នៅក្នុងនោះ គឺមានបញ្ជាក់ច្បាស់លាស់មូលដ្ឋានគឺជម្លៀសដំណាក់កាលទីមួយ និងទីពីរ។

**លោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន ហើយនៅក្នុងវិសាលភាពនៃសំណុំរឿងដំបូងហ្នឹង ក៏មាននិយាយទាក់ទងជាមួយនឹងរចនាសម្ព័ន្ធដែរ។ ចាស អរគុណ ខ្ញុំនឹងបន្តទៅក្នុងសំណួរបន្ទាប់ទៀត។

**ស៖** ខ្ញុំចង់សួរលោកអ៊ំថា នៅក្នុងពេលដែលលោកអ៊ំត្រូវគេតែងតាំងជា--

[១៤:១៩:១៦]

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

ដូច្នេះ ខ្ញុំសូមជំទាស់មួយទៀត គួរតែបង្គាប់ទៅលើការប្រើប្រាស់រយៈពេលវេលាផងដែរ។ ដូច្នេះហើយអ្វីដែលខ្ញុំស្ដាប់ឮគឺវាភាគច្រើន វាពាក់ព័ន្ធទៅនឹងអំឡុង៧៨, ៧៩។ ដូច្នេះហើយ ខ្ញុំគួរសុំឲ្យខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គួរតែសួរថា តើវាកើតឡើងនៅពេលណា? ចៀសវាងការសួរជាក់លាក់ទៅឆ្នាំ។ សូមអរគុណ។

[១៤:១៩:៤៨]

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយដូចអង្គជំនុំជម្រះបានជម្រាបភាគី និងសាធារណជនរួចហើយ ថានៅដំណាក់កាលនេះ អង្គជំនុំជម្រះមិនទាន់បានគិតថា តើសមស្រប នឹងបែងចែកពេលវេលាឲ្យភាគីយ៉ាងដូចម្ដេចទេ ដោយសារមូលហេតុការដឹង ការឮ ពាក់ព័ន្ធនឹងសំណុំរឿងនេះរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្ដី របស់សាក្សីក្ដី ឬរបស់អ្នកជំនាញក្ដី វាមានទំហំខុសគ្នា។ ការដែលយើងកំណត់នេះ គឺអង្គជំនុំជម្រះបានជម្រាបហើយ ទោះបីថាមិនទាន់កំណត់ក៏ដោយ ក៏ភាគីត្រូវកម្រិតនូវសំណួរឲ្យបានចំទៅនឹងបញ្ហាដែល

ជារបៀបវារៈនៃកិច្ចពិភាក្សា។

ទីពីរ អង្គជំនុំជម្រះបានជម្រាបផងដែលថា គឺអង្គជំនុំជម្រះទោះបីយ៉ាងដូច្នេះក៏ដោយ រក្សាសិទ្ធិថា ទៅថ្ងៃមុខនេះនឹងប្រឹងប្រែងរៀបចំការកំណត់នូវពេលវេលាឲ្យបានសមស្របបំផុត។

ដូច្នេះ សូមមេធាវីរំឭកឡើងវិញ ហើយអាចពិនិត្យមើលសាជាថ្មីម្តងទៀតនូវអ្វីដែលជាអនុស្សរណៈក្នុងការណែនាំ ក្នុងការអនុវត្តនៅក្នុងការដេញដោលនេះ ក៏ដូចជាពាក្យពេចន៍ផ្ទាល់មាត់ដែលប្រធានសវនាការ គឺរូបខ្ញុំបានណែនាំមុននឹងដេញដោល យើងបាននិយាយពាក្យនេះដូចច្រើនលើកហើយអម្បាញ់មិញនេះ។ សង្ឃឹមថាទាំងមេធាវី ទាំងភាគីផ្សេងទៀតនឹងប្រឹងប្រែង ដើម្បីអនុវត្តឲ្យបានត្រឹមត្រូវនូវរបៀបវារៈនូវអង្គហេតុដែលយើងបានកំណត់ធ្វើសវនាការ។ ហើយគឺធ្វើយ៉ាងម៉េចឲ្យចំបញ្ហា ចំអង្គហេតុទាំងអស់នេះ។ សូមអញ្ជើញ!

[១៤:២១:៤៥]

**សួរលោកស្រី ម៉ុច សុវណ្ណារី៖**

អរគុណលោកប្រធាន ខ្ញុំនឹងខំប្រឹងឲ្យអស់ពីសមត្ថភាព។

**ស៖** លោកអ៊ំ ខ្ញុំសូមជម្រាបសួរលោកអ៊ំទៀតថា តើអ្នកណាគេដែលបានតែងតាំងលោកអ៊ំឲ្យធ្វើអនុស្រុក២១ ហ្នឹង លោកអ៊ំ?

**ឆ៖** ហ្នឹងហើយគណៈចាត់តាំងហ្នឹងនៅបានលុង។ គណៈភូមិភាគហ្នឹង អ៊ំវង់. អ៊ំយ៉ា, អ៊ំខាន់--

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំសូមជំទាស់លោកប្រធាន។

*(គ្មានការបកប្រែ)*

[១៤:២២:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

មេធាវីអាចបន្តសំណួរទៀត ហើយសូមបញ្ជាក់បន្ថែមថាសំណួរច្រំដែល ក៏ដូចជាអង្គជំនុំជម្រះបានហាមឃាត់ដែរ។ អ៊ីចឹង ប្រយ័ត្ននូវសំណួរច្រំដែល។ ទីពីរ គឺការដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុទាំងឡាយរបស់មេធាវីរបស់ នួន ជា បានកាត់សម្គាល់ គឺប្រសិនជាអង្គហេតុនោះកើតឡើងនៅក្នុងអំឡុងឆ្នាំ៧៨-៧៩ ទេ ទំនងជាឆ្ងាយពីអង្គហេតុដែលយើងកំណត់សម្រាប់ធ្វើសវនាការនេះ។ ពីព្រោះ

សវនាការនេះកំណត់នៅក្នុងអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងដំណាក់កាលនៃជម្លៀសទីមួយ និងទីពីរ។ គឺជម្លៀសទីក្រុងភ្នំពេញ ហើយនិងជម្លៀសទីពីរ គឺបណ្តាខេត្តមួយចំនួន ពីភូមិភាគកណ្តាល ពីភូមិភាគនិរតីទៅកាន់ភូមិភាគពាយព្យ ហើយនិងភូមិភាគឧត្តរ។ នេះជាផែនការ អ៊ីចឹងរយៈពេលនេះគឺមិនចូលទៅដល់៧៨ ឬក៏៧៧-៧៨នោះទេ។ បើ៧៧-៧៨ គឺរឿងមួយទៀត ដែលជម្លោះទីបី គឺជម្លៀសភូមិភាគបូព៌ាដែលជាព្រឹត្តិការណ៍នៅភូមិភាគបូព៌ាដែលត្រូវជម្លៀសមកខាងលិចវិញ។ អ៊ីចឹង គឺមានរយៈពេលខុសគ្នា ហើយប្រសិនបើមានការពាក់ព័ន្ធនឹងបញ្ហានេះ សូមកំណត់សួរច្បាស់លាស់កាលបរិច្ឆេទនៃសំណួរផង ពីព្រោះបើសិនណា យើងប្រើសំណួរណាដែលហួសពីវិសាលភាពនៃអង្គហេតុដែលបានកំណត់សម្រាប់ធ្វើសវនាការលើកទីមួយនេះ វានឹងអាចនាំឱ្យមានកំហុសប្រាសចាក ហើយមានការតបជំទាស់។ បើសិនក្នុងរយៈពេលនៃការដេញដោល ប្រសិនបើទៅមុខទៀតភាគីជំទាស់តវ៉ាតែរបៀបនេះទៅ បានន័យយើងចំណាយពេលវេលាច្រើនណាស់ គ្រាន់តែដោះស្រាយនូវការជំទាស់។ អ៊ីចឹង ទាំងសងខាង ទីមួយអ្នកសួរ អ្នកទទួលភារកិច្ចដែលប្រធានអង្គជំនុំជម្រះបានចាត់តាំងឱ្យសួរត្រូវតែប្រឹងប្រែងដើម្បីសម្រិតសម្រាំងនូវសំណួរណាដែលសមស្រប ដែលខ្លី ដែលច្បាស់ ហើយនិងចំទៅនឹងអង្គហេតុ ហើយគួរតែត្រូវបានប្រឹងប្រែងសួរតាមលំដាប់លំដោយនៃអង្គហេតុ តាមលេខរៀងពីលេខតូចមកលេខធំនៃលំដាប់អង្គហេតុ ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ តាមកថាខណ្ឌនីមួយៗ។

សូមអញ្ជើញបន្តទៀត!

[១៤:២៦:០០]

**លោកស្រី ម៉ុច សុវណ្ណារី៖**

ខ្ញុំសូមអរគុណលោកប្រធាន តែបើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំសូមធ្វើការកត់សម្គាល់បន្តិច ខ្ញុំយល់ពីអ្វីដែលខាងលោកមេធាវីការពារក្តីរបស់លោក នួន ជា ហ្នឹង គាត់បានស្នើសុំទាក់ទងជាមួយនឹងឆ្នាំ។ ខ្ញុំរៀបនឹងសួរសំណួរទាក់ទងជាមួយនឹងឆ្នាំ ក៏ប៉ុន្តែដោយសារគាត់ចេះតែក្រោកជំទាស់ៗ អ៊ីចឹងអត់ទាន់ដឹងថា ខ្ញុំសួរទៅដល់សំណួរហ្នឹង គាត់បានលើកបញ្ហាហ្នឹងឡើង។ អ៊ីចឹង ធ្វើឱ្យមានការអាក់ខានច្រើននៅក្នុងការជំទាស់។ ហើយមួយទៀតទាក់ទងជាមួយនឹងវិសាលភាពនៃសំណុំរឿងដំណាក់កាលជំនុំជម្រះទីមួយនៅក្នុងសំណុំរឿងទីពីរនេះ។ ខ្ញុំគិតថា បើតាមធ្វើដែលខ្ញុំអានអនុស្សរណៈ ហើយនិងដីកាបំបែកសំណុំរឿង ដែលអង្គជំនុំជម្រះបានចេញមក ខ្ញុំគិតថាក្នុងការជំនុំជម្រះដំណាក់កាលទីមួយនៃសំណុំរឿងទីពីរនេះក៏មានរាប់បញ្ចូលផងដែរ ទាក់ទងជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលរបស់កម្ពុជាប្រជា

ធិបតេយ្យ ហើយនៅក្នុងរយៈពេលពីមុនឆ្នាំ១៩៧៥ ក៏ដូចជាក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យពីឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ ថ្ងៃ៦ មករា ឆ្នាំ៧៩។ អ៊ីចឹង ខ្ញុំគិតថា សំណួរដែលទាក់ទងជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាល គឺវាមិនកំណត់ថានៅក្នុងឆ្នាំ៧៧ ឬក៏៧៨ អីទេ គឺទោះបីជាវាកើតមានឡើងនៅក្នុងឆ្នាំ៧៧-៧៨ ក៏ដោយ ក៏វាទាក់ទងជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលដែលជាវិសាលភាពនៃការជំនុំជម្រះនៅក្នុងដំណាក់កាលនេះដែរ។

ហើយសំណួរដែលខ្ញុំនឹងសួរនេះជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងស្រុក២១ ដែលគាត់នឹងគ្រប់គ្រង។ បើសិនជាលោកប្រធានអនុញ្ញាត។

[១៤:២៧:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតហើយ អង្គជំនុំជម្រះអត់មានជំទាស់លើបញ្ហាហ្នឹងទេ គ្រាន់តែកត់សម្គាល់លើបញ្ហាមួយចំនួន ដើម្បីឲ្យទាំងភាគីទាំងសងខាងហ្នឹងគឺប្រមូលនូវបញ្ញាញាណ ដើម្បីរៀបចំការគិតគូរដើម្បីធ្វើម៉េចឲ្យមូលចំនឹងអង្គហេតុដែលអង្គជំនុំជម្រះបានកំណត់តែប៉ុណ្ណោះ។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

អរគុណលោកប្រធានចំពោះការគ្រប់គ្រងសវនាការដែលបានល្អបែបនេះ។

**ស៖** នាងខ្ញុំនឹងសួរសំណួរ១ជាថ្មីម្តងទៀត ពីព្រោះថាលោកអ៊ំ ក្លាន វ៉ុត គាត់មិនទាន់បានឆ្លើយនឹងសំណួររបស់ខ្ញុំទេ ថាតើអ្នកណាដែលបានតែងតាំងលោកអ៊ំឲ្យធ្វើជាអនុស្រុក២១?

**លោក ក្លាន វ៉ុត៖**

**ឆ៖** ខ្ញុំសុំឆ្លើយគណៈចាត់តាំងដូចខ្ញុំប្រាប់អំមិញហើយ ជាក់ស្តែង តាវី គណៈភូមិភាគ។ តាវី, តាខាត់, តាបុត, តាយ៉ា គាត់ប្រាំនាក់ហ្នឹងហើយ គណៈភូមិភាគគេចាត់តាំងហើយៗ ចាត់តាំងតំបន់ហើយ បានស្រុក។ ចាត់តាំងតំបន់ហ្នឹង តាធិន ប្រធាន។ អនុប្រធានដូច បងខាំភី ហ្នឹងហើយ រម៉ាមយុន ហ្នឹងហើយ។ ហើយចាត់តាំងតំបន់ហ្នឹងហើយ ចាត់តាំងស្រុកទៀត។ ស្រុក១បីស្រុកនៅក្នុងតំបន់១០១ហ្នឹង។ ស្រុក២១ ខ្ញុំ, ស្រុក២២ ប៊ូ ខាវ, ស្រុក២៣ ប៉យ។ ដល់ ប៊ូ ខាវ គេចាប់ហ្នឹងឲ្យ បៀន ទៀតជំនួសគាត់ទៀត។ គេចាប់ ប៊ូ ខាវ គេឲ្យ បៀន១ ឈ្មោះ បៀន។ គេធ្វើស្រុក២៣ទៀត-- ស្រុក២២ទៀត។ អាហ្នឹងច្បាស់។

**ស៖** អ៊ីចឹង ខ្ញុំសូមសួរអ៊ំបន្តទៀតថា តើពេលណាដែលគេបានតែងតាំងអ៊ំជាអនុស្រុក២១ ហ្នឹង នៅក្នុងឆ្នាំណាដែរ លោកអ៊ំ?

**ឆ៖** ១៩៧៦។

**ស៖** នៅពេលដែលគេតែងតាំងអ៊ំ តើគេតែងតាំងអ៊ំនៅក្នុងអំឡុងពេលណាដែរ តើគេតែងតាំងអ៊ំរបៀបម៉េចដែរ?

[១៤:២៩:៤១]

**ឆ៖** តែងតាំងហ្នឹង គេហៅទៅប្រជុំរៀន។ ប្រជុំ គេថា ឥឡូវយើងសព្វថ្ងៃហ្នឹង ប្រទេសឯករាជ្យហើយ អត់មានអ្នកគ្រប់គ្រង។ បើអត់មានអ្នកគ្រប់គ្រង អត់កើតទេ គ្រប់គ្រងប្រទេសជាតិ។ បើអ៊ីចឹង ឥឡូវជនជាតិកាចក់ ជនជាតិលាវ ជនជាតិខ្មែររៀងៗ ជនជាតិហ្នឹងឲ្យធ្វើ ធ្វើការងារ។ តំបន់ហ្នឹង ធិន ឈ្មោះ ធិន ជនជាតិដែរ ទំពួន ភូមិកាតាងនេះ។ អនុហ្នឹងបង ខាំភី មកជាមួយខ្ញុំនេះ ហើយចាត់តាំងតំបន់ហើយ គេចាត់តាំងពួកខ្ញុំបីនាក់ហ្នឹងធ្វើជាគណៈស្រុក។ បើយើងអត់ធ្វើ តើពីណាធ្វើការងារ ខ្មែរធ្វើរៀងៗខ្លួន លាវធ្វើរៀងៗខ្លួន កាចក់ ព្រៅ គ្រឹង ធ្វើខ្លួនឯង។ អត់ពីណាទៅធ្វើឲ្យទេ។ រៀងៗខ្លួន ឥឡូវយើងបានឯករាជ្យហើយ ជនជាតិណា ជនជាតិនោះ ជាគ្រប់គ្រងជនជាតិយើង មាតុភូមិយើង គេឃោសនាអ៊ីចឹង សូមអស់។

[១៤:៣០:៥៣]

**ស៖** ចាស អរគុណលោកអ៊ំ។ អ៊ីចឹងខ្ញុំសូមសួរសំណួរលោកអ៊ំទៀតថា នៅពេលដែលលោកអ៊ំធ្វើជាអនុស្រុក២១ ហ្នឹង តើលោកអ៊ំត្រូវបានគេចាត់តាំងឲ្យគ្រប់គ្រងលើប៉ុន្មានឃុំដែរលោកអ៊ំ?

**ឆ៖** ប្រាំមួយឃុំៗ។

**ស៖** តើលោកអ៊ំអាចជម្រាបជូនបានទេ ថាឃុំនោះមានឈ្មោះអ្វី? ហើយអ្នកណាគេខ្លះដែលគាត់ជាកម្មាភិបាលដែលទទួលបន្ទុកឃុំនីមួយដែលនៅក្រោមការគ្រប់គ្រងរបស់លោកអ៊ំហ្នឹង?

**ឆ៖** ស្តាប់បានម៉េច ខ្លួនឯងគ្រប់គ្រង់ម៉េចដឹង គ្រប់ប្រធានៗឃុំ។ មួយឃុំបីនាក់ៗ គេចាត់តាំង។

**ស៖** ចាស អ៊ីចឹងលោកអ៊ំអាចរៀបរាប់ឈ្មោះឃុំដែលលោកអ៊ំបានគ្រប់គ្រងនៅពេលហ្នឹងបានទេលោកអ៊ំនៅពេលប្រាំមួយឃុំហ្នឹង?

**ឆ៖** បានៗ បានគ្រប់ឃុំ។ ប្រាំមួយឃុំ ក្តាប់បានទាំងអស់។ ខ្ញុំក្តាប់បានទាំងឈ្មោះ។

**ស៖** ចាស សូមអ៊ំប្រាប់ខាងអង្គសវនាការទៅថា ឃុំហ្នឹងឈ្មោះអីខ្លះអ៊ំ?

**ធ៖** ឃុំខ្ញុំនៅផ្ទាល់ហ្នឹងឃុំ២១។ ឃុំម-១ ឥឡូវគេហៅថា ឃុំតាឡាវ អង្កាល់កុម្មុយនីស្តហ្នឹង គេហៅថាឃុំម១។ ឃុំហ្នឹងហើយខ្ញុំនៅ។ ពេល-- ហើយឃុំម១ ខ្ញុំ។ ឃុំម-២ ឃុំម-៣ ម-៤ ម-៥ ម-៦ ប្រាំមួយឃុំ។ បើថាឲ្យដឹងឈ្មោះ ខ្ញុំដឹងអស់ដែរឈ្មោះអ្នកគ្រប់គ្រងឃុំពីរនាក់បីនាក់។

**ស៖** អ៊ីចឹងតើលោកអ៊ំអាចប្រាប់ឈ្មោះអ្នកដែលទទួលខុសត្រូវឃុំនីមួយៗហ្នឹងបានទេលោកអ៊ំ?

**ធ៖** បាទ, បាន។ ខ្ញុំប្រាប់ នៅឃុំមមួយខ្ញុំ ឈឺន, ពាស បីនាក់ ឃុំម-១។

[១៤:៣៣:១៤]

**ស៖** ចុះឃុំម-២ លោកអ៊ំ?

**ធ៖** ជីន, គួន, គ្លីក បីនាក់។

**ស៖** ចុះឃុំមបី?

**ធ៖** **ម-៣,** យុង ប៉ែន ធឹង បីនាក់។

**ស៖** ចុះម-៥-- ម-៤?

**ធ៖** (ឮមិនច្បាស់)បីនាក់។

**ស៖** ចុះម-៥?

**ធ៖** មើញ គ្លីត ថាង បីនាក់ហ្នឹង។

**ស៖** ចុះម-៦?

**ធ៖** ម-៦នេះ (ឮមិនច្បាស់)

**ស៖** ចាស អ៊ីចឹង--

**ធ៖** ម-៦នេះ ចឹង អឺ! ភ្លេចហើយពួកពីរនាក់ហ្នឹងភ្លេចហើយ។ ចំណាំតែប្រធានវាហ្នឹង ចឹងៗ

**អ្នកបកប្រែ៖**

លោកអ៊ំប្រធាន អ្នកបកប្រែបកប្រែមិនទាន់ទេទាន ដោយសារមីក្រូរបស់សាក្សី-- របស់ដើមបណ្ដឹងរដ្ឋប្បវេណីបានបាត់តាំងពីសំណួរទាក់ទងជាមួយ ម-៣ ។ សូមឲ្យសាដើមពីហ្នឹងមកវិញទាន។

[១៤:៣៤:៣៩]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីចាំក្បាលមីក្រូហ្នឹងមានភ្លើងពណ៌ក្រហម សឹមនិយាយ ចាប់ផ្ដើមនិយាយ បើពុំដូច្នោះទេ អត់-- អ្នកបកប្រែអត់ស្ដាប់បានទេ។ អត់បានបកប្រែទេ ហើយអាចសម្រួលបន្ថែមទៀត

នឹងរវាងមន្ត្រីដែលអង្គុយជិតគាត់ហ្នឹងអាចសម្រួលជួយចុចគាត់បានទេ? ដើម្បីឲ្យកាលដែលគាត់ប្រាកដថា មានភ្លើងក្រហម ហើយនឹងអាចនិយាយ។ ឬក៏រំឭកគាត់ដើម្បីគាត់និយាយចាប់ដល់ពេលក្បាលមីក្រូមានភ្លើងក្រហមសិមនិយាយណា។ ឥឡូវនេះ គឺសំណូមពររបស់ខាងអ្នកបកប្រែភាសាសូមឲ្យតាំងសំណួរជាថ្មីឡើងវិញអាចបកប្រែបានត្រឹមតែ ម-៣ ប៉ុណ្ណោះ។ អ៊ីចឹងចាប់ពីម-៤ គឺមិនទាន់បានបកប្រែមិនទាន់ទេ ដោយសារគាត់និយាយមិនបើកក្បាលមីក្រូហ្វូន។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

ចាស់អរគុណលោកប្រធាន អ៊ីចឹងនាងខ្ញុំនឹងចាប់ផ្ដើមសួរសំណួរឡើងវិញទាក់ទាក់នឹងអ្នកទទួលខុសត្រូវនៅក្នុង ម-៣។

**ស៖** អ៊ីចឹងសូមលោកអ៊ំប្រាប់ឈ្មោះអ្នកដែលទទួលខុសត្រូវនៅក្នុងឃុំម-៣។

**ឆ៖** ឃុំម-៣ មួយ យុង។ ពីរ ដែន បី ធឹង បីនាក់។

**ស៖** អ៊ីចឹងសូមអ៊ំបន្តទៅដល់ ម-៤ តើអ្នកណាជាអ្នកគ្រប់គ្រង?

**ឆ៖** ខ្ញុំឆ្លើយ ម-៤ ចេង, ព្លឹង, ធ្វីន បីនាក់។

**ស៖** ចាស សូមអ៊ំបន្តទៅ ម-៥?

**ឆ៖** ណើញ, គ្លីត ម្នាក់ខ្ញុំភ្លេចឆ្លើយម្នាក់ ស្គាល់តែស្លាប់បាត់ហើយ។

**ស៖** ចាស់, អ៊ីចឹងសូមអ៊ំបន្តដល់ម-៦?

**ឆ៖** ម-៦ ខ្ញុំចំណាំៗពីរនាក់ ជើង, ហេន ម្នាក់ខ្ញុំភ្លេច គាត់ស្លាប់។ អស់។

[១៤:៣៧:២៣]

**ស៖** ចាស, សូមអរគុណលោកអ៊ំ អ៊ីចឹងខ្ញុំបន្តទៅសំណួរបន្ទាប់មកទៀត។ ខ្ញុំចង់សួរលោកអ៊ំថា នៅក្នុងតួនាទីលោកអ៊ំជាអនុស្រុក២១ តើអ្នកដឹកអង្គការលើហ្នឹងគេបានតម្រូវឲ្យអ៊ំធ្វើការងារអ្វីខ្លះ?

**ឆ៖** ធ្វើការងារអីមានតែអប់រំៗប្រជាជនធ្វើស្រែចម្ការ។ ទីពីរ កុំឲ្យចេញចូលប្រទេសយួនអាហ្នឹងគេឃោសនាខ្ញុំ។ សូមអស់។

**ស៖** អ៊ីចឹង តើអ៊ំអាចជម្រាបអង្គសវនាការបានទេថា ដោយអ៊ំមានតួនាទីអប់រំប្រជាជនឲ្យខំធ្វើពលកម្មកុំឲ្យចូលខាំងយួនអីហ្នឹង។ ថាតើអ៊ំចុះទៅអប់រំគេតាមមធ្យោបាយមួយណា? តាមវិធីណាដែរដែលអ៊ំទៅអប់រំគេហ្នឹងលោកអ៊ំ?

**ឆ៖** ខ្ញុំមានអ្នកកាន់ឯកសារ អ្នកជួយខ្ញុំ។ ដូចថាមានស្មៀន គេមានឯកសារគេអាន ប៉ុន្តែខ្ញុំអត់

ចេះអក្សរ មានស្នៀន គាត់កត់ត្រា គាត់អានឯកសារ។

[១៤:៣៨:៤០]

**ស៖** អ៊ីចឹងនៅពេលដែលមានបញ្ហាពីលើ ពីអង្គការលើមកគេបញ្ជាថា នៅក្នុងស្រុកប្រជាជនត្រូវធ្វើការនេះៗ។ អ៊ីចឹងខ្ញុំចង់សូមជម្រាបសួរលោកអ៊ំថា តើលោកអ៊ំត្រូវផ្ដល់ព័ត៌មានទាំងអស់ហ្នឹងបញ្ហាដែលគេបញ្ជាពីលើមកហ្នឹងទៅដល់ប្រជាជននៅក្នុងស្រុកដោយអ៊ំគ្រប់គ្រងហ្នឹងដោយរបៀបណា? តាមវិធីណាដែរលោកអ៊ំ?

**ឆ៖** កាលនោះ ខ្ញុំធ្វើអនុស្រុកនោះពិបាកណាស់។ ពិបាកអី ដល់ឆ្នាំ៧៦ គេចាត់តាំងខ្ញុំធ្វើអនុស្រុកហ្នឹង គេប្រមូលដី ប្រមូលមនុស្សរើភូមិ។ ដីភូមិនៅមួយកន្លែងមានដីធ្វើស្រែ អានេះគេចាប់បង្ខំបើមិនរើភូមិនុ៎ង-- មុននឹងរើភូមិគេរកដីសិន រកដីធ្វើស្រែ កន្លែងនេះវាមានល្វឹងល្វើយដី។ អាហ្នឹងគេដកភូមិពីចំណាយពីស្រែពីវាលហ្នឹងទៅនៅ ឧទាហរណ៍ភូមិកាក់ ភូមិតាណង ទៅរើភូមិទៅនៅជាមួយភូមិអ៊ុន។ ភូមិអ៊ុន ហ្នឹងហេតុអីគេប្រមូល ដីភូមិអ៊ុនហ្នឹងវាមានដីស្រែល្វឹងល្វើយ។ កាលហ្នឹងខ្ញុំអប់រំស្មុគស្មាញណាស់ ខ្ញុំចង់ចងកខ្លួនឯង អង្គការធ្វើឲ្យខ្ញុំពិបាក។ ពិបាកយ៉ាងម៉េច? ប្រជាជនគេធ្លាប់ធ្វើស្រែ ប្រជាជនមិនចង់បានរើភូមិ ភូមិគេស្រេចហើយមិនដឹងប៉ុន្មានរយឆ្នាំហើយ ឲ្យរើភូមិ អាហ្នឹងធ្វើឲ្យស្មុគស្មាញ។ ខ្ញុំប៉ិះចងកខ្លួនឯង។ គិតទៅគិតមកនឹកកូន នឹកប្រពន្ធ នឹកម៉ែ អាហ្នឹងខ្ញុំអត់បានចងក ខំធ្វើអ៊ីចឹង ទ្រាំធ្វើអ៊ីចឹង។ បើធ្វើអ៊ីចឹងគេមកទាំងអស់ ពីរភូមិនៅមួយកន្លែងភូមិអ៊ុន។ ខ្ញុំនៅធ្វើឃុំ-- អនុស្រុកអប់រំគេអ៊ីចឹង បងប្អូនបើយើងមិនធ្វើផ្លូវណាយើងទៅ យើងខ្លាចងាប់ បើយើងមិនទៅតាមមាគ៌ារបស់បក្សគេកាប់ចោលយើងអស់រលីងហើយ ខ្ញុំថាខំធ្វើគេថា។ គេធ្វើហ្នឹងឲ្យយើងធ្វើទៅមុខ ធ្វើអាង ធ្វើប្រឡាយ ដើម្បីមានទឹកធ្វើស្រែនេះហើយ កុំដីវាសល់មនុស្សច្រើន។ អាហ្នឹងខ្ញុំអប់រំប្រជាជនណា។

សូមអស់។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ក្លាន វ៉ិត ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត។ មុននឹងផ្តល់វេទិកាទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្រើពេលវេលាឲ្យបានមានប្រសិទ្ធភាពនៅក្នុងការសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ អង្គជំនុំជម្រះសួរថា តើដើមបណ្តឹងរដ្ឋប្បវេណីត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការសួរសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ?

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន នៅតែពីរចំណុចទៀតទេ ដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចង់លើកជាសំណួរ ហើយរយៈពេលប្រហែល១០នាទីយ៉ាងច្រើន។ សូមអរគុណ។

[១៥:០៣:៣៣]

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គជំនុំជម្រះសូមប្រគល់វេទិកាជូនទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញបន្តសំណួរ។

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

សូមអរគុណលោកប្រធាន។

**ស៖** លោកអ៊ំ ខ្ញុំមានតែពីរសំណួរទៀតទេ ចង់សួរលោកអ៊ំ។ អ៊ីចឹងអម្បាញ់មិញទាក់ទងជាមួយនឹងរបៀបនៃការដែលលោកអ៊ំទាក់ទងការងារជាមួយនឹងមេឃុំទាំងប្រាំ ដែលលោកអ៊ំគ្រប់គ្រង។ អ៊ីចឹងខ្ញុំចង់សួរលោកអ៊ំថា តើគេមានតម្រូវពីលើមកថា លោកអ៊ំត្រូវតែកំណត់ការប្រជុំជាមួយនឹងមេឃុំហ្នឹងទៀងទាត់ប៉ុន្មានដងៗដែរទេ លោកអ៊ំ?

[១៥:០៤:១១]

**លោក ក្លាន រ៉ិត៖**

**ឆ៖** បាទ, មានមួយខែពីរដង។

**សៈ** អ៊ីចឹងលោកអ៊ំអាចជម្រាបជូនអង្គសវនាការបានទេថា នៅពេលដែល តើមានតម្រូវថា លោកអ៊ំត្រូវតែរាយការណ៍ពីស្ថានភាពនៅក្នុងតំបន់ដែលលោកអ៊ំគ្រប់គ្រង ស្រុកដែលលោកអ៊ំគ្រប់គ្រង ហ្នឹងទៅខាងលើដែរឬទេ? ហើយបើសិនជាមានថាត្រូវរាយការណ៍ តើរបៀបនៃការដែលគេរាយការណ៍ទៅថ្នាក់លើ ក៏ដូចជាបញ្ជូនព័ត៌មានទៅខាងក្រោមហ្នឹង ថាតើវារាយការណ៍តាមរបៀបណា? តាមរយៈអ្វីដែរ លោកអ៊ំ?

[១៥:០៤:៥២]

**ឆៈ** សុំឆ្លើយ ក្នុងការរាយការណ៍ឲ្យគណៈតំបន់ហ្នឹង បើមានពេលកាលហើយ ប្រជុំហើយ ត្រូវរាយការណ៍ឲ្យគេដឹង អ៊ីចេះៗ ដើម្បីអី ដើម្បីគេក្តាប់ខ្លាចខ្ញុំ គេចោទខ្ញុំមនុស្សចូលបក្សសម្ព័ន្ធវៀត-ណាម។ គ្រាន់តែចោទអ៊ីចឹងហើយ ហេតុអី ហេតុតាំងពីមុនខ្ញុំធ្លាប់នៅទាក់ទងជាមួយវៀតណាម ដោយសារគេផ្អែកខ្ញុំលើព្រំដែន។ អាហ្នឹងគេនៅសង្ស័យ។ បើប្រជុំហើយ មិនរាយការណ៍ឲ្យគេដឹង គេថាខ្ញុំប្រជុំដើម្បីនាំប្រជាជនរត់ទៅវៀតណាម អ៊ីចឹង។

**សៈ** ចាស, អរគុណលោកអ៊ំ ខ្ញុំអស់សំណួរហើយ តែជាចុងបញ្ចប់នេះ បើសិនជាលោកអ៊ំមាន តើលោកអ៊ំមានអ្វីថ្លែងទៅសវនាការជាលើកចុងក្រោយទេ ទាក់ទងជាមួយទុក្ខវេទនារបស់លោកអ៊ំ ក៏ដូចជាភាពស្មុគស្មាញដែលលោកអ៊ំមាន នៅក្នុងសម័យនោះលោកអ៊ំ។ បើលោកអ៊ំមាន សូមលោកអ៊ំជម្រាបទៅអង្គសវនាការនៅពេលនេះ។ ខ្ញុំអស់សំណួរសួរលោកអ៊ំហើយ។

**ឆៈ** មានការស្មុគស្មាញ គឺថាធ្វើបដិវត្តន៍កុម្មុយនីស្ត ពិបាកដោយសារនោះហើយ មនុស្សវាងាប់ច្រើន។ មិនដឹងខុស មិនដឹងត្រូវ ប្រជារាស្ត្រដែលកាប់វាយចោល កម្មាភិបាលធំៗ តំបន់ ស្រុក ភូមិភាគ ដូចអ៊ំយ៉ា អ៊ំអីហ្នឹង សុទ្ធតែគណៈភូមិភាគគេវាយចោលដែរ មិនដឹងគេវាយចោលរឿងអី អាហ្នឹងហើយខ្ញុំស្មុគស្មាញ អង្កាល់ណោះ។ ក្រោយពីគេ ថាចាត់តាំងស្រុកឲ្យនោះ វាស្មុគស្មាញ។ ដល់សព្វថ្ងៃខ្ញុំបានសប្បាយចិត្ត គឺថាវាហួសពេលហើយ បក្សកុម្មុយនីស្ត កាលដែលបដិវត្តន៍កុម្មុយនីស្តគេហ្នឹង។ ចប់ត្រឹមហ្នឹង។

[១៥:០៦:៤៦]

**លោកស្រី ម៉ុច សុវណ្ណារីៈ**

អរគុណលោកអ៊ំ ក្លាន វ៉ិត ចំពោះការចូលរួមរបស់លោកអ៊ំនៅក្នុងសវនាការ ហើយជាពិសេសការឆ្លើយនឹងសំណួររបស់ខ្ញុំ ហើយខ្ញុំសូមអរគុណអង្គជំនុំជម្រះដែលបានផ្តល់ពេលវេលាឲ្យខ្ញុំនៅក្នុងការ

សំណួរនេះ។ ហើយខ្ញុំសូមជម្រាបជូនទៅអង្គជំនុំជម្រះថា ពីខាងភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនមានសំណួរដើម្បីសួរទៅអ៊ំ ក្លាន រ៉ិត បន្តទៀតទេ។ សំណួរត្រូវបានបញ្ចប់នៅពេលនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

ជាកិច្ចបន្ត អង្គជំនុំជម្រះប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ប្រសិនបើមានសំណួរត្រូវសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៥:០៧:៣៤]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រមទាំងអស់។ ថ្ងៃនេះខ្ញុំនឹងចាប់ផ្តើមសួរសំណួរ ហើយប្រសិនបើខ្ញុំមិនបានបញ្ចប់សំណួរទេ សូមឲ្យសហសេវិករបស់ខ្ញុំបន្តទៅថ្ងៃស្អែកទៀត បាទ សូមអនុញ្ញាត។

សូមគោរពលោក ក្លាន រ៉ិត! សូមអរគុណដែលលោកបានធ្វើដំណើរពីចម្ងាយមកដល់ទីនេះ ហើយដើម្បីមកធ្វើសក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីនេះ។ យើងនឹងសួរសំណួរមួយចំនួនទៅកាន់លោក ហើយយើងដឹងថា ភាសាខ្មែរមិនមែនជាភាសាកំណើតរបស់លោកទេ ប៉ុន្តែគឺជាភាសាមួយក្នុងចំណោមភាសាជាច្រើន ដែលលោកនិយាយដូច្នេះ យើងនឹងព្យាយាមសួរសំណួរខ្លីៗ សាមញ្ញងាយយល់តាមដែលធ្វើទៅបាន។ ខ្ញុំចង់រំឭកថា ប្រសិនបើលោកមានការលំបាកក្នុងការយល់នូវសំណួរដែលខ្ញុំសួរនោះ សូមមេត្តាលើកដៃឡើង ហើយនិងប្រាប់ខ្ញុំមក ខ្ញុំនឹងអាចសួរឡើងវិញនូវសំណួរទាំងនោះបាន។

ហើយយើងដឹងហើយថា រឿងហេតុនោះបានកើតឡើងតាំងពី៣០ឆ្នាំជាងមុននោះ ដូច្នេះលោកប្រហែលជាមិនអាចរំឭកបានច្បាស់លាស់អំពីអ្វីដែលបានកើតឡើងនោះទេ។ ដូច្នេះ ខ្ញុំសូមឲ្យលោកផ្តល់អារម្មណ៍ឲ្យបានតាមលទ្ធភាពដែលអាចធ្វើទៅបាន ទៅលើសំណួរដែលខ្ញុំនឹងចោទសួរ ហើយសូមឲ្យឆ្លើយឲ្យបានច្បាស់លាស់បំផុតតាមដែលអាចធ្វើទៅបាន។

**ស៖** ជាបឋម ខ្ញុំចង់សួរលោកថា តើកាលពីពីរឆ្នាំកន្លះមុននេះ គឺពីឆ្នាំ២០០៩ គឺអ្នកអង្កេតការណ៍របស់តុលាការបានទៅជួបលោក ហើយបានសួរសំណួរទៅកាន់លោក។ តើវាជាការពិតទេ?

**លោក ក្លាន វិត៖**

**ឆ៖** បាទ, ពិត។

**ស៖** តើលោកបានរំឭកថា លោកបានឆ្លើយតបថា គេសួរជាភាសាខ្មែរ ឬក៏បានបកប្រែជាភាសាខ្មែរ តាមរយៈអ្នកបកប្រែ?

**ឆ៖** ខ្ញុំនិយាយតាមលទ្ធភាព និយាយខ្មែរហ្នឹងហើយ។ តាមពិតបកប្រែខ្មែរ។ ខ្ញុំអត់បាននិយាយជនជាតិ ព្រោះភាសាខ្លួនឯង កាចក់ទេ។ ខ្ញុំបាននិយាយត្រឹមណា ចេះត្រឹមណានិយាយត្រឹមហ្នឹង។ គេមកក្តាប់សភាពការណ៍នុ៎ង។ សូមអស់។

**ស៖** បាទ, សូមអរគុណ។ តើនៅពេលចប់ការសួរនោះ តើគេបានអានឲ្យលោកស្តាប់ឡើងវិញទេនូវកំណត់ហេតុនោះ?

**ឆ៖** បាទ, គេអានឲ្យស្តាប់ដែរ។

**ស៖** ហើយនៅពេលដែលគេអានឲ្យលោកស្តាប់ហើយ តើលោកបានគិតថាត្រូវ ហើយលោកបានចុះហត្ថលេខា ឬក៏បានផ្តិតមេដៃនៅលើឯកសារនោះ ថាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, បានផ្តិត។

**ស៖** ចំពោះឯកសារD247/1 បាទ ខ្ញុំសូមសូត្រលេខ ERN ជាភាសាខ្មែរគឺ 00040357 រហូតដល់ 004064 ហើយភាសា សំណៅជាភាសាបារាំងជាសំណៅកែប្រែ គឺD247/1 correct គឺទំព័រ 0071325 គឺរហូតដល់ 007139 ហើយជាភាសាអង់គ្លេស 0040460 រហូតទៅដល់ 0040467។ ដូច្នេះយើងនឹងយោងទៅលើ ឯកសារនេះនៅក្នុងសំណួររបស់យើងមួយចំនួន ដោយថាមិនសួរជាសំណួរនាំមុខទេ។

[១៥:១២:០១]

ខ្ញុំចង់ត្រឡប់មកនិយាយអំពីរយៈដែលលោកបានចូលរួមនៅក្នុងសម័យនោះ រហូតទៅដល់ឆ្នាំ១៩៧០។ ហើយកាលពីព្រឹកមិញនេះ លោកបាននិយាយថា មិនបានចងចាំឲ្យច្បាស់ទេពីឆ្នាំដែលលោកបានចូលរួមនៅក្នុងចលនានេះនោះ។ តើលោកអាចបញ្ជាក់ឲ្យច្បាស់ទេថា តើនៅក្នុងសម័យកាលណាមួយដែរ ដែលលោកបានចូលរួមនៅក្នុងចលនានោះក្នុងឆ្នាំ៥០ ឬក៏ទសវត្សរ៍ឆ្នាំ៦០ ឬក៏មុននឹងឆ្ងាយទៀត? មុនរដ្ឋប្រហារ លន់ នល់?

**ឆ៖** ខ្ញុំសូមឆ្លើយ កាលចូលបដិវត្តន៍ប្រជាជាតិហ្នឹងឆ្នាំ៦១។

**ស៖** ពីព្រឹកមិញ គឺលោកបាននិយាយអំពីរឿងហេតុដែលកើតឡើងមុនរដ្ឋប្រហារ គឺខ្ញុំបានស្ដាប់ឮឆ្នាំ៧១ គឺខ្ញុំចង់បញ្ជាក់ថា តើជាឆ្នាំ៧១មែន ឬក៏មុនឆ្នាំ៧១ នេះ?

**ឆ៖** មុនឆ្នាំ៧១។

[១៥:១៣:៣១]

**ស៖** កាលពីព្រឹកមិញនេះ លោកបាននិយាយថាមានឥស្សរជនមួយចំនួនបានមករកលោកដើម្បីឲ្យចូលរួមនៅក្នុងចលនា។ តើអស់លោកទាំងអស់នោះបាននិយាយអំពីទស្សនៈអំពីខ្មាំង ដើម្បីជំរុញឬក៏បញ្ចុះបញ្ចូលឲ្យលោកចូលរួមនៅក្នុងបដិវត្តន៍ដែរឬទេ?

**ឆ៖** មិនមានខ្មាំងទេ ដោយសារពួកអ៊ំៗហ្នឹងហើយ អប់រំឲ្យចូលធ្វើបដិវត្តន៍ ពួកអ៊ំ អៀង សារី អ៊ំរី, អ៊ំយ៉ា ពួកគាត់ទាំងអស់អប់រំខ្ញុំ កាលពីនៅព្រៃ ពីដើម។

**ស៖** សូមអរគុណ។ តើចំពោះលោកខ្លួនឯងផ្ទាល់នោះ លោកដឹងអំពីវត្ថុបំណងនៃចលនាបដិវត្តន៍ហ្នឹងដែរឬទេ?

**ឆ៖** អត់ដឹងទេ។ គេថាបដិវត្តន៍ បដិវត្តន៍តាមគេ។ គេឲ្យចិញ្ចឹមជ្រូកៗ គេឲ្យជម្រះចម្ការៗ គេឲ្យ ធ្វើផ្ទះៗ មានតែប៉ុណ្ណឹង។ អត់ដឹងគាត់ដឹកនាំបដិវត្តន៍យ៉ាងម៉េច បើគាត់ថ្ងៃក្រោយទៅអត់ដឹងទេ។ ចេះតែធ្វើដោយខ្លាច អត់យល់ អត់ចេះអក្សរ អត់ចេះឯកសារ ចេះតែ-- បើមិនទៅខ្លាចគេកាប់សម្លាប់ចោល មានតែប៉ុណ្ណឹង។ តាំងពីមុនដំបូងនោះ នៅមិនទាន់មានភារកិច្ច វាយការណ៍ស្មោះត្រង់។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

សូមលោកប្រធាន ដោយសារដាច់ភ្លើង ឬក៏ខ្ញុំអាចបន្ត ឬក៏ខ្ញុំត្រូវរង់ចាំឲ្យភ្លើងឆេះវិញសិន?

សូមអរគុណ លោកប្រធាន។

**ស៖** សំណួរ--

**លោក ម៉ៃខល កាណាវាស៖**

ជំទាស់រយៈពេលរយៈពេលប្រាំនាទី តើយើងកំពុងតែនិយាយអំពីទសវត្សរ៍ទី៦០ ឬក៏យ៉ាងម៉េចនៅពេលដែលចូលរួមចលនាបដិវត្តន៍ ហើយគាត់បានថា បើមិនចូលគេអាចសម្លាប់ដោយអ្នកណា?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោក កាណាវាស គឺខ្ញុំជាអ្នកសួរសំណួរនៅពេលនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំមិនដឹងថា ខ្ញុំត្រូវសួរសំណួរឡើងវិញ ឬក៏យ៉ាងម៉េច? ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់អាចបញ្ជាក់បានថាដោយសារអ្នកណាដែលលោកមានអារម្មណ៍ថាលោកត្រូវបានការគំរាមកំហែងនេះ?

**លោក ក្លាន រ៉ុត៖**

**ឆ៖** ខ្ញុំឆ្លើយ ដោយសារអី? ដោយសារ គឺថាគេអង្គការ។ ការងារស្ទីវាធំជាងអង្គការទៀត? អង្គការបដិវត្តន៍។ បើមិនធ្វើចៀសវាងនៅកន្លែងណា? នៅជាមួយត្រីក្នុងទឹកនៅអត់បាន។ ហើរលើមេឃក៏អត់មាន អត់ចេះហើរលើមេឃ ចេះតែធ្វើហ្នឹងហើយ។ គេប្រាប់ ដោយសារគេប្រាប់អ៊ីចឹងហើយខ្ញុំខ្លាច ខ្ញុំធ្វើតាមគេ។ អស់។

**ស៖** តើលោកដឹងថាចលនាបដិវត្តន៍នេះ មានឈ្មោះដែរឬទេ តើចលនាបដិវត្តន៍ហ្នឹងឈ្មោះៗអី? ឬក៏បក្សហ្នឹងឈ្មោះអី?

**ឆ៖** ឈ្មោះហ្នឹងដូចខ្ញុំថា មុនដំបូងហ្នឹង ថង ស៊ី, អ៊ំវង់, អ៊ំយ៉ា, តាខាត់, ហើយនិងគណៈភូមិភាគគេ។ ថងស៊ី ហ្នឹង គណៈស្រុកនៅវ៉ឺនសៃ។

[១៥:១៧:១៣]

**ស៖** សំណួរថា តើចលនាហ្នឹងមានឈ្មោះអី? ហើយគេហៅចលនាហ្នឹង ជាចលនាអីដែរ?

**ឆ៖** ចលនាអី ដើម្បីសកម្មដឹកនាំប្រជាជនធ្វើស្រែ ធ្វើចម្ការ កុំឲ្យងាករេទៅខាងនេះៗនោះៗជាក់ស្តែងខ្លាចយើងចូលខ្មាំង។ អាហ្នឹងសំខាន់ គេឃោសនា។

**ស៖** នៅពេលដែលលោកចូលក្នុងចលនាហ្នឹង តើគេមានបានអប់រំលោកទេ ឬក៏បណ្តុះបណ្តាលលោកស្អីខ្លះទេ?

**ឆ៖** អប់រំៗនយោបាយ។ គេអប់រំនយោបាយ។ ដល់ក្រោយទៀត គេបណ្តុះបណ្តាលឲ្យរៀនសូត្រម្តងពីរដង ប៉ុណ្ណឹង។

**ស៖** បើតាមលោកដឹង តើអ្នកផ្សេងទៀតនៅក្នុងភូមិរបស់លោកនុ៎ង ដែលបានចូលរួមនៅក្នុងចលនាបដិវត្តន៍ហ្នឹង ហើយតើអ្នកទាំងអស់ហ្នឹង ជាជនជាតិភាគតិចដែរ ឬក៏យ៉ាងណា?

**ឆ៖** ជនជាតិដើមភាគតិចដែរ។ទាំងអស់ក្នុងប្រាំមួយឃុំសុទ្ធតែជនជាតិដើមភាគតិចទាំងអស់។

**ស៖** តើលោកដឹងទេថា មូលហេតុអ្វីដែរ បានចលនាបដិវត្តន៍ហ្នឹង គាត់ព្យាយាម ឬក៏មានគោលដៅជ្រើសរើសយកជនជាតិភាគតិចនៅក្នុងតំបន់ព្លៃសានហ្នឹង?

**ធ៖** ដោយសារគេក្តាប់ខាងនោះ វាល្ងង់ល្ងិត អត់ដឹងថាខ្លាំង អត់ដឹងថាបដិវត្តន៍ អាហ្នឹងគេយកឯកសារអប់រំឲ្យដឹងរបៀបបដិវត្តន៍អ៊ីចេះៗ របៀបខ្លាំងអ៊ីចុះៗ។

**សៈ** គឺក្នុងទសវត្សរ៍ឆ្នាំ៦០ ដដែលហ្នឹង ហើយនិងមុនរដ្ឋប្រហាររបស់ លន់ នល់ តើលោកអាចបាននិយាយ អាចប្រាប់យើងទេថា តើមេដឹកនាំចលនាបដិវត្តន៍ហ្នឹងនៅឯណាដែរ? តើពួកគាត់ហ្នឹងរស់នៅឯណា កន្លែងស្នាក់នៅរបស់ពួកគាត់?

**ធ៖** កាលនោះមានតែអ៊ំ ថងស៊ី, អ៊ំវ៉ង់, អ៊ំយ៉ាហ្នឹងហើយអប់រំ អង្គាល់នុំងគណៈភូមិភាគដដែលគណៈស្រុកដដែលហ្នឹងហើយ អត់មានពីណាទេប្រាប់។

**សៈ** តើក្នុងរយៈពេលហ្នឹង តើលោកមានបានឆ្លងកាត់ព្រំដែនជាមួយវៀតណាមទេ តើបើសិនករណីហ្នឹងមែន តើលោកធ្វើអ្វីនៅវៀតណាម?

**ធ៖** សូមឆ្លើយ កាលនោះអត់បានទាក់ទងទៅនឹងប្រទេសគេទេ។ កាលហ្នឹង វៀតណាមគេដឹកជញ្ជូនអង្ករមកពីខ្មែរ។ ដឹកជញ្ជូនអង្ករ ដឹកជញ្ជូនកាំភ្លើងឲ្យខ្ញុំចំណាំព្រៃ ចំណាំទឹក ចំណាំអូរ ដើម្បីគេធ្វើខ្សែរយៈគេទាក់ទង គេដឹកជញ្ជូនអង្ករមកពីស្ទឹងត្រែងទុកកន្លែងណា អូរឡាឡៃ អូរដំបូក អូរអីខ្ញុំចំណាំៗ ឲ្យខ្ញុំនាំព្រៃ នាំអូរ ចំណាំ គេធ្វើកន្លែង គេធ្វើឃ្លាំងអង្ករគេ ធ្វើវំលងភ្នំ វំលងព្រៃទៀត។ គេធ្វើឃ្លាំង គេដឹកអន្លង់ គេលាក់កាំភ្លើងគេ ថ្នាំគេរបស់របរគ្រប់សព្វ អាហ្នឹងបានគេវាយរំដោះនៅឯហ្នឹង។ គេថាអ៊ីចឹង។ គេផ្អែកទៅលើ មិនមែនទៅទាក់ទងនៅប្រទេស គេពឹងផ្អែកខ្ញុំចំណាំនៅ ស្គាល់មាត់ញកព្រៃភ្នំម្តុំអាជិតព្រំដែនវាហ្នឹង ប៉ុណ្ណឹង។

**សៈ** ដើម្បីឲ្យខ្ញុំយល់កាន់តែច្បាស់នោះ តើអាវុធទាំងអស់ហ្នឹងឯគឺសម្រាប់យកទៅឲ្យអ្នកណាដែរ? ដែលបានលាក់ ហើយនិងដឹកនាំមកដល់ខេត្តស្ទឹងត្រែងហ្នឹង?

[១៥:២១:៥៥]

**ធ៖** កាលហ្នឹងអាវុធ គេថាគេវាយហាណូយហើយ បើដឹកមកពេលនោះ ព្រោះប្រទេសវាហ្នឹងវាអត់មានផ្លូវ អាហ្នឹងគេដឹកបង្វែងតាមកាប៉ាល់ ៗវាចុះពីភ្នំពេញ ឡើងពីភ្នំពេញទៅនៅព្រំដែននោះទៀត។ គេថា សីហនុៗ ល្អ! កុំទៅពួកខ្ញុំ! មានផ្លូវដឹកជញ្ជូនអង្ករ ដឹកជញ្ជូនកាំភ្លើង ដឹកជញ្ជូនគ្រប់សព្វ ដើម្បីបម្រើកងទ័ពវាយអាខ្លាំងនៅហាណូយហ្នឹង គេថាអ៊ីចឹង។

**សៈ** លោកជាសមាជិកចលនានោះ ហើយគេឲ្យលោកជាអ្នកនាំផ្លូវជនជាតិវៀតណាម ដែលដឹកអាវុធ។ ខ្ញុំមិនសួរយល់សោះ តើអាវុធហ្នឹង គឺសម្រាប់ៗយកទៅឲ្យរបប សីហនុ ឬសម្រាប់តែពួក

ខ្មែរក្រហម?

**ឆ៖** សូមឆ្លើយ អាវុធហ្នឹងអ៊ីចេះ គេដឹកមកពីប្រទេសគេហ្នឹងចុះភ្នំពេញ។ ដឹកពីភ្នំពេញហ្នឹងគេទៅលាក់នៅព្រំដែន ដើម្បីគេវាយរំដោះនៅអ៊ីចឹង។ មិនមែនថា គេឲ្យខ្មែរទេ គេដឹកមកផ្លូវយើង គឺចុះមកពីកាប៉ាល់ប្រទេសចិន បើកប៉ាល់ៗភ្នំពេញៗវាឡើងទៅទន្លេមេគង្គដល់ស្ទឹងត្រែង។ ដល់ស្ទឹងត្រែង គេដឹកអង្ករដឹកស្អី លាក់នៅព្រំដែន ពួកខ្ញុំនៅសព្វថ្ងៃ អ៊ីចឹង។

[១៥:២៣:៣៨]

**ស៖** តើអាវុធទាំងអស់ហ្នឹង គឺសម្រាប់ប្រគល់ជូនខ្មែរក្រហម ឬសម្រាប់ប្រើប្រាស់ ដោយពួកវៀតណាមហ្នឹងផ្ទាល់តែម្តង?

**ឆ៖** គឺរបស់ពួកវៀតណាមហ្នឹងហើយ វាមិនប្រគល់ឲ្យខ្មែរទេ។ វាដឹកជញ្ជូនដូចថា ផ្លូវយើងវាមានផ្លូវ ខាងអត់គេអត់មានផ្លូវ។ មិនមែនប្រគល់ឲ្យខ្មែរ មិនប្រគល់ឲ្យអ្នកណាទេ គេដឹកដោយសារផ្លូវយើងវាស្រួលអត់មានខ្មាំង។ គេថាអ៊ីចឹង ខ្ញុំសួរដែរ។

**ស៖** បាទ,សូមអរគុណ។សំណួរ ខ្ញុំសូមត្រឡប់មកនិយាយអំពីរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងតំបន់របស់លោក មុនរបបកម្ពុជាប្រជាធិបតេយ្យ គឺចាប់ពីពេលដែល លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សីហនុ រហូតដល់ការវាយយកទីក្រុងភ្នំពេញដោយរបបខ្មែរក្រហម គឺយើងកម្រិតត្រឹមតែរយៈពេលហ្នឹងទេ គឺពីឆ្នាំ៧០ ដល់ឆ្នាំ៧៥?

កាលពីព្រឹកមិញនេះ លោកបាននិយាយថា លោកបានចូលរួមសាងសង់ផ្ទះ មន្ទីរសម្រាប់ ប៉ុល ពត និងលោក អៀង សារី តើកន្លែងដែលលោកសាងសង់មន្ទីរ ហើយនិងផ្ទះនោះ តើមានឈ្មោះទេ?

[១៥:២៤:៥៩]

**ឆ៖** អាហ្នឹងមិនទាន់ ចលនា សង្គ្រាមទេអាហ្នឹង។ នៅកំពុងតស៊ូនយោបាយ កំពុងតែរៀបរៀងកម្មាភិបាល។ ក-៥ ព្រៃចុងអូរ ក-៥។ ឈ្មោះ ក-៥ ចុងអូរដាំង។ ពួកអ៊ំ អៀង សារី នៅជាមួយ តាពតនៅឯនុ៎ង។

**ស៖** សូមអរគុណ។ សំណួរ ក-៥ ហ្នឹងត្រូវបានសាងសង់មុនរដ្ឋប្រហារ លន់ នល់ គឺនៅឆ្នាំ៧៥ ឬមួយក៏បានកសាង-- សាងសង់ហ្នឹងក្រោយរដ្ឋប្រហារ?

**ឆ៖** មុនរដ្ឋប្រហារៗ។

**ស៖** ដូច្នេះ កាលពីព្រឹកមិញនេះ គឺលោកបាននិយាយថា គឺ ប៉ុល ពត និង អៀង សារី បានជា

អ្នកស្នើសុំឲ្យកសាង-- សាងសង់ក-៥ នេះ។ បើតាមលោកដឹងថា តើក-៥ នេះដំណើរការរួចមកហើយ នៅកន្លែងណាមួយផ្សេងទៀត មុននឹងលោកសាងសង់មន្ទីរ ឬក៏ផ្ទះនៅកន្លែងក-៥ ហ្នឹង?

[១៥:២៦:៣០]

**ឆ៖** មានតែមួយកន្លែងហ្នឹងហើយខ្ញុំ ដើម្បីបម្រើឲ្យ ធ្វើកន្លែងគេនៅ ក្រៅពីហ្នឹងខ្ញុំអត់ដឹងទេ ក្រៅពីហ្នឹង មុនមិនទាន់រដ្ឋប្រហារ ធ្វើកន្លែងគាត់ហ្នឹង។ គាត់នៅនោះ។

**ស៖** តើមេដឹកនាំហ្នឹងបានណែនាំយ៉ាងម៉េចខ្លះ? តើគាត់ប្រាប់ថា ហេតុអីបានជាគេសាងសង់ ក-៥ នៅកន្លែងហ្នឹង នៅពេលហ្នឹង? តើគេមានបានបញ្ជាក់ទេ?

**ឆ៖** បញ្ជាក់ស្អី គឺថាធ្វើកន្លែងគាត់ពួន ដើម្បីកុំឲ្យខ្មាំងវាឃើញ បបួលមនុស្សបានចូលហ្នឹង។ ខ្ញុំជាអ្នកដឹកនាំបងប្អូនភាគច្រើន ក្នុងមួយភូមិពីរបីនាក់ៗ ដើម្បីខ្លាចបែការណ៍សម្ងាត់។ ខ្លាចខ្មាំងវាដឹងកន្លែងគាត់ មានតែប៉ុណ្ណឹងទេ។

**ស៖** តើលោកអាចនិយាយប្រាប់យើងបានទេ ថាតើអគារហ្នឹងត្រូវបានសាងសង់យ៉ាងដូចម្ដេច? តើគេមានបច្ចេកទេសអីខ្លះក្នុងការសាងសង់ មានបច្ចេកទេសអីពិសេសដែរឬទេ?

[១៥:២៧:៥០]

**ឆ៖** ដឹងស្អី សាងសង់ស្អីមាន ប្រក់ស្បូវ នៅព្រៃប្រក់ស្បូវ កាប់ឫស្សីហ្នឹងរួចហើយ វាធ្វើអាហ្នឹងបាំងវា។ រយៈគេនៅហ្នឹងហើយ រយៈគេនៅកន្លះឆ្នាំ រើមកដល់រដ្ឋប្រហារ រត់មកខាងនេះរហូតដល់សព្វថ្ងៃ អ៊ីចឹង។

**ស៖** ប៉ុន្តែ តើផ្ទះហ្នឹងគឺនៅលើដី ឬនៅក្រោមដី?

**ឆ៖** កន្លែងតាពត ផ្ទាល់ហ្នឹង គេជីកអន្លង់ គេធ្វើឈើអ៊ីចេះ គេធ្វើអន្លង់អា ខ្លាចខ្មាំងវាឃើញ។ បើអ៊ំ អៀង សារី គាត់ដេកនៅលើ គេធ្វើគ្រែៗឫស្សី គេធ្វើគ្រែ។ ដុតភ្លើងកុំឲ្យមូសវាខាំ គាត់នេះ គាត់អ៊ំ អៀង សារី នេះ។ អា តាពត នេះដេកនៅអន្លង់ គេជីកអន្លង់ គេធ្វើអន្លង់អាជាឈើ។ គេលុបៗដី មានទ្វារចូល ទ្វារចេញ នៅក-៥ហ្នឹង។ ក្រោយៗហើយនោះ រដ្ឋប្រហារហ្នឹង ដល់ឆ្នាំ ជិតឆ្នាំ១៩៧០ នោះ។ ទម្លាក់គ្រាប់បែកតាមព្រំដែននោះ។ ហ្នឹងគាត់ចេញចូលមករហូតដល់សព្វថ្ងៃ ខាងនេះ។ ខ្ញុំអត់ឃើញ ហើយគាត់--

**ស៖** ដូច្នេះ វាជាកន្លែងដែលមានសុវត្ថិភាពណាស់ បើតាមខ្ញុំយល់នោះ។ ក្រៅពី ប៉ុល ពត និង អៀង សារី ដែលបាន លោកបាននិយាយពីមុននេះ តើមានមេដឹកនាំណាផ្សេងទៀតនៃចលនាបដិវត្តន៍

ឬក៏បក្សមកមន្ទីរក-៥ នេះដែរឬទេ?

**ឆ៖** បើគាត់ទៅផុតអត់មានហើយ មានតែលែងចោលហ្នឹង អត់មានពីណាទេ។ អត់ឃើញពីណា អត់ឃើញខ្មែរពីណាទេ។ ព្រោះគាត់ត្រឡប់មកខាងនេះ អត់ឃើញទេ។ គេអត់បានទៅ គេទម្លាក់គ្រាប់បែក ពួកខ្ញុំរើភូមិនៅព្រៃពីរឆ្នាំ អត់មានភូមិ អត់មានផ្ទះទេ នៅរហូតនៅព្រៃជីកអន្លង់រាល់ថ្ងៃៗបានរស់។ គេទម្លាក់គ្រាប់បែកតាំងពីពួកខ្ញុំនៅជិតព្រំដែនជាមួយវៀតណាមឯនោះ។ អត់ស្រណុកទេ ពួកអ៊ំនោះ មកខាងនេះទាំងអស់ អត់ឃើញ។

**ស៖** ប៉ុន្តែនៅពេលដែលលោកបញ្ចប់ការសាងសង់មន្ទីរក-៥ ហ្នឹង ថាតើមេក្រហមហ្នឹង គាត់ប្រើ ក-៥ ហ្នឹង ជាកន្លែងសម្រាប់ប្រជុំអី ឧទាហរណ៍ដែរឬទេ?

**ឆ៖** កន្លែងប្រជុំនោះ ប្រជុំនៅបុស្សចាស់គេធ្វើៗខ្ទម អាស្លឹកខិនម៉ា គេធ្វើខ្ទម មានអីគេធ្វើកៅអីដាក់ឈើពីរៗ គេអង្គុយ គេប្រជុំនោះ។ អត់មានស្រួលបួលទេ។

**ស៖** តើមានមេដឹកនាំខ្មែរក្រហមក្រៅពី ប៉ុល ពត ហើយនិង អៀង សារី ដែលទៅកន្លែងហ្នឹងសម្រាប់ធ្វើកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** ក្រោយគាត់ទៅ អត់ឃើញៗ។ អត់ឃើញពីណាមក យួនក៏អត់ឃើញ ខ្មែរក៏អត់ឃើញ លាវអត់ឃើញ មានពួកខ្ញុំម្ចាស់ការខ្លួនឯងតាមភូមិ។ គិតគូរការខ្លាចងាប់ ត្រូវគ្រាប់បែកអាមេរិកវាទម្លាក់នោះ។ ថ្ងៃនេះ នៅកន្លែងនេះ ថ្ងៃស្អែកទៅព្រៃនោះៗ ខ្លាចវាទម្លាក់គ្រាប់បែក។

[១៥:៣១:៣៣]

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេលប្រជុំមាន មានទេ?

**លោក ក្លាន វ៉ិត៖**

អត់មានៗ ពេលប្រជុំ ក្រោយមក។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** នៅពេលដែលគេបំផ្លាញមន្ទីរ ក-៥ ចោល តើផ្ទះប៉ុល ពត, អៀង សារី ហើយនិងការិយាល័យគាត់ហ្នឹង ស្ថិតនៅកន្លែងណានៅក្នុងព្រៃហ្នឹង តើមានឈ្មោះទេ? មានលេខកូនសម្រាប់ហៅកន្លែងហ្នឹងទេ?

**ឆ៖** នៅព្រៃៗ។ នៅព្រៃ ដើមឫស្សីខ្ពី ជើងភ្នំ ជើងអូរ។

**ស៖** តើផ្ទះហ្នឹងមានឈ្មោះទេ? នៅពេលដែលគេនិយាយពីផ្ទះហ្នឹង តើគេមានហៅផ្ទះហ្នឹងឈ្មោះអី ឧទាហរណ៍ដូចជា មន្ទីរក-៥ ឬក៏មានលេខឈ្មោះបដិវត្តន៍? ឬមានលេខកូដអីដែរឬទេ?

**ឆ៖** អត់មានអីទេ មានតែឈ្មោះគេថា ក-៥។ ក-៥ សម្រាប់មន្ទីរអង្គការ មានតែប៉ុណ្ណឹងទេ។

[១៥:៣២:៤៦]

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

និយាយយឺតៗ អ៊ំ យឺតៗ។

**លោក ក្លាន វ៉ិត៖**

បាទ។

**អ្នកសម្របសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចុះ កន្លែងប្រជុំឈ្មោះអី កន្លែងប្រជុំ? កន្លែងគេប្រជុំ?

**លោក ក្លាន វ៉ិត៖**

គេប្រជុំជិតកៀនកន្លែងគាត់ហ្នឹងហើយ។ អត់មានសាលាត្រឹមត្រូវទេ គ្រាន់តែមានតែដំបូលស្លឹកខិនម៉ា។ ក្រៅពីនេះ យកឈើហ្នឹងអង្គុយ ធ្វើកន្លែងអង្គុយ ធ្វើតុ ធ្វើតាំងណ៎ា។ អត់-- ពិបាកណាស់។

[១៥:៣៣:២២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

**ស៖** ពីព្រឹកមិញ ហើយនិងរសៀលនេះ គឺយើងបានសួរអំពីទំនួលខុសត្រូវរបស់លោកក្នុងឋានៈជាប្រធានភូមិ។ ខ្ញុំគិតថាគឺប្រហែលជាឆ្នាំ៧០ ហើយបន្ទាប់មកបានក្លាយទៅជាមេឃុំតាឡាវ ចាប់ពីឆ្នាំ៧៤ រហូតដល់ឆ្នាំ៧៦។ ខ្ញុំចង់ឲ្យលោកជម្រាប តើនៅសម័យនោះគឺសម្រាប់ឆ្នាំមុនខែ៤/៧៥ តើវាមានរចនាសម្ព័ន្ធគំរូសម្រាប់តំបន់របស់លោកទេ? ពីព្រោះថាអំមិញនេះ លោកបាននិយាយពីភូមិ ឃុំ តើថ្នាក់អីដែលលើ នៅលើពីលើឃុំ ហើយភូមិហ្នឹង?

**ឆ៖** ថ្នាក់លើ ខ្ញុំឆ្លើយថ្នាក់ គេចាត់តាំងថ្នាក់ឃុំ ថ្នាក់ស្រុក ដោយសារអី ដើម្បីដោយសារគ្រប់គ្រងប្រជារាស្ត្រ អប់រំខាងនយោបាយ ដើម្បីយល់បដិវត្តន៍ អ៊ីចឹង។

**ស៖** សូមអរគុណ។ ដូចលោកមិនឆ្លើយមិនត្រូវនឹងសំណួរទេ។ តើនៅពីលើឃុំតាឡាវ តើមានកម្រិតថ្នាក់រដ្ឋបាលអីផ្សេងទៀតនៅក្នុងតំបន់-- នៅក្នុងតំបន់ព្លិសានហ្នឹង តើវាមានរចនាសម្ព័ន្ធយ៉ាងម៉េច? អំមិញលោកបាននិយាយប្រាប់ខ្ញុំហើយ ប៉ុន្តែគឺអ្វីដែលលោកនិយាយហ្នឹងគឺថាក្រោយខែបួន

ឆ្នាំ៧៥ទេ។ ខ្ញុំចង់ដឹងគឺមុនខែបួន ឆ្នាំ៧៥ គឺចាប់ពីមាន តាំងពីថ្នាក់ភូមិ រហូតទៅដល់ថ្នាក់ភូមិភាគ។ តើវាមានកម្រិតអីផ្សេងគ្នាយ៉ាងម៉េច?

**ឆ៖** អត់មានថ្នាក់អីទេ។

**អ្នកសម្រួលភាសាឲ្យដើមបណ្តឹងរដ្ឋប្បវេណី៖**

មុន៧៥ហ្នឹង លើឃុំតាឡាវទៀត មានឋានានុក្រមអីទៀត មានរចនាសម្ព័ន្ធអីទៀតលើឃុំតាឡាវហ្នឹង មុន៧៥?

**ឆ៖** អត់មានៗ។

**ស៖** អ៊ីចឹងលោកបានប្រាប់ហើយ គឺថានៅសម័យហ្នឹង គឺអត់មានតំបន់ទេ ឬក៏ស្រុកទេ អ៊ីចឹងដែរឬទេ?

**ឆ៖** កាលហ្នឹងមានស្រុក។ ដល់ឆ្នាំ៧៥-- ៧៦ហ្នឹងគឺគេមានតំបន់ មានស្រុក។

**ស៖** តើនៅពីលើស្រុក តើមានថ្នាក់អីទៀត គឺចាប់ពីឆ្នាំ៧៦មក?

[១៥:៣៦:២២]

**ឆ៖** ថ្នាក់ស្រុក ថ្នាក់តំបន់ ថ្នាក់ភូមិភាគ។

**ស៖** ប្រសិនបើខ្ញុំយល់ច្បាស់ គឺថាយើងមានថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់តំបន់ ហើយនិងថ្នាក់ភូមិភាគ។ អ៊ីចឹងរចនាសម្ព័ន្ធហ្នឹង គឺថាមុន៧៥ ឬក៏ក្រោយខែបួន ឆ្នាំ៧៥ហ្នឹង?

**ឆ៖** អត់ចំណាំ ខ្ញុំភ្លេចហើយ អត់ដឹងឆ្នាំអីៗទេ អត់ចំណាំទេ ត្រចៀកវាថ្លង់។ សរសេរក៏អត់ចេះ អត់មានឯកសារ និយាយទ្រឹស្តីមុខទុកក្រោយ ក្រោយទុកមុខ អត់ចំណាំខែឆ្នាំ អត់ចំណាំទៅដោយសារគេប្រើប្រាស់ អត់ចំណាំ។ ខ្ញុំនិយាយដូចមនុស្សល្ងង់អត់ចេះអក្សរ ដូចមនុស្សខ្វាក់ភ្នែកធ្វើដោយសារខ្លាចគេ។ ខ្ញុំអត់ចំណាំខែឆ្នាំ ធ្វើចលនាហ្នឹង។ អ៊ីចឹង អត់លាក់លៀមទេ។

**ស៖** ខ្ញុំនឹងជួយលោក។ នៅពេលដែលលោកជាប្រធានភូមិ តើនៅសម័យនោះ គឺថានៅលើថ្នាក់ភូមិហ្នឹង គឺមានមេលោកទេ? មានមេឃុំ ហើយបន្ទាប់មកនៅឃុំហ្នឹងមានមេស្រុក ហើយមានមេភូមិភាគ មេតំបន់ មេភូមិភាគអី តើមានអ៊ីចឹងទេ?

[១៥:៣៧:៥៩]

**ឆ៖** មានក្អួយ! បើមិនមានម៉េច មានការចាត់តាំង! មាន។ ប៉ុន្តែខ្ញុំអត់ចំណាំខែ ចំណាំថ្ងៃ គេចលនាហ្នឹង។ មាន បើមិនមានម៉េច មានមនុស្សអប់រំ មានមនុស្សចាត់ចែង មានមនុស្សចាត់តាំង មានៗ

តំបន់ មានស្រុក មានឃុំ មានភូមិ មានក្រុម។ ម៉េចមិនមាន មាន។

**ស៖** បាទ, សូមអរគុណ។ បើសិនជាខ្ញុំយល់ច្បាស់គឺថាលោកដឹងអំពីរចនាសម្ព័ន្ធនៅពេលដែលលោកជាមេភូមិ នៅមុនឆ្នាំ៧៥ និងក្រោយឆ្នាំ៧៥ នៅពេលដែលលោកត្រូវបានដំឡើងឋានៈជាអនុលេខាស្រុក២១ គឺថាវាមានរចនាសម្ព័ន្ធដដែល មានក្រុម មានភូមិ មានឃុំ មានតំបន់ មានភូមិភាគ។ តើត្រឹមត្រូវដែរឬទេ អ្វីដែលខ្ញុំអះអាងនេះ?

**ឆ៖** ត្រឹមត្រូវក្លយ ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ចាប់ពីឆ្នាំ៧០ លោកបានដឹងថា សម្តេច សីហនុ បានអំពាវនាវឲ្យចូលរួមធ្វើបដិវត្តន៍ តើចាប់ពីការមានការអំពាវនាវហ្នឹង តើមានមនុស្សច្រើនទេដែលបានចូលរួមនៅក្នុងចលនាខ្មែរក្រហមនៅក្នុងតំបន់របស់លោក?

**ឆ៖** អត់ដឹងទេ ឃើញតែគេហៅពួកខ្ញុំ តាមស្រុក តាមភូមិហ្នឹងទេ។ ភាគច្រើនជនជាតិផ្សេងៗអត់ឃើញទេ។

[១៥:៤០:១១]

**ស៖** សូមអរគុណ។ ប្រសិនបើមានអ្នកថ្មី គឺនៅពេលដែលមានអ្នកថ្មីដែលចូលរួមនៅក្នុងចលនាបដិវត្តហ្នឹងតើអ្នកថ្មីហ្នឹងត្រូវអប់រំ ឬណែនាំដូចដែលកាលលោកធ្លាប់បានទទួលកាលពីទសវត្សរ៍៦០ដែរឬទេ?

**ឆ៖** ក្រោយគេចាត់តាំងឆ្នាំ៧៦ហ្នឹង ផ្សេងហើយ គេនិយាយ គេនិយាយផ្សេងហើយ។ ខ្លាំងខ្លាំងយ៉ាងម៉េច? គឺថាអនុវត្តបដិវត្តន៍សង្គមនិយម បើមិនទៅតាមមាគ៌ាបក្សអត់កើតទេ។ គេថាអ៊ីចឹង។

**ស៖** កាលពីព្រឹកមិញនោះលោកបាននិយាយជាច្រើនដងគឺថាលោកត្រូវបានបង្ខំក្នុងការចូលរួមនៅក្នុងចលនា។ តើលោកអាចនិយាយទេថា តើវាមានវិន័យយ៉ាងម៉េចនៅក្នុងបក្សហ្នឹង? តើលោកត្រូវធ្វើអ្វីខ្លះ? តើអ្វីដែលលោកមិនត្រូវធ្វើ?

**ឆ៖** ខ្ញុំសូមតបដោយសារ ធ្វើបដិវត្តន៍គឺវាមានគោលជំហរតឹងតែង មិនងាករេខាងនោះខាងនេះមិនងាប់ មិនខ្លាចលំបាក មិនខ្លាចវេទនា ខិតខំលះបង់ បើគ្មានគោលជំហរ អត់មានគោលនឹងនរ។ គោលជំហរនឹងនរដើម្បីឲ្យតស៊ូបដិវត្តយូរអង្វែង។ ទីពីរទៀត ឲ្យស្មោះត្រង់ជាមួយបក្ស ជាមួយប្រជាជន។ ហេតុនោះខ្លាច ព្រោះថាដូចខ្ញុំ ឃើញការលំបាកធ្វើបដិវត្តន៍ខ្លាចខ្ញុំរត់ទៅខ្មាំង អាហ្នឹងគេបង្រៀនឲ្យអ៊ីចឹងខ្ញុំយល់អ៊ីចឹង។ សូមអស់។

**ស៖** តើលោកអាចបញ្ជាក់បានទេថា តើអ្នកណាជាសត្រូវ? អ្វីដែលលោកនិយាយថាសត្រូវៗហ្នឹងអ្នកណាគេដែរ?

**ឆ៖** សត្រូវហ្នឹងដឹងមកពីអង្គការទេ គេថាសត្រូវ។ ពួកខ្ញុំអត់ដឹងទេ ខ្ញុំផ្ទាល់ គឺថា ពួកអាទាហាន លន់ នល់ គេថាសត្រូវ។ ខាងរដ្ឋាភិបាល ខាងបដិវត្តន៍គឺថា អ្នកស្រឡាញ់ប្រជាជនអ៊ីចឹង។

**ស៖** កាលពីព្រឹកមិញលោកនិយាយដែរថា គឺជនជាតិវៀតណាមជាខ្មាំងតើលោកនៅតែនិយាយរហូតថា អ្នកវៀតណាមជាខ្មាំងសត្រូវ ឬក៏លោកគិតថា ពេលណាមួយគាត់មិនមែនជាសត្រូវទេ?

[១៥:៤៣:១២]

**ឆ៖** ខ្ញុំឆ្លើយថា ការងារនេះដោយសារមកពីអ៊ំៗ។ កាលមុនដំបូងតស៊ូនយោបាយ គេប្រមូលកម្លាំងវ៉ៃខ្មាំងគឺថា យើងហៅបងប្អូនវៀតណាម យើងកុំហៅ យួន។ ហៅ យួន ដូចយើងស្អប់គេ។ គេប្រាប់អ៊ីចឹង។ អ៊ំ អៀង សារី ហ្នឹងហើយអប់រំខ្ញុំធ្វើប្រធានភូមិអង្កាល់ហ្នឹង។ ដល់ក្រោយគេថា ប្រវត្តិរូបខ្ញុំថា ខ្ញុំចូលបក្សសម្ព័ន្ធវៀតណាមអ៊ីចឹងទៀត គឺថាខ្មាំង អាយួននេះខ្មាំងកម្ពុជា លេបទឹកដីកម្ពុជាអ៊ីចឹងទៀត។ ខ្ញុំថា ខ្មាំងរបៀបម៉េច អ៊ំឲ្យពួកខ្ញុំហៅ បងប្អូនដល់ឥឡូវថា ខ្មាំងយួន បើយើងធ្វើបដិវត្តន៍មុនដំបូងនៅជាមួយគ្នា ស៊ីជាមួយគ្នា ដេកជាមួយគ្នា ដល់ឥឡូវម៉េចថា អាខ្មាំងយួនទៀតហ្នឹងខ្ញុំឆ្ងល់។ បើថាពួកខ្ញុំចូលបក្សសម្ព័ន្ធវៀតណាម ពួកអ៊ំហ្នឹងហើយនាំផ្លូវចូលបក្សសម្ព័ន្ធវៀតណាម។ ពួកអ៊ំហ្នឹងហើយប្រធាន ពួកខ្ញុំដឹងអីបក្ស អត់ដឹងបក្សកុម្មុយនីស្ត មិនដឹងអីបក្សអីទេ ជនជាតិនេះ។ ម៉ែខ្ញុំបង្គាប់ខ្ញុំកាន់ផ្គាក់កាន់ពូថៅធ្វើស្រែធ្វើចម្ការ។

[១៥:៤៤:១៣]

អ៊ំដឹកនាំខ្ញុំ ឲ្យចូលបក្សដោយសារអ៊ំ អ៊ំចោទខ្ញុំចូលបក្សសម្ព័ន្ធវៀតណាមខ្ញុំអត់ដឹងទេវៀតណាមចូលបក្សនោះបក្សនេះអត់ដឹង។ បើថាអ៊ំចោទខ្ញុំថ្ងៃក្រោយ ពួក នួន អ៊ំ អៀង សារី អ៊ំអីក៏ចូលបក្សវៀតណាមទាំងអស់ដែរ។ ខ្ញុំថាអ៊ីចឹងខ្ញុំឆ្លើយ។ ប្រវត្តិរូបខ្ញុំនេះនៅភ្នំពេញនៅទួលស្លែងនេះ។ សូមអស់។

**ស៖** សូមអរគុណ។ ខ្ញុំបានឮចំណុចពីរ នៅក្នុងចម្លើយរបស់លោក។ លោកនិយាយថា ទីមួយគឺថា មិនចាត់ទុកវៀតណាម មិនត្រូវហៅ យួន ទេ គឺត្រូវហៅ វៀតណាម ហើយគឺគេនិយាយប្រាប់ថាគេខ្មាំង តើសារពីរដែលគេប្រាប់លោកនោះគឺថានៅក្នុងពេលសម័យកាលតែមួយ ឬក៏មានការផ្លាស់ប្តូរគឺដោយសារមានការផ្លាស់ប្តូរទៅតាមពេលវេលា?

**ឆ៖** ផ្លាស់ប្តូរពេលវេលាឆ្នាំ១៩៧៦, ១៩៧៧ ហើយ។ មើលនៅវាយយួននៅឆ្នាំ១៩៧៤,

១៩៧៥ នៅព្រំដែន កំប៉ិកកំប៉ុកៗ។ ឆ្នាំនោះហើយគេប្រកាសអ៊ីចឹង។ ប្រកាសថា "យួន អាខ្មាំងបដិវត្តន៍លេបទឹកដីកម្ពុជា"។ ឆ្នាំនោះហើយ។

**ស៖** លោកបាននិយាយអំពីមេធំៗ ឬអ៊ំៗ បានជម្រាបលោកថា និយាយពីបញ្ហាអស់នេះលើវៀតណាម តើលោកចង់និយាយពីអ្នកណា ពេលនិយាយអ៊ំៗនោះ? អ៊ីចឹងអាចឱ្យឈ្មោះបានទេ ដែលលោកចាត់ទុកថា ជាអ្នកដឹកនាំជាន់ខ្ពស់របស់បក្សនោះ?

**ឆ៖** អ៊ំ អៀង សារី, តា ប៉ុល ពត ពួកហ្នឹងហើយធំ ក្រៅពីហ្នឹងពីណាធំទៀត?

**ស៖** តើលោកស្គាល់ឈ្មោះបដិវត្តន៍របស់លោក អៀង សារី ដែរឬទេ? តើកាលសម័យនោះ គេហៅឈ្មោះគាត់យ៉ាងម៉េចទៅ?

**ឆ៖** កាលនោះ ឈ្មោះអ៊ំគេហៅ បងវ៉ាន់។ កាលនៅក្នុងព្រៃ គេហៅ បងវ៉ាន់ៗ។

**ស៖** តើគាត់មានឈ្មោះបដិវត្តន៍ផ្សេងទៀតទេ ឬក៏មានឈ្មោះតែមួយនោះទេ?

**ឆ៖** ខ្ញុំឮតែមួយហ្នឹងហើយ ដល់មកក្រុងគេហៅថា អ៊ំ អៀង សារី ប៉ុន្តែកាលនៅព្រៃជាមួយពួកខ្ញុំ គេហៅ បងវ៉ាន់។ ប៉ុណ្ណឹងទេ ខ្ញុំដឹង។

**ស៖** ខ្ញុំសូមត្រឡប់មក ពេលដែលថា លោកជាប្រធានក្រុម ឃុំតាឡាវ វិញ។ អម្បាញ់មិញនេះលោកបាននិយាយអំពីភូមិ ហើយនិងក្រុម ឥឡូវនេះ ខ្ញុំចង់ដឹងសម័យអីដែលថាលោកជាប្រធានឃុំ មេឃុំនោះ តើមានសហករណ៍ដែលមានហើយឬទេ កាលនុ៎ងនៅតាមឃុំនុ៎ងមានសហករណ៍ដែរឬទេ?

**ឆ៖** កាលហ្នឹងមុនដំបូងធ្វើនៅក្នុងឃុំមិនទាន់មានទេ សហករណ៍នោះ កំពុងតែធ្វើប្រវាស់ដៃ។ សាមគ្គី ក្រុមសាមគ្គីប្រវាស់ដៃ ពលកម្ម។

**ស៖** បើអ៊ីចឹង អង្កាល់ហ្នឹង កាលដែលលោកជាប្រធានភូមិទេ អម្បាញ់មិញនេះលោកបានឆ្លើយថា លោកបានដំឡើងឋានៈជាមេឃុំតាឡាវ។ កាលដែលលោកជាប្រធានឃុំនោះ មានសហករណ៍ហើយឬនៅ ឬក៏មិនទាន់មានទេ?

**ឆ៖** មិនទាន់មានទេលោក ដល់គេចាត់តាំងខ្ញុំឆ្នាំ១៩៧៦ហ្នឹង ធ្វើអនុស្រុកនោះបានគេចាត់តាំងសហករណ៍។

[១៥:៤៨:៤៣]

**ស៖** បាទ, សូមអរគុណ។ អង្កាល់លោកជាមេឃុំ ហើយបន្ទាប់មកទៀតក្លាយជាមេស្រុកនោះ តើលោកបានទទួលបញ្ហាទាក់ទងទៅនឹងផលិតផលកសិកម្មដែរឬទេ?

**ឆ៖** អត់មានផលិតផលអីទេ ការស្អុតស្អាញ ឆ្នាំ១៩៧៦ ហើយដល់ខែ៦ គេមានផែនការ គេហៅប្រជុំ ដើម្បីបង្កើតសហករណ៍ប្រមូលផ្តុំដី ប្រមូលផ្តុំកម្លាំង ប្រមូលថ្នាក់នយោបាយ ហូបបាយរួម។

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីបញ្ហាមួយចំនួនដែលលោកបានលើកឡើងកាលពីព្រឹកមិញ ទាក់ទងទៅនឹងតួនាទី ហើយនិងមុខងាររបស់លោក អៀង សារី ហើយនិងឱកាសមួយចំនួន ដែលក្នុងឱកាសនោះលោកបានជួបគាត់។

ព្រឹកមិញនេះ លោកបាននិយាយអំពីកិច្ចប្រជុំពីរ ដែលលោកបានចូលរួម ហើយដែល អៀង សារី គាត់បាននិយាយនៅពេលនោះ។ អ៊ីចឹងខ្ញុំសូមជម្រាបជូនលោកថា នៅក្នុងសេចក្តីប្រកាសរបស់លោកមុន នៅចំពោះមុខចៅក្រមស៊ើបអង្កេតនោះ លោកបាននិយាយថា មានកិច្ចប្រជុំចំនួនបី។ អ៊ីចឹងខ្ញុំសូមបំភ្លឺ ពីមុនមកលោកបានិយាយថា កិច្ចប្រជុំនោះមាននៅឆ្នាំ៦៦, ៧០ ហើយនិង ៧៤ ហើយថ្ងៃនេះលោកបាននិយាយថាមានតែពីរ កិច្ចប្រជុំពីរទេ។ អ៊ីចឹងសូមបំភ្លឺម្តងទៀតបានទេ ថាតើមានកិច្ចប្រជុំពីរ ឬក៏បី ហើយពេលណា? ហើយមានវត្តមានលោក អៀង សារី ដែលហៅថាលោកអ៊ំវ៉ាន់នោះនៅពេលណា?

**ឆ៖** និយាយពីពួកគាត់ជាមួយអ៊ំ អៀង សារី មានតែពីរលើកទេ គាត់នៅព្រៃ។ គាត់ហៅប្រជុំមានពីរលើកនោះហើយ។ ក្រៅពីហ្នឹងមានតែគណៈភូមិភាគ ដូចជាអ៊ំវី, តាធិន, តាខាត់, តាបុត ដែលហៅប្រជុំ បើគាត់ថាបាត់ហើយ អត់ឃើញហើយ។ អ៊ំ អៀង សារី និយាយប្រាប់ស្មោះត្រង់។

**សៈ** តើលោកចាំ ខ្ញុំមិនដឹងថាលោកមានបញ្ហាកាលបរិច្ឆេទហ្នឹង តើលោកចាំរយៈពេល ដំណាក់កាលដែលថាលោកប្រជុំនុ៎ង តើការប្រជុំនោះវានៅជិតគៀកៗគ្នាទេ ឬក៏វាឃ្លាតឆ្ងាយពីគ្នា រយៈពេលពីការប្រជុំមួយទៅការប្រជុំមួយទៀតនោះ?

**ឆ៖** ប្រជុំនុ៎ង ខ្លះគេហៅប្រជុំនៅបានលុង។ ដល់គណៈភូមិភាគហៅប្រជុំនោះ ប្រជុំនៅបានលុង រយៈពីរថ្ងៃប៉ុណ្ណឹងទេ។ ដល់លើកក្រោយ មានតែតំបន់ហ្នឹងញឹកញាប់ តាធិន តំបន់១០១ គាត់ហ្នឹងញឹកញាប់ ហៅប្រជុំ មួយខែម្តង ពីរខែម្តង តាធិន នោះ។ គាត់ប្រធានតំបន់។

**សៈ** ការប្រជុំលើកទីមួយ ដែលលោកបានឃើញលោក អៀង សារី នោះ ខ្ញុំមិនដឹងថាជាលើកទីមួយ ឬក៏មិនមែនលើកទីមួយទេ តើក្នុងកិច្ចប្រជុំនោះវាកើតឡើងនៅមុនរដ្ឋប្រហារ លន់ នល់ ឬក៏នៅក្រោយរដ្ឋប្រហារ លន់ នល់?

**ឆ៖** មុនៗ មុនរដ្ឋប្រហារ។ គាត់នៅព្រៃនោះមុនរដ្ឋប្រហារ។

**សៈ** តើអាន៎ុងជាលើកទីមួយហើយ ដែលលោកឃើញលោក អៀង សារី នោះ ឬក៏បានជួបគាត់មុនហ្នឹងទៅទៀត ក៏ប៉ុន្តែលោកមិនធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំ ដែលគាត់ជាអ្នកដឹកនាំនោះ?

[១៥:៥៣:៥៧]

**ឆៈ** មានតែពេលប្រជុំនោះហើយឃើញគាត់ ព្រោះពេលគាត់ហៅប្រជុំមានពីរលើកហ្នឹងហើយឃើញគាត់។ អត់បានចូលទេអាកន្លែងគេផ្ដេសផ្ដាស គេមិនឲ្យចូលទេ។ បើគេហៅប្រជុំនោះ ក្រៅពីកន្លែងគាត់នៅ អាហ្នឹងបានឃើញ។

**សៈ** អ៊ីចឹងនៅពេលប្រជុំលើកទីមួយនោះ តើលោកចាំពីបរិបទនៃកិច្ចប្រជុំនោះទេ? ហើយនៅពេលន៎ុងតើមានអ្នកដែលនៅក្បែរៗអៀង សារី មានទេ ដែលថានៅក្នុងចំណោមអ្នកដឹកនាំធំៗនោះ ដូចគេហៅថា អ៊ំនោះណ៎ា?

**ឆៈ** អង្គាល់ហ្នឹងឃើញជាក់ស្ដែង មកដល់ជួបមែនទែនជាមួយគាត់មានតែ ប៉ុល ពត នោះហើយ។ ពួកគាត់ក្រៅពីនោះក៏រវល់ឃើញ អ៊ំយ៉ា។ មានតែឃើញគាត់ពីរនាក់ហ្នឹងហើយ។ អ្នកអប់រំហ្នឹង អ៊ំ អៀង សារី អ៊ំពតហ្នឹងនៅមួយកន្លែង។ នៅកន្លែងបន្ទាយគាត់ហ្នឹងហើយ គាត់នោះបើពេលគេប្រជុំហ្នឹង គេបញ្ចេញ កន្លែងគាត់នៅ ហ្នឹងបានឃើញអ៊ំ អៀង សារី អ៊ីចឹង។

**សៈ** កាលសម័យនោះហ្នឹង តួនាទី មុខងាររបស់ អ៊ំយ៉ា ហ្នឹងអីទៅ?

**ឆៈ** ឮគេផ្សព្វផ្សាយថាគណៈភូមិភាគ។ គណៈភូមិភាគឦសាន មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ គេផ្សាយណា។ គាត់បង្ហាញខ្លួន គាត់មានភារកិច្ច ខ្ញុំជាអ្នកគ្រប់គ្រងហ្នឹងមាន បួនខេត្តអ៊ីចឹងខ្ញុំបានដឹង។ បើគាត់អត់បង្ហាញខ្លួន ខ្ញុំអត់ដឹងទេ។

**សៈ** បាទ, ខ្ញុំសូមអរគុណ។ តើនៅក្នុងកិច្ចប្រជុំទាំងពីរជាមួយ អៀង សារី ហ្នឹង ប្រសិនជាលោក អៀង សារី បាននិយាយអំពីសាសនា ឬក៏ជំនឿអ្នកតា ឬក៏អារក្សអ្នកតាថែរក្សាហ្នឹង តើគាត់បាននិយាយអំពីអ្វីខ្លះនៅពេលហ្នឹង?

**ឆៈ** កិច្ចការប្រជុំហ្នឹង គាត់ប្រកាសកុំឲ្យថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ភូមិដើម្បីដឹងអ្នកណាខ្មាំងណាសត្រូវ។ យ៉ាងម៉េចគេថាខ្មាំង យ៉ាងម៉េចគេថាសត្រូវ បងប្អូនយល់ទេ ឬក៏មិនយល់? ពួកខ្ញុំថា អត់យល់ទេ។ ពួកដែលជិះជាន់ប្រជារាស្ត្រហ្នឹង គេថាខ្មាំង។ គេថាសត្រូវអ្នកជិះជាន់ អ្នកស៊ីឈ្នួល (ឮមិនច្បាស់) អ្នកនោះគេថាសត្រូវ។ នោះគាត់ប្រកាស គាត់បង្រៀនឲ្យដើម្បីដឹងអ៊ីចឹង អ៊ំហ្នឹង។

**សៈ** ហើយនៅក្នុងរយៈពេលហ្នឹង លោកត្រូវបានគេអនុញ្ញាតឲ្យប្រតិបត្តិសាសនាដែរឬទេ? អានេះនៅក្នុងករណីដែលថាលោកមានកាន់សាសនា ឬក៏កាន់សាសនាជំនឿអ្នកតាជាដើមនោះ?

**ឆៈ** សូមឆ្លើយអត់មានទេ តឹងតែង។ គេថាមិនឲ្យជំនឿទេ អារក្សអ្នកតាសែនព្រេន ជូនកាលឈឺគ្រុន ស្លាប់រស់ យើងទៅរកពេទ្យ។ មើលបងប្អូនខាងក្រោមនោះ ខ្មែរក្រោមអត់មានលោកសង្ឃ អត់មានវត្តទេ បងប្អូន។ បងប្អូនជនបទនោះអត់មានវត្តអារាមនោះ សែនព្រេន បើកើតការឈឺគ្រុនឥឡូវអត់មានទេ អត់មានហើយ។ គាត់ឃោសនាអ៊ីចឹង។

[១៥:៥៨:២៨]

**សៈ** តើលោកទទួលយកការបង្គាប់បញ្ជាមិនឲ្យគោរពសាសនា ឬក៏អ្នកតាហ្នឹង លោកទទួលយកដោយស្រួលដែរ ឬទេ? ឬក៏យ៉ាងណា?

**ឆៈ** អត់ទទួលស្រួលដែរ ខ្ញុំខ្លាចដោយសារជនជាតិពួកខ្ញុំវាធ្លាប់សែនព្រេន ដូចបងប្អូនខ្មែរខាងក្រោម មានវត្ត មានវ៉ា មានអារាម ឥឡូវគេអត់ឲ្យមាន វាស្លុតស្មាញដែរ សតិអារម្មណ៍ហ្នឹង។ បើថាអប់រំខ្លាំង ប្រជាជន ខ្លាចប្រជាជនវាយខ្ញុំចោល វាយចោលខ្ញុំ។ បើមិនផ្សាយផែនការរបស់គាត់ហ្នឹងខ្ញុំខ្លាចគាត់និយាយឲ្យខ្ញុំខ្លាំងថា ខ្ញុំអត់មានជំហរ។

**សៈ** អ៊ីចឹងនៅពេលដែលលោក អៀង សារី និយាយពីរឿងអស់នេះនៅក្នុងកិច្ចប្រជុំទាំងពីរនេះ លោកបានថា គឺនៅអង្កាល់នោះមុនរយៈពេលដែលថា មុនសម័យដែលភ្នំពេញមិនទាន់ធ្លាក់ទៅក្នុងដៃខ្មែរក្រហមនោះ តើនេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆៈ** ត្រឹមត្រូវក្អួយ ត្រឹមត្រូវ។ ដោយសារវាមិនទាន់រំដោះ គាត់ពួននៅព្រៃអ៊ំ អៀង សារីនៅព្រៃ លើភ្នំ។

[១៦:០០:១០]

**សៈ** បើសិនជានរណាម្នាក់ក្នុងចំណោមក្រុមបក្ស-- អ្នកធ្វើបដិវត្តន៍ហ្នឹងចង់ទៅវត្ត ឬក៏យកចង្ហាន់ទៅប្រគេនលោកសង្ឃនោះ តើពួកគេនោះនឹងអាចត្រូវរងទារុណកម្មអ្វី ឬក៏ការបរិហារកេរ្តិ៍អ្វីខ្លះទៅសម័យនោះ?

**ឆៈ** ប៉ុន្តែ ការងារនេះដោយសារខាងក្រោមហ្នឹង គេនៅមានដែរ ប៉ុន្តែគេនិយាយប្រកាសដើម្បីពួកខ្ញុំជនបទហ្នឹង វាអត់វត្តវ៉ាដែរ មានតែជំនឿសង្គម សែនព្រេនពេលឈឺគ្រុន។ អាហ្នឹងគាត់ឃោសនាឲ្យខាងពួកខ្ញុំមិនឲ្យជឿអារក្ខអ្នកតា ដោយសារអី? បើធ្វើជឿអារក្ខអ្នកតាហ្នឹង អត់កើតទេធ្វើបដិវត្តន៍។

**អ្នកសម្រួលភាសាឲ្យដើមបណ្ដឹងរដ្ឋប្បវេណី៖**

ចុះទទួលទណ្ឌកម្ម អ្នកដែលគោរពសាសនា ឬក៏អ្នកគោរពអារក្ខអ្នកតាហ្នឹង គេធ្វើទណ្ឌកម្មដែរ?

**ឆ៖** អត់ទេ។ មិនធ្វើទណ្ឌកម្មទេ។ បើមិនជឿគេ ម៉េចមិនទណ្ឌកម្ម? ពួកខ្ញុំធ្វើកម្មាភិបាលហើយ គេវាយចោល គេបន្ទោសអ៊ីចេះ អ៊ីចុះ ថាមិនគោរពមាគ៌ាបក្ស។ និយាយស្អីក៏ផ្អែកទៅលើបក្សកុម្មុយនីស្ដ វាមិនលេងទេ បក្សកុម្មុយនីស្ដវាខ្លាំង។ ពីណាតវ៉ា ពីណាប្រឆាំង គឺថាអត់ផ្លូវដើរហើយ គឺថាអ៊ីចឹង គេគំរាមអ៊ីចឹងណា។ ដោយសារហ្នឹងហើយ បានពួកខ្ញុំខ្លាច ចេះតែធ្វើ ចេះតែទៅ ព្រោះខ្ញុំនៅជនបទ ចុងកាត់មាត់ញក វាមនុស្សវាល្ងង់ មនុស្សវាងងឹតភ្នែក ចេះតែធ្វើតាម គេធ្វើយ៉ាងម៉េចក៏ធ្វើតាម។ អ៊ីចឹងណ៎ា ខ្លាចចិត្ត ដោយសារមិនមែនថាយល់ ខ្លាច ចេះតែខ្លាច ចិត្តអាណិតគេ។ អត់យល់ទេបដិវត្តន៍ អត់យល់។ ទោះខ្ញុំ គេក៏ដោយ ដោយសារខ្លាច។

[១៦:០២:២៨]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញារង តើនៅមានសំណួរប៉ុន្មានទៀតដែលគ្រោងសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន បើយើងត្រូវការរយៈពេលប្រហែលមួយម៉ោងទៀត ដើម្បីចោទសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី។ បើសិនជាលោកប្រធានចង់បញ្ឈប់យើងឥឡូវនេះ ក៏យើងឈប់ក្នុងពេលឥឡូវនេះក៏បានដែរ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។

[១៦:០៤:១៣]

ឥឡូវនេះដល់ម៉ោងសមល្មមនឹងសម្រាកនៅរសៀលនេះហើយ ប៉ុន្តែមុននឹងសម្រាក ដោយសារស្ដាប់នូវយោបល់របស់សហព្រះរាជអាជ្ញារងអន្តរជាតិអំមិញថា មានពេលវេលាត្រូវចំណាយប្រហែលជាមួយម៉ោងទៀត។ ដោយពេលវេលានៃកិច្ចដំណើរការរបស់យើងហ្នឹង មានកំណត់ ដែលគួរតែប្រឹងប្រែង ដើម្បីឲ្យកិច្ចដំណើរការហ្នឹងបានឿនលឿន អង្គជំនុំជម្រះនឹងផ្ដល់វេទិកាទៅឲ្យសហព្រះរាជ

អាជ្ញាអាចបន្តនៅព្រឹកថ្ងៃស្អែកកន្លះម៉ោងទៀត។

ដូច្នេះសូមសហព្រះរាជអាជ្ញាត្រៀមរៀបចំជ្រើសរើសនូវសំណួរដែលមានខ្លឹមសារ និងសំខាន់ៗ ពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអាចសួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមត្រូវ។ ហើយសវនាការ នឹងលើកបន្តទៅព្រឹកថ្ងៃស្អែកចាប់ផ្តើមពីម៉ោងប្រាំបួន។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោកប្រធាន លោកនួន ជា នឹងត្រូវមកផ្តល់សក្ខីកម្មនៅស្អែកនេះ ឬយ៉ាងម៉េច? ខ្ញុំចង់បានការ ពន្យល់ ថាតើគាត់នឹងចូលមកផ្តល់សក្ខីកម្មនៅពេលណា?

**ប្រធានអង្គជំនុំ៖**

ការបន្តស្តាប់ចម្លើយរបស់ នួន ជា អាស្រ័យលើលទ្ធភាពនៃការធ្វើសវនាការស្តាប់ចម្លើយដើម បណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត។ មានន័យថា បន្ទាប់ពីការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី រូបនេះចប់ នោះអង្គជំនុំជម្រះនឹងបន្តក្នុងការសួរដេញដោលចំពោះ នួន ជា ជាបន្ត។

[១៦:០៧:១០]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោកប្រធាន ខ្ញុំប្រហែលជាចង់ទទួលបានការបញ្ជាក់ពីភាគីដទៃ ថាតើគេត្រូវការរយៈពេល ប៉ុន្មានដែរ? ប្រហែលជាអាចប្រាំនាទី ឬក៏យ៉ាងម៉េចហ្នឹង?

**ប្រធានអង្គជំនុំ៖**

ភាគីផ្សេងទៀត មេធាវីលោក អៀង សារី ហើយមេធាវីលោក ខៀវ សំផន តើក្រុមមេធាវី របស់លោកទាំងពីរហ្នឹង មួយក្រុមៗអាចចំណាយពេលវេលាប៉ុន្មានដែរ សម្រាប់សួរដើមបណ្តឹងរដ្ឋប្ប- វេណីរូបនេះ?

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំត្រូវការសាកសួរទៅដើមបណ្តឹងរដ្ឋ ប្បវេណីសិន បើអាចជា១៥នាទី ទៅ៤៥នាទី។ អ៊ីចឹង ខ្ញុំត្រូវការសាកសួរដើមបណ្តឹងរដ្ឋប្បវេណីសិន មុននឹងកំណត់ពេលវេលានេះ ត្រូវទាក់ទងទៅនឹងអំឡុងពេលដែលមានការពាក់ព័ន្ធ ដូច្នេះខ្ញុំគិតថា យ៉ាង

ហោចណាស់ក៏ត្រូវការចន្លោះពី១៥ ទៅ៤៥នាទីដែរ។

**លោក អាកទួរ វ៉េកកែន៖**

ចំពោះក្រុមការពារ ខៀវ សំផន ក៏ដូចគ្នាដែរ គឺរយៈពេលប្រហែល៤៥នាទីហ្នឹងដែរ។

**ប្រធានអង្គជំនុំ៖**

តាមការផ្តល់ព័ត៌មាននេះបង្ហាញថា ការប៉ាន់ប្រមាណនូវការតាំងសំណួររបស់ភាគីតទៅនៅព្រឹកថ្ងៃស្អែកចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ទំនងជាមិនអាចកំណត់ពេលវេលាជាក់លាក់ទេ។ ដោយហេតុការសន្សំសំចៃពេលវេលាក្នុងការដេញដោល។ ដូច្នេះ គឺអង្គជំនុំជម្រះកំណត់នូវរបៀបនៅក្នុងការនីតិវីធីនៅក្នុងការសួរដេញដោល គឺក្រោយពីសួរស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីចប់ គឺយើងនឹងបន្តការសួរដេញដោលចំពោះលោក នួន ជា។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅមន្ទីរឃុំឃាំងវិញ ហើយឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះ នៅព្រឹកថ្ងៃនេះស្អែកឲ្យបានមុនម៉ោងប្រាំបួន។

អង្គជំនុំជម្រះប្រកាសសម្រាកត្រឹមនេះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*